01193772

E1/370.1/Old-1

OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2016, 12:43
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅជំណាក់កាលពីរ**

**សាធារណៈ – កោសល្យ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៥១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| 2-TCW-1000 | ខ្មែរ |
| លោក ថេង ផល (2-TCW-848) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-1000

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ ទំព័រ ៤
សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ ទំព័រ ៤១
សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ ទំព័រ ៥៦

**ការសួរសំណួរទៅសាក្សី៖ លោក ថេង ផល** (2-TCW-848)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ៦២
សួរដោយលោក សេង លាង ផ្តើមពី ........................................ ទំព័រ៦៦
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី........................................ ទំព័រ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជំនុំជម្រះលើអង្គសេចក្តីពិនិត្យភស្តុតាងលើសំណុំរឿង០០២/០២។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម [2-TCW-1000] ដែលនឹងត្រូវសួរដេញដោលដោយក្រុមសហមេធាវីការពារក្តីទាំងពីរក្រុម ហើយនិងមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម [2-TCW-848]។ ហើយអង្គ -- មុននឹងបន្តដំណើរការនីតិវិធីសវនាការក្នុងការស្តាប់សក្ខីកម្មសាក្សីនៅថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីទាំងអស់នៃរឿងក្តីថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ នឹងអាចថ្ងៃសវនាការបន្តបន្ទាប់ លោកចៅក្រម យ៉ា សុខន ដែលជាចៅក្រមជាតិអវត្តមាន ដោយមូលហេតុគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងចៅក្រម បណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិ ជំនួសកន្លែងចៅក្រម យ៉ា សុខន ដែលអវត្តមាននៅថ្ងៃនេះ និងថ្ងៃបន្ទាប់រហូតដល់ពេលលោកចៅក្រម យ៉ា សុខន មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ នៅអង្គជំនុំជម្រះសាលាដំបូងនេះវិញបាន។ ហើយការសម្រេចនេះ ដោយផ្អែកលើបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បាទ ជាបន្តទៅនេះ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោកស្រី អង់តា ហ្គីសសេ មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន និងលោក ខលវីន សោនដឺស៍ មេធាវីអន្តរជាតិប្រចាំការសម្រាប់លោក ខៀវ

សំផន អវត្តមាន ដោយមូលហេតុផ្ទាល់ខ្លួន។

[០៩:០៨:២៩]

ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ មានរហស្សនាម [2-TCW-1000]។ សាក្សីនិងមេធាវីប្រឹក្សា គឺលោក មឿន សុវណ្ណ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

នៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម[2-TCW-848]។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា ឬលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះ បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីព្រឹកមិញ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំះ**

បាទ អរគុណ កញ្ញា ជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើរសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ដោយមេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:១០:២៤]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោកចោទ នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះខ្លាំងមិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃផ្ទៃ៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:១១:២០]

បាទ ហើយមុននឹងអញ្ជើញសាក្សី និងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនេះ អង្គជំនុំជម្រះសូមជម្រាបជូនភាគីនៃរឿងក្តីនេះឱ្យបានជ្រាបថា សវនាការស្តាប់សារណាផ្ទាល់មាត់របស់ភាគីចំពោះសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា និងសហមេធាវី -- និងសហព្រះរាជអាជ្ញាដែលស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅបន្ថែមសាក្សីមួយចំនួន និងទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីអនុលោមតាមវិធាន៨៧(៣) ហើយនិង ៨៧(៤) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងអង្គហេតុ ការប្រព្រឹត្តចំពោះក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាម ឯកសារE380, E381 និងE382 ដែលអង្គជំនុំជម្រះគ្រោងធ្វើនៅព្រឹកនេះនោះ ត្រូវលើកទៅធ្វើនៅព្រឹកស្អែកវិញតាមសំណើរបស់សហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ អ៊ីចឹង សូមភាគីជ្រាប។

ហើយទី២ គឺអង្គជំនុំជម្រះចេញនូវសេចក្តីសម្រេចផ្ទាល់មាត់ចំពោះសំណើសុំរបស់ ខៀវ សំផន ដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកនូវឯកសារចំនួនបួនជាភស្តុតាងក្នុងការសួរដេញដោលសាក្សីដែលមានរហស្សនាម [2-TCW-1000]។

អង្គជំនុំជម្រះបានទទួលសំណើមួយពីមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ សូមឱ្យទទួលយកនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីចំនួនបួនធ្វើជាឯកសារភស្តុតាងមុនពេលមេធាវីការពារក្តីសួរដេញដោលសាក្សី [2-TCW-1000], ឯកសារ E319/23/2។

អង្គជំនុំជម្រះពុំបានទទួលចម្លើយតបណាមួយពីភាគីផ្សេងទៀតត្រឹមកាលបរិច្ឆេទចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥ ដែលអង្គជំនុំជម្រះបានកំណត់ឡើយ។ អង្គជំនុំជម្រះសន្និដ្ឋានថា សំណើនេះបានដាក់ទាន់ពេលវេលាដោយសារកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមិនអាចរកបាននូវមុនពេលចាប់ផ្ដើមដំណើរការសវនាការសំណុំរឿង០០២/០២។

[០៩:១៣:៣០]

កំណត់ហេតុស្ដាប់ចម្លើយទាំងនេះត្រូវបានរៀបចំដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយហេតុនេះស្របទៅនឹងបទដ្ឋាននៃភាពជឿជាក់ និងយថាភាព តាមការវិភាគបឋមដោយផ្អែកលើសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី អង្គជំនុំជម្រះយល់ឃើញបន្ថែមទៀតថាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីទាំងនេះជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ នឹងអាចជាប្រយោជន៍ក្នុងការស្វែងរកការពិត។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកឯកសារទាំងបួនដែលបានស្នើសុំនេះធ្វើជាឯកសារភស្ដុតាងនៅក្នុងរឿងក្ដីនេះ។

បាទ ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី [2-TCW-1000] ហើយនិងមេធាវីប្រឹក្សាសាក្សីលោក មឿន សុវណ្ណ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ហើយដំបូងនេះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់ សូមជូនពរឆ្នាំថ្មីដល់អស់លោក លោកស្រីទាំងអស់គ្នានៅក្នុងបន្ទប់សវនាការទាំងអស់នេះ។

[០៩:១៦:៣០]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរតិចតួចទេ ដើម្បីសួរទៅលោកនៅព្រឹកនេះ។ គឺសំណួរសួរបន្តពីសក្ខីកម្មរបស់លោកកាលពីថ្ងៃមុន។ ហើយខ្ញុំសូមចាប់សួរលោកអំឡុងឆ្នាំ១៩៧២-៧៣

ដែលលោកបានឆ្លើយថា លោកបានចូលបដិវត្តន៍នៅពេលនោះ។ តើលោកបានចូលបដិវត្តន៍នៅក្នុងឆ្នាំ ១៩៧៣មែនទេ បើខ្ញុំស្តាប់មិនច្រឡំទេ?

**លោក 2-TCW-1000៖**

**ឆ៖** បាទ នៅក្នុងអំឡុងនោះ ខ្ញុំចូលនៅឆ្នាំ៧២ ថ្ងៃទី២ ខែ៥ ឆ្នាំ៧២ បាទ ចូលនៅតំបន់ខេត្ត កំពត។

**ស៖** បាទ សូមទោស គឺឆ្នាំ៧២។ សូមលោកជួយរៀបរាប់ជូនតុលាការបន្តិចមក នៅក្នុងឆ្នាំ -- មុនឆ្នាំ១៩៧៥ តើលោកមានតួនាទីធ្វើអ្វីដែរ នៅក្នុងខេត្តកំពតនោះ នៅក្នុងបណ្តាឆ្នាំមុនៗ ឆ្នាំ១៩៧៥ លោកធ្វើអ្វីឲ្យពិតប្រាកដទៅ?

[០៩:១៧:៥១]

**ឆ៖** បាទ ខ្ញុំថ្លែងអំណរអរគុណដ៏ជ្រាលជ្រៅណាស់ ហើយសម្តែងនូវការស្មោះត្រង់ បាទអត់លាក់ អត់លៀមអីនូវភារកិច្ចរបស់ខ្លួនដែលខ្លួនធ្វើទេ។ បាទ ខ្ញុំធ្វើជានីរសាររនៃវរសេនាតូចទេ អត់មានធ្វើអីដ៏ធំដុំទេ។ បាទ អរគុណ។

**ស៖** ហើយតើអ្នកណាជាមេបញ្ជាការនៅក្នុងកងវរៈរបស់លោកហ្នឹង?

**ឆ៖** បាទ អរគុណណាស់ នៅក្នុងវរសេនាតូចរបស់ខ្ញុំ ហើយខ្ញុំជានីរសាររបស់គាត់ហ្នឹង ឈ្មោះ តាម៉ន បាទ តាម៉ន បញ្ជាការនៃវរសេនាតូចរបស់ខ្ញុំ ហើយខ្ញុំជានីរសាររបស់គាត់ផ្ទាល់តែម្តង។

**ស៖** ហើយលោកធ្វើជានីរសាររបស់គាត់ហ្នឹងចាប់ពីពេលណា ទៅដល់ពេលណា?

**ឆ៖** បាទ ខ្ញុំធ្វើជានីរសាររបស់គាត់នៅឆ្នាំ៧៣។ ពី៧២ មក៧៣មក បានអង្គការបញ្ជូនខ្ញុំឲ្យទៅនៅភូមិភាគតែម្តងបាទ។

[០៩:១៩:២៩]

**ស៖** លោកចង់និយាយថាម៉េច ដែលថាគេបញ្ជូនលោកទៅភូមិភាគហ្នឹង។ នៅពេលដែលលោកធ្វើការនៅក្នុងទឹកដីខេត្តកំពតហ្នឹង គឺថាលោកមិនចំណុះឲ្យភូមិភាគទេឬ?

**ឆ៖** បាទ នៅឆ្នាំ៧២ ខ្ញុំនៅធ្វើសកម្មភាពនៅខេត្តកំពត។ ដល់ឆ្នាំ៧៣ អង្គការបានបញ្ជូននៃវរសេនាតូចរបស់ខ្ញុំនេះឲ្យមកធ្វើសកម្មភាពនៅដោះកញ្ជរ មកចូលមកទៅទីក្រុងភ្នំពេញហ្នឹងមក។

**ស៖** លោកបានឆ្លើយថាលោកធ្វើជានីរសាររបស់ដល់ឆ្នាំ១៩៧៣។ ចុះក្រោយពីឆ្នាំ១៩៧៣ មក លោកធ្វើអ្វី?

**ឆ៖** បាន ខ្ញុំក្រោយពីឆ្នាំ៧៣ហ្នឹងមក ចូលឆ្នាំ៧៤ ខ្ញុំអត់មានធ្វើទេ។ គេឲ្យនៅជាកងកាំភ្លើងធំតែម្ដង បាទ ដកពីនីរសារ ហើយនៅកងកាំភ្លើងធំ បាញ់កាំភ្លើងធំ។

**ស៖** នៅក្នុងកងកាំភ្លើងធំហ្នឹង លោកមានតួនាទីអ្វីពិតប្រាកដនោះ?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំសម្ដែងនូវការស្មោះត្រង់ អត់ទេ អត់មានធ្វើអីទាំងអស់កាលនោះ បាទ ខ្ញុំជាយុទ្ធជន បាទ។

**ស៖** តើលោកមានបានចូលរួមប្រយុទ្ធនៅតាមបណ្ដាសមរភូមិ ប្រយុទ្ធជាមួយហ្នឹងទាហាន លន់ នល់ ដែរទេ នៅពេលដែលលោកនៅក្នុងកងកាំភ្លើងធំនុ៎ង?

**ឆ៖** បាទ កាលក្នុងនោះ ក្នុងសង្គ្រាមបានប្រយុទ្ធជាមួយទាហាន លន់ នល់ ពិតប្រាកដ។

[០៩:២១:៥៣]

**ស៖** តើកងកាំភ្លើងធំរបស់លោកហ្នឹងមានសមាជិកប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ អរគុណណាស់។ ក្នុងមួយវរសេនាតូចហ្នឹង មានកាំភ្លើង -- មានអនុសេនាធំ តែចែកជាក្រុម បាទ ក្រុមកាំភ្លើង មានក្រុមខ្លះកាំភ្លើង ដេ.កា៧៥ មានកាំភ្លើងខ្លះ កាំភ្លើង៨០មិល្លីម៉ែត្រ មានកាំភ្លើង៦០ និងកាំភ្លើង ដេ.កា៧៥ បាទ។ អ៊ីចឹងខ្ញុំនៅខាងកាំភ្លើង ៨១ –៨១ មិល្លីម៉ែត្រ។

**ស៖** ប៉ុន្តែនៅក្នុងកាំភ្លើងធំនុ៎ង តើលោកគ្រាន់តែជាយុទ្ធជនម្នាក់ ដើម្បីក្នុងការប្រយុទ្ធហ្នឹង ឬក៏ថាលោកក៏មានកូន -- ឬក៏មានកងទ័ពនៅពីក្រោមការបញ្ជារបស់លោកដែរ?

**ឆ៖** បាទ អត់មានទេ គ្រាន់តែខ្ញុំទទួលតែបញ្ជាពីខាងលើដែរទេ បាទ។ នៅកាំភ្លើងធំ បើថាឲ្យខ្ញុំបញ្ជាពីលើមកអត់ទេ ខ្ញុំជាក្រោម ជាយុទ្ធជននៅក្រោមការដឹកនាំរបស់គេខាងលើហ្នឹងទៀតបាទ មានមេក្រុម មានអនុសេនាតូច មានអនុសេនាធំ និងរួមទាំងខ្ញុំដែរ។

**ស៖** ហើយនៅក្នុងកងកាំភ្លើងធំហ្នឹងឬ លោកនៅក្នុងកងនេះរហូតដល់ពេលរំដោះទីក្រុងភ្នំពេញ ១៧ មេសា ១៩៧៥ ឬយ៉ាងណា?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំនៅត្រឹមតែកងកាំភ្លើងធំនេះ រហូតដល់ឆ្នាំ៧៥ រំដោះហើយ បានទៅនៅកំពង់សោមតែម្ដង។

[០៩:២៤:២០]

**ស៖** នៅក្នុងបណ្ដាឆ្នាំមុនៗ ដែលលោកនៅក្នុងកងកាំភ្លើងធំ រហូតដល់ឆ្នាំ១៩៧៥ គឺថាលោកមិនមានសិទ្ធិអំណាចក្នុងការបញ្ជាទៅកងទ័ពអ្នកណាម្នាក់ទេ គឺថាលោកគ្រាន់តែជាយុទ្ធជនចាំតែទទួល

បញ្ហាពីគេតែប៉ុណ្ណោះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អរគុណណាស់។

**ស៖** ហើយបើខ្ញុំយល់មិនច្រឡំទេ ក្រោយខែមេសា ១៩៧៥ គឺថាលោកមានតួនាទីជាយុទ្ធជនសុទ្ធសាធ ហើយលោកមិនមានសិទ្ធិអំណាចបញ្ជាទៅយុទ្ធជនដទៃណាទៀតទេ។ អ៊ីចឹងឬយ៉ាងណា?

**ឆ៖** បាទ អរគុណណាស់។

**ស៖** លោកទើបតែលើកឡើងអម្បាញ់មិញនេះអំពីប្រភេទកាំភ្លើងធំ ដែលលោកនិងយុទ្ធជនរួមអាវុធរបស់លោកបានប្រើប្រាស់នោះ។ តើលោកមានប្រើកាំភ្លើងធំ១២,៧ -- លោកៗយល់ទេ? លោកធ្លាប់ឮប្រភេទកាំភ្លើងនេះទេ ពេលខ្ញុំនិយាយថា កាំភ្លើងធំប្រភេទ១២,៧ នេះ?

**ឆ៖** បាទ ឮកាំភ្លើងធំ១២,៧ហ្នឹង ឮហើយ។ ហើយមានកាំភ្លើងហ្នឹងវាច្រើនតែនៅលើកប៉ាល់ទេកាំភ្លើងហ្នឹងបាទ មិនមានយកមកបាញ់នៅលើគោកទេ។ អានេះបើៗនិយាយទៅ កាំភ្លើងយន្តដែលនៅតាមថ្មើរជើងដែលបាញ់នៅលើគោក ភាគច្រើនតែកាំភ្លើង ខូសេត, ខូវីត និងកាំភ្លើងមីគីយើ ហើយនិងកាំភ្លើងដែលបង់ត្រឡោកអីហ្នឹងជាការធម្មតាទេ។ អ្វីដែលកាំភ្លើង១២,៧ហ្នឹង អាហ្នឹងមាននៅលើកប៉ាល់អាហ្នឹងមាន។ បាទ អរគុណ។

[០៩:២៦:៥៣]

**ស៖** តើលោកផ្ទាល់ធ្លាប់ដែលប្រើប្រាស់កាំភ្លើងខូសេតដែរទេ? តើលោកគឺជាអ្នកជំនាញបាញ់កាំភ្លើង១២,៧ –ខូសេត– នេះឬក៏អ្នកដទៃទេដែលបាញ់កាំភ្លើងនេះ?

**ឆ៖** បាទ អរគុណណាស់។ កាលខ្ញុំនៅកងកាំភ្លើងធំហ្នឹងគឺធ្លាប់បាញ់។ កាំភ្លើងខូសេត និងកាំភ្លើងខូវីតរបស់ចិន និងកាំភ្លើងខូសេតរបស់អាមេរិកាំង ហ្នឹងធ្លាប់។ បាទ ធ្លាប់ប្រើប្រាស់ដែរ ព្រោះខ្ញុំនៅកងកាំភ្លើងធំពួកចល័ត កាលហ្នឹងខ្ញុំនៅកងកាំភ្លើងធំមែន ប៉ុន្តែចល័ត កាំភ្លើងម៉ាស៊ីនហ្នឹងក៏ចល័តដែរ។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរអំពីកាំភ្លើងខូសេតនេះខាងក្រោយមកទៀត។ តែខ្ញុំសួរថាអ៊ីចេះទេ សួរថាខ្លួនលោកផ្ទាល់នេះធ្លាប់ដែលបាញ់កាំភ្លើងខូសេតនេះទេ?

**ឆ៖** បាទ អរគុណណាស់។ កាំភ្លើងខូសេតនេះ ខ្ញុំធ្លាប់បាញ់ៗ។

**ស៖** អូខេ លោកសាក្សី ខ្ញុំនឹងមកសួរលោកអំពីបញ្ហាកាំភ្លើងខូសេតនេះពេលក្រោយ។ នៅថ្ងៃ ១៧ មេសា ១៩៧៥ នៅពេលដែលទីក្រុងភ្នំពេញដួលរលំ តើលោកស្ថិតនៅក្នុងទឹកដីភូមិភាគនិរតីនៅក្នុងខេត្តកំពតឬ?

ឆ៖ ឆ្នាំ៧៥ហ្នឹងគឺកាំភ្លើងធំ គឺដកអស់ហើយ រៀបចំជាអង្គភាពថ្មីដើម្បីការនៅជើងទឹកវិញទេ។

ស៖ សំណួររបស់ខ្ញុំ អ៊ីចេះលោក នៅថ្ងៃ១៧ មេសា ១៩៧៥ និងមួយសប្តាហ៍ក្រោយថ្ងៃ១៧ មេសា ១៩៧៥។ តើលោកស្ថិតនៅឯណា?

ឆ៖ បាទ ឆ្នាំ៧៥ ខ្ញុំចូលទៅនៅខាងកំពង់សោមហើយបាទ នៅកំពង់សោមតែម្តង ឡើងទៅកំពង់សោម។

ស៖ លោកបានទៅដល់កំពង់សោមនៅថ្ងៃខែឆ្នាំណាដែរ?

[០៩:៣០:០៥]

ឆ៖ បាទ ខ្ញុំភ្លេចដែរហើយ ព្រោះពេលរំដោះឆ្នាំ៧៥ហ្នឹង រំដោះហ្នឹងរយៈបានជាបីថ្ងៃទេខ្ញុំទៅដល់កំពង់សោមបាទ។ ហើយភ្លេចពេលវេលាខែហ្នឹងហើយ។ បាទ សូមអរគុណ។

ស៖ ហើយនៅពេលនុ៎ងនោះ ពេលទៅដល់កំពង់សោមហ្នឹង លោកនៅតែស្ថិតនៅក្នុងកងកាំភ្លើងធំដដែល ឬក៏យ៉ាងណា?

ឆ៖ បាទ អរគុណណាស់។ កាលខ្ញុំចូលទៅដល់នៅកំពង់សោម គឺរំលាយកងកាំភ្លើងធំនៅថ្មើរជើងវិញហើយ បាទ នៅថ្មើរជើងជាការធម្មតា ចែកទៅតាមអង្គភាព។

ស៖ ឥឡូវនិយាយថា អ៊ីចេះទៅចុះ ថាបួនសប្តាហ៍ បួនអាទិត្យក្រោយថ្ងៃរំដោះ តើលោកមានបានទៅកាន់កោះមួយ ដែលជាកោះរបស់ប្រទេសកម្ពុជាដែរឬទេនៅពេលនោះ?

ឆ៖ ឆ្នាំ៧៥ បានអង្គការបានបញ្ជូនខ្ញុំឱ្យទៅនៅកោះ បាទនៅកោះមួយ ជាកោះ ហៅថាកោះៗ កោះតាង បាទ កោះតាង។ ហ្នឹង ៧៥ ហ្នឹងទៅនៅកោះតាងតែម្តង។

ស៖ តើលោកបានទៅនៅកោះតាងហ្នឹង ពិតប្រាកដទៅនៅពេលណាដែរ?

ឆ៖ ខ្ញុំអត់បានចាំដែរព្រោះ ការភ្លេចភ្លាំងហើយ ព្រោះយូរពេកទៅហើយ អ៊ីចឹងអត់ចាំនូវថ្ងៃខែហ្នឹងដែរ។ បាទ អរគុណណាស់ សូមបន្ត។

ស៖ តើលោកបានទៅដល់ទីនោះ គឺក្នុងរយៈពេលពីរបីអាទិត្យ ក្រោយពេលរំដោះទីក្រុងភ្នំពេញត្រឹមត្រូវដែរទេ?

ឆ៖ បាទ ត្រឹមត្រូវហើយលោក អរគុណ។

ស៖ តើលោកនៅចាំបានទេថានៅក្នុងថ្ងៃ០៧ ខែឧសភា ឆ្នាំ១៩៧៥ មានអ្វីកើតឡើងនៅកោះតាងនោះ? មានព្រឹត្តិការណ៍អ្វីកើតឡើងនៅកោះតាង?

**ឆ៖** បាទ អរគុណណាស់ ខ្ញុំសូមជម្រាបដោយការស្មោះត្រង់ ដោយមានព្រឹត្តិការណ៍កើតឡើងនៅឆ្នាំ៧៥ ដោយមានចាប់កប៉ាល់ម៉ាយ៉ាហ្គេសមួយគ្រឿង បាទ យកមកចតនៅកោះតាងនោះគឺថា ព្រឹត្តិ-ការណ៍ដែលកើតឡើងមានវាយគ្នាយ៉ាងខ្លាំង នៅឆ្នាំ៧៥ហ្នឹង បាទ។

**ស៖** តើមានអ្វីកើតឡើងឲ្យពិតប្រាកដទៅនឹងកប៉ាល់ម៉ាយ៉ាហ្គេសនេះ ថាតើកប៉ាល់ម៉ាយ៉ាហ្គេសនេះជាកប៉ាល់របស់ពីខាងណាមកដែរ ហើយគេចាប់កប៉ាល់ម៉ៃយ៉ាហ្គេសហ្នឹងចាប់នៅពេលណា? សូមលោកជម្រាបតុលាការឲ្យបានលម្អិតបន្តិចបានទេ។

**ឆ៖** បាទ អរគុណណាស់ ខ្ញុំអត់នៅចងចាំទេ ព្រោះថ្ងៃខែឆ្នាំ -- ថ្ងៃខែហ្នឹង ខ្ញុំអត់បានចាំទេ។ អត់បានចាំដឹងថា ចាប់ម៉ាយ៉ាហ្គេសជាកប៉ាល់របស់អាមេរិកាំងបាទ ជនជាតិអាមេរិកាំងទាំងអស់។ បាទ អាហ្នឹងឃើញផ្ទាល់នឹងភ្នែក ហើយក៏បានឡើងទៅលើកប៉ាល់ដែលម៉ាយ៉ាហ្គេសនោះ ដែលចាប់មកពីផ្លូវអន្តរជាតិតែម្តង។

**ស៖** ដូច្នេះ នៅពេលដែលលោកនៅកោះតាងកាលនោះ កប៉ាល់ម៉ាយ៉ាហ្គេសនោះ ក៏ត្រូវបានបញ្ឈប់ ហើយមនុស្សនៅលើកប៉ាល់នោះត្រូវបានចាប់ខ្លួន។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដណាស់ ដែលពេលចាប់បានយកមកហ្នឹង គឺថាអ្នកនៅលើកប៉ាល់ហ្នឹង ក៏គេដកចេញពីលើកប៉ាល់ហ្នឹងយកទៅកំពង់សោមតែម្តង ហើយក៏បានដក បានគេបញ្ជូនឲ្យមកវិញ។ បាទ មុននឹងបញ្ជូនមកក៏ធ្វើសកម្មភាពប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅលើកោះនោះដែរ។ បាទ អរគុណ។

[០៩:៣៥:១២]

**ស៖** អ៊ីចឹងការវាយប្រយុទ្ធគ្នារវាងទ័ពខាងណានិងខាងណាដែរ?

**ឆ៖** ការប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅលើកោះនោះគឺជាមួយទ័ពអាមេរិកាំងតែម្តង។ ប្រយុទ្ធគ្នាដោយថ្មើរជើង ប្រយុទ្ធគ្នាទាំងជើងទឹក។ ពេលយន្តហោះដាក់ទ័ត – ដាក់ទ័ពបានចំនួនជាពីរគ្រឿងប៉ុណ្ណោះទេ តែប្រយុទ្ធគ្នាក៏កាន់ខ្លាំង ហើយអាមេរិកាំងក៏បានឡើងយន្តហោះឡើងវិញទាំងអស់។ ក្រោយមកទៀតបានប្រយុទ្ធគ្នានៅខាងលើអាកាស។ លើអាកាសនិងលើនាវាចម្បាំង ដែលរបស់អាមេរិកាំងតែម្តង។ ហ្នឹងមានការប្រយុទ្ធគ្នានៅលើកោះនោះ។

**ស៖** តើលោកនៅចាំដែរឬទេថាតើក្រុមណា ផ្នែកណានៃកងកម្លាំងបដិវត្តន៍កម្ពុជា ដែលជាអ្នកចាប់កប៉ាល់នោះ? តើក្រុម ឬក៏កងណាដែលចាប់បានកប៉ាល់ម៉ាយ៉ាហ្គេសនោះ?

**ឆ៖** អរគុណណាស់។ ខ្ញុំជម្រាបដោយការស្មោះត្រង់ និងដល់តុលាការ ព្រោះកាលក្នុងឆ្នាំ៧៥

**E1/370.1/Old-1**

នោះ នៅថ្មើរជើងនៅតាមកោះ គឺថាគ្មានកប៉ាល់ទេ អត់មានកប៉ាល់ទេ។ អ៊ីចឹងថ្មើរជើងអត់មានទេ មានតែកប៉ាល់មកពីដីគោក ហើយបញ្ជា បាទបញ្ជាពីដីគោក ដើម្បីកប៉ាល់នោះមកដេញចាប់គេតែម្ដង។ សូមអរគុណ។

[០៩:៣៧:១៤]

**ស៖** តើលោកចាំដែរឬទេ ថាក្រុមណាដែលជាអ្នកចាប់បានកប៉ាល់ម៉ាយ៉ាហ្គេស? ខ្ញុំសួរពីក្រុមកងទ័ព? ក្រុមដែលចាប់កប៉ាល់ម៉ាយ៉ាហ្គេសហ្នឹង ក្រុមអ្វី? កងវរៈអ្វី? នៅក្រោមការបញ្ជារបស់អ្នកណាជាដើម?

**ឆ៖** បាទអរគុណណាស់។ ខ្ញុំអត់ដឹងក្រុមដែរ អត់ៗដឹងក្រុមដែរ ប៉ុន្តែបញ្ជាពីកងពលទៅចាប់។ ហើយអ្នកនៅលើកោះនោះឃើញកប៉ាល់ៗហ្នឹងក៏រាយការណ៍ទៅថ្នាក់លើ។ ថ្នាក់លើក៏ឲ្យនាវាប្រដេញពីគ្រឿង តែមិនដឹងកងណា ឬអ្នកណាទេ ព្រោះកប៉ាល់ក្នុងនោះនៅក្នុងក្របខ័ណ្ឌកងពលគ្រប់គ្រងទាំងអស់បាទ គ្រប់គ្រងទាំងអស់។ កប៉ាល់នោះ គឺជាកប៉ាល់ដែលនៅសេសសល់ពីអាមេរិកាំងដែលយើងរើរំដោះបាន។ អ៊ីចឹងកប៉ាល់នោះនៅក្រោមការដឹកនាំនៅក្នុងក្របខ័ណ្ឌកងពល ហើយបញ្ជាពីកងពលមក ហើយក្នុងក្រុមក៏អត់បានស្គាល់ អត់បានដឹងដែរ មិនដឹងជាក្រុមណា ប៉ុន្តែដឹងតែគេបញ្ជាពីកងពលមកហើយបានគេទៅចាប់។ បាទ អរគុណ។

**ស៖** លោកនិយាយអំពីថា "យើង" តើក្រុមមួយទៀតដែលចាប់កប៉ាល់ៗអាមេរិកាំង។ តើក្រុមហ្នឹងគឺដែលថាក្រុម ប៉េ.សេ.អេហ្វហ្នឹង ឬក៏ក្រុមអ្វី ដែលទៅចាប់នោះ?

**ឆ៖** បាទអរគុណណាស់។ មិនមែនយក ប៉េ.សេ.អេហ្វ ទៅចាប់ទេ។ កាលនុំងកប៉ាល់ ប៉េ.សេ.អេហ្វ យឺត។ ក្នុងនោះមានកប៉ាល់នាវាលឿន។ នាវាលឿននោះគឺនាវាផ្ដាច់មីន។ នាវានោះលឿនខ្លាំងណាស់ សូម្បីតែយើងជិះឈរក៏ដាច់ដែរ ឡេវអារ។ អ៊ីចឹងនាវាហ្នឹងមានតែពីរគ្រឿងទេ យកទៅចាប់។ សូមអរគុណ។

[០៩:៣៩:៤១]

**ស៖** នៅក្នុងចម្លើយរបស់លោកដែលឆ្លើយទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត E3/9092, អង់គ្លេស ERN 00978569, ខ្មែរ 00955477, អត់មានភាសាបារាំងទេ។ ដែលនិយាយថា ក្រុម ប៉េ.សេ.អេហ្វ ជាអ្នកចាប់កប៉ាល់ម៉ាយ៉ាហ្គេស។ នៅពេលនោះ គេមិនបានប្រើកប៉ាល់តូចទេ ពីព្រោះកងនាវមិនទាន់មានកប៉ាល់តូចនៅឡើយទេ។ អ៊ីចឹងចម្លើយដែលលោកកាលនោះ

ត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អរគុណណាស់ ហើយកាលខ្ញុំនិយាយកាលនុ៎ង ខ្ញុំបាទភ្លេចភ្លាំងៗ។ ខ្ញុំប្រាប់ បាទ ខ្ញុំប្រាប់ត្រង់ហើយ បាទជម្រាបត្រង់ កុំនិយាយអ៊ីចេះហើយ មកនិយាយអ៊ីចុះ។ ប៉េ.សេ.អេហ្វ គឺមានទាំងអស់វាមានប្រាំមួយគ្រឿង ប៉ុន្តែប៉េ.សេ.អេហ្វវាល្បឿនវាឃើត បាទ ហើយអ៊ីចឹងខ្ញុំភ្លេចរឿងប៉េ.សេ.អេហ្វនុ៎ង បាទ ប៉េ.សេ.អេហ្វ ហើយអត់ទេ ថ្ងៃនុ៎ងគឺថាយក ប៉េ.សេ.អេហ្វមែន ប៉ុន្តែប៉េ.សេ.អេហ្វនុ៎ងដេញមិនទាន់ អ៊ីចឹងគេយកនាវាលឿននោះមក។ បាទ សូមអរគុណណាស់ ព្រោះខ្ញុំអង្កាល់នោះ ខ្ញុំវានៅភ្លេចភ្លាំងដែរ ហើយម្យ៉ាងទៀតវាយូរឆ្នាំពេកទៅ តែឥឡូវខ្ញុំនឹកឃើញដែលការចងចាំរបស់ខ្ញុំ។ បាទ ឥឡូវខ្ញុំនឹកឃើញ។ បាទ សូមអរគុណណាស់ សូមអភ័យទោស។

[០៩:៤១:២២]

**ស៖** ប៉ុន្តែនៅពេលដែលលោកប្រើពាក្យថា “យើង” តើលោកមិននិយាយថា ជាក្រុមរបស់លោកផ្ទាល់ទេ? លោកចង់និយាយថា កងពលដែលជាកងពលបញ្ជាលើរូបលោក។ ហើយនៅពេលដែលលោកប្រើពាក្យថា “យើង” វាមិនមែនមានន័យថា ក្រុម ឬក៏កងរបស់លោកតែមួយទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ទេ មិនមែនទេ។ ខ្ញុំចាប់ចំណុចនេះអត់ទាន់ដែរ។

**ស៖** មិនបញ្ហាទេ។ ជួនកាលយើងមានបញ្ហាភាសាបកប្រែ។ លោកសាក្សី លោកបាននិយាយថា “យើង” យើងចាប់កប៉ាល់ម៉ាយ៉ាហ្គេស ប៉ុន្តែលោកប្រើពាក្យថា “យើង” វាមិនមែនមានន័យថា ជាកងកាំភ្លើងធំរបស់លោកទេ គឺជាសមាជិកផ្សេងទៀតនៃកងទ័ពបដិវត្តន៍នៃភូមិភាគនិរតី តើអ៊ីចឹងដែរឬទេដែលលោកប្រើពាក្យថា “យើង”រួមនោះ?

**ឆ៖** បាទ មិនមែនទេ បាទ។ ព្រោះមិនតែភូមិភាគនិរតី និយាយរឿងយើង រឿងអីហ្នឹង ខ្ញុំដូចមិនចាប់អារម្មណ៍អី ព្រោះខ្ញុំអត់បានដឹងដែរ ព្រោះនិយាយភាសាយើងៗ គេ -- ចំណុចនេះមួយគឺដូចយើងវាក់អត់ដឹងដែរហ្នឹង។ បាទ អរគុណណាស់ សូមអភ័យទោស។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម -- លោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងគឺថាយើងសូមឲ្យលោកបើកសំណួរនេះ។ ថាតើសួរថា បើលោកនិយាយពាក្យថា “យើង”

តើលោកសំដៅទៅអ្នកណាខ្លះ?

**2-TCW-1000៖**

បាទ ខ្ញុំសូមអរគុណណាស់ ជាពាក្យនិយាយថា "យើងៗ" នេះ មិនមែនថា សំដៅទៅបុគ្គលណា ឬទៅអង្គភាពណាមួយទេ។ និយាយរួមថាពាក្យ "យើង" ជារួម។ យើងទាំងអស់គ្នាអ៊ីចឹងទៅបាទ។ ជាអ្នកធ្វើសកម្មភាព មិនមែននិយាយអ៊ីចឹងទេ។ ព្រោះអ្វីមួយដល់ការអនុញ្ញាត ដល់ការបញ្ជា ឬមួយបានធ្វើ បើជាអង្គភាពណាមួយ បញ្ជាទៅអង្គភាពណាមួយ ទៅកងណាមួយ អាហ្នឹងបានកងនោះធ្វើ។ អានេះ ពាក្យ "យើងៗ" នេះ គឺយើងជារួម។ បាទ មិនមែនថា និយាយទៅសង្កត់តែទៅអង្គភាពណា គឺទៅវរសេនាធំណា វរសេនាតូចណា គឺអត់ទេ។ បាទ ពាក្យ "យើង" នេះ ខ្ញុំអត់សូវយល់ន័យដែរហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនទាន់យល់ទេថា ដែលពាក្យថា "យើង" នៅឡើយទេ។ នៅពេលដែលលោកនិយាយថា "យើង" ទទួលបញ្ជា។ តើ "យើង" ហ្នឹងលោកសំដៅអ្នកណាខ្លះ?

[០៩:៤៤:៣០]

**2-TCW-1000៖**

បាទ អរគុណណាស់។ ខ្ញុំ -- ជាខ្ញុំទាំងអស់គ្នាដែលអ្នកក្រោមការដឹកនាំរបស់សម័យរណសិរ្សកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាមិនមែន ហៅថានិយាយ "យើង" ឬមួយហៅថា អ្នកណាមួយបញ្ជាមកបានធ្វើទេ។ ទាល់តែបញ្ជាទៅតាមវរសេនាតូច ដូចជាវរសេនាតូចខ្ញុំប្រមាណ ថាប្អូនដប់ ឬមួយប្អូនម្ភៃអ៊ីចឹងទៅ បាទ។ បញ្ជាមកឱ្យចំឈ្មោះ អាហ្នឹងបានៗគេធ្វើ ហើយបើថា បើមិនបញ្ជាមកឱ្យចំឈ្មោះ ឬមួយចំអង្គភាពទេ គឺថាមិនបានធ្វើទេ ហើយក៏មិនបានអង្គភាពណាម្ចាស់ការដោយខ្លួនឯងបានដែរ ពេលបច្ចុប្បន្ននោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំអានសេចក្ដីដកស្រង់តូចមួយ អំពីចម្លើយរបស់លោកដែលៗមិនឆ្លើយទៅសហចៅក្រមស៊ើបអង្កេតទេ ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/9092, ERN ដដែល ខ្ញុំនឹងអានសេចក្ដីដកស្រង់ទាំងមូល៖ "តើលោកស្ថិតនៅការបណ្ដុះបណ្ដាលទេ នៅពេលដែលខ្មែរក្រហមចាប់បានកប៉ាល់ម៉ាយ៉ាហ្គេស? លោកបានឆ្លើយថា៖ វាកើតឡើងមុនៗពេលដែលខ្ញុំរៀនបច្ចេកទេស បន្ទាប់ពីកាលភ្នំពេញដួលរលំ គេបានបញ្ជូនខ្ញុំឱ្យទៅចូលកងនាវា ហើយមួយសប្ដាហ៍ក្រោយមក គេបានចាប់បានកប៉ាល់ម៉ាយ៉ា-

ហ្គេស។ សំណួរ៖ ហេតុអ្វីបានគេចាប់កប៉ាល់ម៉ាយ៉ាហ្គេសនោះ? កាលនោះលោកឆ្លើយថា៖ ខ្ញុំមិនបានដឹងទេ ប៉ុន្តែយើងដូចជាក្រុមទ័ពព្រៃអ៊ីចឹង ពីព្រោះយើងចាប់កប៉ាល់នោះ ដោយខុសច្បាប់។ សំណួរ៖ តើលោកបានចាប់ដោយខុសច្បាប់ឬ? ចម្លើយ៖ យើងបានចាប់ដោយខុសច្បាប់ ពីព្រោះកប៉ាល់នោះធ្វើដំណើរ១០គីឡូម៉ែត្រក្រៅឆ្នេរសមុទ្រកោះពូលូវ៉ៃ។ តើក្រុមណាដែលជាអ្នកទៅចាប់កប៉ាល់ម៉ាយ៉ាហ្គេសនោះ? ពេលនោះលោកឆ្លើយថា៖ ក្រុមប៉េ.សេ.អេហ្វ ជាអ្នកចាប់កប៉ាល់នោះ។ នៅពេលនោះ គេមិនប្រើកប៉ាល់តូចទេ ពីព្រោះកងនាវាមិនទាន់មានកប៉ាល់តូចៗនៅឡើយទេ។ សំណួរ៖ តើលោកបានចូលរួមដើម្បីចាប់កប៉ាល់នោះដែរឬទេ? ចម្លើយ៖ ទេ ខ្ញុំមិនបានចូលរួមទេ ពីព្រោះខ្ញុំនៅកោះតាង។ តើមានរឿងអ្វីកើតឡើងបន្ទាប់ពីនោះ? លោកឆ្លើយថា៖ បន្ទាប់ពីគេបានចាប់ គេបានចាត់តាំងក្រុមខ្ញុំឲ្យឡើងទៅកប៉ាល់នោះដើម្បីយាម។ បន្ទាប់មក គឺមានកប៉ាល់ហោះ និងយន្តប្រតិកម្មក៏បានមកទម្លាក់ ហើយបន្ទាប់មក ខ្ញុំបានរត់គេចពីនោះ ពីការប្រយុទ្ធនោះ។”

អ៊ីចឹងលោកសាក្សី លោកបានយោងទៅរកក្រុមមួយចំនួនខុសៗគ្នា ជួនកាលលោកនិយាយពីក្រុមរបស់លោក ហើយជួនកាលលោកបាននិយាយសំដៅទៅក្រុមផ្សេងទៀត។ អ្វីដែលខ្ញុំអានប្រាប់លោកនេះ ដែលនៅពេលដែលលោកនិយាយប្រាប់ទៅអ្នកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានចាំថាលោកបាននិយាយបែបនេះដែរឬទេ?

[០៩:៤៨:២៧]

**លោក 2-TCW-1000៖**

**ឆ៖** បាទ ពិតប្រាកដណាស់ ខ្ញុំបាននិយាយ បាទនិយាយពិតប្រាកដ អត់មានលាក់លៀមអីទេ ដោយសម្តែងនូវការស្មោះត្រង់ ដោយជូនអង្គ ជូនទាំងអស់ បាទ ពិតប្រាកដ។

**ស៖** ដូច្នេះគឺជាក្រុមរបស់លោកដែលគេឲ្យភារកិច្ចទៅយាមលើកប៉ាល់នោះនៅឯកោះតាង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដណាស់ គេឲ្យក្រុមខ្ញុំទៅយាមនៅលើកប៉ាល់ ហើយចាប់អ្នកនៅលើកប៉ាល់នោះ ដាក់នៅលើទូក ដើម្បីបញ្ជូនទៅកំពង់សោមតែម្តង។ នេះជាពិតប្រាកដមែន បាទ ខ្ញុំនិយាយ ហើយខ្ញុំភ្លេចខ្លះអីខ្លះអ៊ីចឹង ខ្ញុំនិយាយទៅមានការកាត់ខ្លះអីខ្លះហើយ។ បាទ អរគុណណាស់។

**ស៖** ដូច្នេះក្រុមកងនាវិកនៅលើៗកប៉ាល់នោះក៏ត្រូវបានគេបញ្ជូនទៅកំពង់សោម ហើយអង្គភាពរបស់លោក មានភារកិច្ចជាអ្នកយាមកប៉ាល់នោះ។ សូមលោកពន្យល់តុលាការមើល៍ ថាមានរឿងអ្វីកើត

ឡើងបន្ទាប់ពីនោះមក?

[០៩:៤៩:៥៥]

**ឆៈ** បាទ អរគុណណាស់។ នៅពេលហ្នឹងក៏ចាប់អ្នកនៅលើកប៉ាល់ម៉ាយ៉ាហ្គេសនោះ បញ្ជូនទៅកំពង់សោម។ រយៈពេលយប់ប្រហែលជាម៉ោងដប់យប់បានពួកយើងខ្ញុំដែលនៅលើនាវានោះ នៅលើកប៉ាល់ម៉ាយ៉ាហ្គេសនោះក៏គេដកមកនៅលើកោះវិញដើម្បីរៀបចំដឹងថាសភាពការណ៍មិនស្រួលហើយ អ៊ីចឹងគេក៏ឲ្យរៀបចំនៃការប្រយុទ្ធ ព្រោះសភាពការណ៍អាមេរិកាំងមានការវាយតប់មកលើយើងហើយ ព្រោះនាវា យន្តហោះក៏ធ្វើសកម្មភាពមកច្រើនឡើងៗក្នុងពេលនោះ ប៉ុន្តែមិនទាន់ទម្លាក់គ្រាប់បែកទេ គ្រាន់តែមកឆ្វែលមើលកប៉ាល់របស់វា ក្នុងពេលយកអាមេរិកាំងទៅដីគោក ហើយខ្ញុំក៏ដកមកនៅលើឈរនៅលើកោះត្រៀមប្រយុទ្ធវិញ។

**សៈ** ដូច្នេះ លោកៗបានប្រចាំការនៅកោះតាងនៅពេលដែលយន្តហោះ ឬក៏ឧទ្ធម្ភាគចក្ររបស់អាមេរិកាំងក៏មកធ្វើការវាយប្រហារ កាលនោះលោកនៅកោះតាង អ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ ត្រឹមត្រូវពិតប្រាកដមែន។

**សៈ** តើលោកចាំដែរឬទេថាមានហេតុការណ៍អ្វីកើតឡើងនៅពេលដែលឧទ្ធម្ភាគចក្ររបស់អាមេរិកាំងហោះបានសំដៅមកកោះតាង តើមានហេតុការណ៍អីពេលដែលយន្តហោះហ្នឹងសំដៅមកនោះ?

**ឆៈ** នៅពេលព្រឹកឡើង យន្តហោះក៏បានធ្វើសកម្មភាពចុះ ដាក់ទ័ព។ នេះមានការប្រយុទ្ធគ្នាហើយ។ ពេលប្រយុទ្ធហើយ យន្តហោះដែលឡើងខ្លះក៏ឡើងទាន់ ខ្លះក៏ឡើងមិនទាន់ក៏មានការបាញ់ បាទ បាញ់ទម្លាក់យន្តហោះឡើងចុះបានតែពីរគ្រឿង បីគ្រឿងតែប៉ុណ្ណោះទេ ប៉ុន្តែហើយវាឡើងទៅវិញ ដល់ឡើងទៅវិញហើយពេលនោះទៀតក៏វាឆាបរកមកចុះទៀត គឺបាញ់ធ្លាក់បាទ បាញ់ធ្លាក់យន្តហោះពីរគ្រឿងទៀត បាទបានធ្លាក់នៅលើផ្ទៃសមុទ្រ ហើយនិងនៅលើកោះ នៅលើឆ្នេរសមុទ្រហ្នឹងមួយគ្រឿងពិតប្រាកដ ដែលក្នុងការធ្វើនូវសកម្មភាពនៅពេលនោះ។ ក្រោយមកទៀត ក៏យន្តហោះក៏ធ្វើសកម្មភាពយ៉ាងខ្លាំងនៅលើកោះ ទម្លាក់គ្រាប់បែកៗខ្លាំង ហើយក្រោយមកទៀតក៏កប៉ាល់ បាទកប៉ាល់ខាងជើងទឹកបាញ់ៗខ្លាំងមកលើកោះ មកលើយោធាខ្មែរក្រហមហ្នឹង ហើយក៏យោធាក៏មានការប្រយុទ្ធគ្នាយ៉ាងខ្លាំងធ្ងន់ធ្ងរជាទីបំផុតឡើងមួយថ្ងៃទើសដល់ទាល់យប់តែម្តង ទើសដល់ម៉ោងប្រាំពីរយប់។

**សៈ** ហើយតើអ្នកណាជាអ្នកបាញ់ៗធ្លាក់នូវឧទ្ធម្ភាគចក្រសហរដ្ឋអាមេរិកពីរគ្រឿងហ្នឹង ក្រុមខាងណាជាអ្នកបាញ់បាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[០៩:៥៣:៥៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជន ព្រមទាំងដើមបណ្ដឹងរដ្ឋប្បវេណី។ យើងខ្ញុំសង្កេតឃើញថាលោកមេធាវី កូប៉េ បានឆ្លើយ -- បានសួរសំណួរច្រើនពាក់ព័ន្ធទៅនឹងបញ្ហាកប៉ាល់អាមេរិកាំងនេះ ហើយយើងខ្ញុំមានការមិនច្បាស់លាស់ ថាតើបញ្ហានេះវាពាក់ព័ន្ធទៅនឹងវិសាលភាពនៃសវនាការដែរឬទេ។ ដូច្នេះ សូមលោកប្រធានមេត្តាឲ្យខាងមេធាវីលោក នួន ជា មេត្តាបំភ្លឺ ថាតើបញ្ហានេះវាពាក់ព័ន្ធទៅនឹងវិសាលភាពនេះសំណុំរឿងយើងនៅកន្លែងណា។

សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីឆ្លើយតបលោកប្រធាន។ បើនិយាយពីពេលវេលាគឺថា គឺស្ថិតនៅក្នុងវិសាលភាព ហើយសំណួររបស់ខ្ញុំគឺនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៥។ មូលហេតុដែលខ្ញុំផ្តោតលើហេតុការណ៍មួយនេះ គឺមានផលប្រយោជន៍ជាទូទៅម្យ៉ាង។ ប៉ុន្តែខ្ញុំព្យាយាមផ្តល់ភស្តុតាង បង្ហាញភស្តុតាង តើគាត់មានតួនាទីតំណែងជាអ្វីសាក្សីហ្នឹង នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ហើយខ្ញុំព្យាយាមដើម្បីពិនិត្យឲ្យឃើញថា តើចម្លើយពីមុនរបស់គាត់ទៅ ឌី.ស៊ី.ខេម គឺមានព័ត៌មានស៊ីចង្វាក់ដែរឬទេ? ហើយដោយប្រាកដនោះ ខ្ញុំព្យាយាមបង្ហាញភស្តុតាង។ កាលណាគាត់និយាយអំពី *"វី"* ហ្នឹងគឺថាគាត់សំដៅក្រុមណាខ្លះ ឬក៏មានថាកងទ័ពបដិវត្តន៍កម្ពុជា ឬក៏តែកងរបស់គាត់ទេ។ នេះហើយដែលខ្ញុំផ្តោតអារម្មណ៍ទៅបញ្ហាមួយទៀតដែលទាក់ទងទៅនឹង ទៅតាមការលំដាប់លំដោយ ដែលស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះឯង លោកប្រធាន បាទ។

[០៩:៥៦:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៨:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី មុននឹងធ្វើសេចក្តីសម្រេច តើជាមូលហេតុតែមួយគត់ ដើម្បីពិនិត្យភាពជឿជាក់

បានរបស់សាក្សីហ្នឹងដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

មូលហេតុពិតប្រាកដ លោកស្រីចៅក្រម បាទ ខ្ញុំរីករាយនឹងឆ្លើយតបលោកស្រីចៅក្រម។ ខ្ញុំសូមដកស្រង់នូវសេចក្តីដកអំពីសៀវភៅរបស់ អេលីហ្សាបេត បេកឃ័រ គឺជា -- លោកប្រធាន E3/20 ឯកសារនេះ។ នៅអង់គ្លេស ERN 00237902, បារាំង 00638463, ខ្មែរ 00232262។ នាងបានរៀបរាប់នៅក្នុងសៀវភៅរបស់នាងថា ជាព័ត៌មានខ្សែកាបមកសហរដ្ឋអាមេរិក -- ទូតសហរដ្ឋអាមេរិកនៅបាងកក។ ខ្ញុំដកស្រង់សេចក្តីសម្រង់ទាំងមូលជូនលោកស្រីចៅក្រមជ្រាប ដើម្បីខ្ញុំនឹងបង្ហាញភស្តុតាង។ គាត់បានសរសេរដូចខាងក្រោមនេះ៖ “នៅពេលដែលបញ្ចប់នៃការវាយប្រយុទ្ធនោះ ហើយទ័ពអាមេរិកកាំង៣៨នាក់ស្លាប់ ដើម្បីសង្គ្រោះ៦នាក់ ហើយពីភាគច្រើនហ្នឹង ត្រូវបានស្លាប់ក្រោយពីសមាជិកនាវិកបានដោះលែង ហើយកងទ័ពនោះ គឺថាអាច នេះគឺជាការស្លាប់ចុងក្រោយនៅក្នុងសង្គ្រាមអាមេរិកាំង ហើយគេបានប្រកាសនូវជោគជ័យ។ ស្ថានទូតអាមេរិកនៅបាងកកបានឃើញវិបត្តិនោះ គឺថាជារូបភាពមួយផ្សេង។ សូមដកស្រង់៖ “ខ្មែរ មេបញ្ជាការខ្មែរនៅក្នុងស្រុក បានមានស្វ័យភាពទាំងស្រុង ហើយបានអនុវត្តអំណាចរបស់គេដោយសេរី គឺទាក់ទងទៅគួរឲ្យខ្មាសអៀន។” ហើយនៅក្នុងសារព័ត៌មានតាមខ្សែកាបនេះគឺថាអាចនិយាយអំពីហេតុការណ៍ អំពីកាប៉ាល់ម៉ាយ៉ាហ្គេស។ ហើយប្រសិនបើពិនិត្យមើលសំណួររបស់ខ្ញុំក្នុងបរិបទធំធេង ដើម្បីពិនិត្យមើលថាតើអ្វីបានកើតឡើងនៅក្នុងតំបន់កម្ពុជានៅក្នុងតំបន់កោះទាំងអស់នោះ ត្រូវបានធ្វើឡើង ជាពិសេសគឺក្នុងរបៀបជាស្វ័យប្រវត្តិរបស់កងទ័ពនៅទីនោះ។ អ្វីដែលខ្ញុំចង់បញ្ជាក់ហ្នឹងគឺថា អ្វីដែលសាក្សីបានដឹងនៅពេលនោះគឺថា តាំងពីមេបញ្ជាការរបស់គាត់ឡើងមកខ្ពស់នោះ គឺថារហូតទៅដល់កងកម្លាំងភូមិភាគនិរតីបានចាត់ការដោយឯករាជ្យ ដោយស្វ័យភាពរបស់គេ។ ហើយក៏តាមរយៈហេតុការណ៍ម៉ាយ៉ាហ្គេស – ហេតុការណ៍ម៉ាយ៉ាហ្គេសនេះ ខ្ញុំអាចនឹងបញ្ជាក់ពីហេតុការណ៍តាមលំដាប់លំដោយកាលវេលា ដើម្បីបញ្ជាក់ពីភាពជឿជាក់បាននៃសាក្សីរូបនេះ លោក លោកស្រីចៅក្រម បាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០២:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យសួរបាន ពាក់ព័ន្ធនឹងបញ្ហាដែលលោកមេធាវីកំពុងតែតាំងសំណួរ

ដេញដោលចំពោះសាក្សីនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ដូច្នេះខ្ញុំត្រឡប់ទៅសំណួរខាងដើមរបស់ខ្ញុំ។ សូមលោកជម្រាបជូនតុលាការឲ្យបានច្បាស់លាស់នៅពេលដែលឧទ្ធម្ភាគចក្រហ្នឹងមក ហើយតើអង្គភាពណាដែលជាអ្នកបាញ់ទម្លាក់ឧទ្ធម្ភាគចក្រនោះ កន្ទុំរុយនោះ?

**2-TCW-1000៖**

**ឆ៖** បាទអរគុណណាស់ ខ្ញុំសម្ដែងនៃការស្មោះត្រង់ទៅអង្គប្រជុំ។ ពេលប្រយុទ្ធគ្នាយ៉ាងខ្លាំងអង្គភាពរបស់ខ្ញុំនៅលើកោះហ្នឹង គឺវរសេនាតូចរបស់ខ្ញុំហ្នឹង មិនទាន់ផ្លាស់ប្ដូរនៃកងលេខ -- លេខកងទេ នៅកងវរសេនាតូចលេខ៤១០។ ហើយក្នុងនៅលើកោះនោះ មិនមែនទ័ពច្រើនទេ ប្រហែលជាមួយ១០០នាក់ បាទ ប្រហែលជា១០០នាក់។ ហើយនៃការប្រយុទ្ធៗគ្នាយ៉ាងខ្លាំង បាទប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅលើកោះនោះ ដោយកប៉ាល់ហោះ ដោយកាប៉ាល់ទឹក បាទ។ កាប៉ាល់ហោះ ឧទ្ធម្ភាគចក្រនោះ ខ្ញុំសម្ដែងនូវការពិតប្រាកដនៃខ្ញុំ បាទ ពិតប្រាកដណាស់ ខ្ញុំបាញ់ធ្លាក់ខ្លួនឯងដោយផ្ទាល់តែម្ដង។ ដោយសារអី? ដោយសារខ្ញុំរត់លែងរួចហើយ ខ្ញុំត្រូវរបួសយ៉ាងទម្ងន់។ ឯអឺចឹងកាំភ្លើងខ្វូសេតមួយដើម បាទ នៅតែម្នាក់ឯងទេកាលហ្នឹង គេរត់រប៉ាត់របាយអស់ហើយ។ អឺចឹងនៅតែខ្លួនខ្ញុំតែម្នាក់ឯងពិតប្រាកដ ខ្ញុំបាញ់ទម្លាក់យន្តហោះនោះ គឺដាច់គូថ ដាច់កន្ទុរក្រោយធ្លាក់ៗនៅពីមុខខ្ញុំតែម្ដង។ នេះខ្ញុំសម្ដែងនៃការស្មោះត្រង់ ជូនអង្គប្រជុំ។

**ស៖** លោកប្រើកាំភ្លើងធំ ១២,៧ –ខ្វូសេត– ហ្នឹងអី ដែលលោកបាញ់ទម្លាក់កាប៉ាល់ហោះហ្នឹង ព្រោះលោកបានឆ្លើយពីខាងដើមថា អាវុធខ្វូសេតនេះ គឺថាគេប្រើប្រាស់តែនៅលើកាប៉ាល់សម្រាប់បាញ់របស់ធំៗអឺចឹងហ្នឹង ដូចជាបាញ់ទម្លាក់យន្តហោះជាដើមអឺចឹង។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ពិតប្រាកដត្រឹមត្រូវមែន។

**ស៖** ឥឡូវនេះ ខ្ញុំព្យាយាមស្វែងយល់ថា អ្នកណាជាអ្នកបញ្ជាឲ្យលោកបាញ់ទម្លាក់ឧទ្ធម្ភាគចក្រហ្នឹង?

[១០:០៥:០៧]

**ឆ៖** បាទ ក្នុងពេលប្រយុទ្ធគ្នានៅក្នុងសមរភូមិ គឺការទទួលនៃផែនការប្រយុទ្ធក្នុងក្របខ័ណ្ឌយោធា គឺតែពេលប្រយុទ្ធគ្នាគឺអត់មានបញ្ជាទេ ឲ្យសត្រូវស្លាប់រស់នៅពីមុខ គឺប្រយុទ្ធគ្នា គឺបាញ់ទាំងអស់ បាទ

ពេលឲ្យតែសត្រូវ។ ហើយអ៊ីចឹងអត់មានបញ្ជាពីណាទេ ឲ្យតែសត្រូវស្លាប់រស់ហើយគឺថាប្រយុទ្ធនៅក្នុងសមរភូមិ គឺម្ចាស់ការៗទៅតាមរៀងៗខ្លួន ធ្វើម៉េចយកឲ្យឈ្នះ បាទក្នុងសម័យបច្ចុប្បន្ននោះ។ បាទ សូមអរគុណ។

**ស៖** លោកចង់និយាយថាម៉េចហ្នឹងនៅពេលដែលលោកនិយាយថា ពេលនុំងគឺថាពួកយើងគឺជាក្រុមស្វយ័តនោះ?

**ឆ៖** បាទ នៅពេលដែលការរៀបចំប្រយុទ្ធ ការប្រយុទ្ធសភាពការណ៍ៗមិនស្រួល។ សភាព-ការណ៍អី? ថាសភាពការណ៍គេវ៉ៃយើងហើយ បើអ៊ីចឹងត្រូវលក្ខណៈដែលត្រៀមប្រយុទ្ធៗ ហើយដល់ត្រៀមប្រយុទ្ធដែលប្រព្រឹត្តិការណ៍ដែលកើតឡើងហើយ គឺអ្នកត្រៀមប្រយុទ្ធនោះដឹងតែប្រយុទ្ធទេៗ។ ព្រោះកាលនុំងនៅក្នុងអំណាចឆ្នាំ៧៥ ទើបតែរំដោះហើយហ្នឹង គឺដល់មានសម័យអាមេរិកាំងហ្នឹងប្រយុទ្ធគ្នាហ្នឹងគឺថា វ៉ៃគ្នាម៉ាទឹងហ្នឹងទៀត គឺថាមានការស្លាប់រស់នៅលើកោះហ្នឹងក៏មាន។ អ៊ីចឹងទ័ពដឹងតែប្រយុទ្ធទេ ដឹងតែប្រយុទ្ធទេ។ ប្រយុទ្ធម្ចាស់ការរៀងៗខ្លួនធ្វើម៉េចបើខ្មាំងដាក់ទ័ពបានហើយ ប្រយុទ្ធវ៉ៃយើងៗ ក៏យើងស្លាប់។ អ៊ីចឹងមានតែការប្រយុទ្ធគ្នាទៅវិញទៅមក អ៊ីចឹងអត់មានបញ្ជាពីវរសេនាតូចណាវរសេនាធំណាទេគឺថាម្ចាស់ការរៀងខ្លួននៃការប្រយុទ្ធនៅក្នុងអង្គភាពរបស់ខ្លួនដែលទល់មុខតែម្តង។បាទសូមអរគុណ។

[១០:០៧:៣០]

**ស៖** ខ្ញុំយល់ច្បាស់ហើយលោកសាក្សីអំពីការចាប់កប៉ាល់ម៉ាយ៉ាហ្គេស គឺថាការចាប់កប៉ាល់នេះមិនបានធ្វើឡើងនៅក្នុងពេលសង្គ្រាមនោះទេ។ សំណួររបស់ខ្ញុំសួរថា អ្នកណាជាអ្នកបញ្ជាឲ្យចាប់កប៉ាល់ម៉ាយ៉ាហ្គេស? ហើយអ្នកណាជាអ្នកបញ្ជាឲ្យឃាត់កប៉ាល់ម៉ាយាហ្គេសនេះទុកនោះ?

**ឆ៖** បាទ អរគុណណាស់។ អ្នកបញ្ជាចាប់កប៉ាល់ម៉ាយ៉ាហ្គេស បញ្ជាវរសេនា -- ពីកងពលមកវរសេនាធំ បញ្ជាពីវរសេនាធំទៅវរសេនាតូច បញ្ជាវរសេនាតូចទៅយោធា។ មិនមែនថាវរសេនាតូចណាមួយ ឬក៏វរសេនាធំណាមួយម្ចាស់ការបានទេ ទាល់តែបញ្ជាពីលើមកបានទៅចាប់។ ហើយក្នុងការចាប់នោះ ខ្ញុំដឹងថាចាប់មិនមែនត្រូវច្បាប់ទេ កាលទើបតែចប់សង្គ្រាមភ្លាមមិនទាន់មានច្បាប់អីចែងមកអត់ទាន់មានច្បាប់អីទេ គឺថាឲ្យមាន -- ឲ្យតែកប៉ាល់នៅលើផ្ទៃទឹកនៅសមុទ្រជិតកោះកម្ពុជាគឺចាប់ទាំងអស់។ អ៊ីចឹងបញ្ជាពីខាងលើមកអ៊ីចឹង គឺថាខាងក្រោមក៏អនុវត្តទៅតាម បើមិនអនុវត្តទៅតាមខុសគោលការណ៍នយោបាយរបស់គេ គឺមានបញ្ហាដែលការដោះស្រាយគ្នា។ អ៊ីចឹងយោធាខាងក្រោមដឹងថាចាប់តែ

ប៉ុណ្ណោះ។ បាទ សូមអរគុណ។

**ស៖** ឥឡូវនេះគឺថាវាចំចំណុចដែលខ្ញុំត្រូវសួរនេះហើយ។ លោកសាក្សី លោកបានរៀបរាប់ស្ថានការណ៍ដូចតទៅ លោកគឺជាសមាជិកនៃកងកាំភ្លើងធំនៅលើកោះដាច់ស្រយាលមួយ ហើយកងកម្លាំងផ្សេងទៀតចាប់កប៉ាល់ម៉ាយ៉ាហ្គេស។ តើធ្វើម៉េចបានជាលោកដឹងអំពីថា អ្នកណាបញ្ជាឲ្យចាប់កប៉ាល់ម៉ាយ៉ាហ្គេស? អ្នកណាជាអ្នកឲ្យចាប់កងនាវិកនៅលើកប៉ាល់ម៉ាយ៉ាហ្គេសនោះ? ធ្វើម៉េចបានជាលោកដឹង?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:១០:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ដឹងថា សំណួររបស់លោក កូប៉េ ហ្នឹង គឺត្រឹមត្រូវឬក៏អត់ សាក្សីហ្នឹងគាត់និយាយថា គាត់អត់ គាត់លែងនៅខាងកាំភ្លើងធំទៀតហើយ ដូច្នេះគាត់មិននៅក្រោមឱវាទ ខាងកាំភ្លើងធំទេ។ អ៊ីចឹង ខ្ញុំដូចជាមិនយល់ថាហេតុអ្វីបានជាលោកសួរពាក់ព័ន្ធទៅនឹងខាងកងកាំភ្លើងធំនេះទៅវិញ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ពេលហ្នឹងគាត់នៅតែជាសមាជិកកងកាំភ្លើងធំ បាញ់កាំភ្លើងខ្វសេត ហើយគាត់ក៏បានបាញ់ទម្លាក់យន្តហោះ។ អ៊ីចឹងបានខ្ញុំសួរអ៊ីចឹង ប៉ុន្តែខ្ញុំអាចកែប្រែបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ សាក្សីគាត់បាននិយាយច្បាស់ហើយ គាត់ថា កាំភ្លើងខ្វសេតហ្នឹងគេប្រមូលហើយយកទៅដាក់ឲ្យខាងកងទ័ពជើងទឹក ហើយគាត់ៗមិនស្ថិតនៅក្នុងក្រុមកងកាំភ្លើងធំហ្នឹងទៀតទេ គេដកគាត់ចេញហើយ គាត់គេដកគាត់ចេញពីហ្នឹងហើយ។ អ៊ីចឹងលោកសួរសំណួរហ្នឹង មានពាក់ព័ន្ធមានប្រយោជន៍អីទៀត?

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបដោយត្រង់ទៅចុះលោកចៅក្រម ឡាវែន៍ គឺថាគាត់មិនបានជាសមាជិកកងនាវា -- កងទ័ពជើងទឹកនៅពេលនោះទេ គឺ គាត់ថាគាត់នៅជាចំណុះរបស់កងពល១៦៤ដដែល ពេលនោះ។ ហើយយ៉ាងហោចណាស់ក៏គាត់ជាផ្នែកមួយនៃកងទ័ពរបស់ភូមិភាគនិរតីដែរទេ។ តែខ្ញុំសូមកែប្រែសំណួរចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅពេលដែលលោកស្ថិតនៅលើកោះតាង លោកចំណុះ -- លោកជាកងទ័ពចំណុះឲ្យភូមិភាគនិរតីដដែល ហើយលោកនៅតែជាសមាជិកនៃកងកាំភ្លើងធំនេះ *អាល់ទេរី* នេះដដែល ឬក៏លោកចំណុះផ្សេង កងផ្សេងទេ?

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំឡើងពីភូមិភាគនិរតីចូលទៅនៅកំពង់សោម គឺភូមិភាគ យុទ្ធភូមិភាគ។ ក្រោយមកបានជាកងពល១៦៤ហ្នឹង ជាយុទ្ធភូមិភាគ ភូមិភាគមជ្ឈិមបាទ ភូមិភាគមជ្ឈិម។ អ៊ីចឹង ខ្ញុំអត់មាននៅការពាក់ព័ន្ធអីនៅជាមួយនិរតីទេ គឺនៅភូមិភាគមជ្ឈិមបាទ នៅកងពល១៦៤។ បាទ នេះខ្ញុំជម្រាបដោយត្រង់ ដោយអត់មានពាក់ពិន វាក់វិន ហើយកាំភ្លើងធំ ក៏អត់មានពាក់ពិនអីដែរ ព្រោះកាំភ្លើងនេះ ការរៀបធ្វើរជើងនៃការប្រយុទ្ធទេ មិនមែននៅកងកាំភ្លើងធំ បាញ់ផ្គោងទម្លាក់អីទៅកន្លែងណាមួយ គ្មានទេ។ អានេះគឺជាកាំភ្លើងយន្តសម្រាប់ប្រយុទ្ធនៅលើៗគោក។ កាំភ្លើងខ្វសេត កាំភ្លើងខ្វរីតកាំភ្លើងត្បាល់អី អាហ្នឹងជាការធម្មតានៃការ -- ប៉ុន្តែខ្ញុំដាច់ដោយឡែកអត់មាននៅកងកាំភ្លើងធំទេ ប៉ុន្តែការចាត់តាំងរបស់អង្គការ បើថាឲ្យយើងកាន់កាំភ្លើងអី បើថាកាន់៤០ ឬមួយកាន់កាំភ្លើងខ្វសេត យើងត្រូវតែតាម ប៉ុនបើថាឲ្យជាតាំងថាកងកាំភ្លើងធំ គឺអត់ទេ។ បាទ ក្នុងនោះគឺចម្រុះហើយ ហើយនៅក្នុងកង ក្របខ័ណ្ឌនៃកងពល១៦៤ ភូមិភាគមជ្ឈិម។ បាទ សូមអរគុណ។

[១០:១៣:៤០]

**ស៖** ឥឡូវនេះ និយាយអំពីថ្ងៃ០៧ ខែឧសភា គឺថា លោកមិនមែនជាកងទ័ពរបស់ភូមិភាគនិរតីហើយក៏មិនមែនជាសមាជិកនៃកងកាំភ្លើងធំដែរ គឺថានៅក្នុងកងផ្សេងមួយ ប៉ុន្តែចំណុះឲ្យភូមិភាគនិរតី។ សំណួររបស់ខ្ញុំសួរថា ហេតុអ្វីបានជាលោកដឹងមេបញ្ជាការនៅលើកោះតាង ចំណុះឲ្យភូមិភាគនិរតីនោះទទួលបញ្ជាមកពីថ្នាក់លើទៅវិញ។ ធ្វើម៉េចបានជាលោកដឹងអ៊ីចឹង?

**ឆ៖** បាទ ជាពិតប្រាកដណាស់ ដោយខ្ញុំជាសមាជិក យុទ្ធជន នៅតាមអង្គភាពនីមួយៗ គឺស្គាល់ ភាគច្រើនស្គាល់កម្មាភិបាល។ កម្មាភិបាលវរសេនាតូច វរសេនាធំ សូម្បីតែខ្ញុំជាយុទ្ធជនមួយ តែវរសេនាធំរបស់ខ្ញុំៗស្គាល់។ ខ្ញុំស្គាល់ក្នុងក្របខ័ណ្ឌនៃកងពល បាទ កងពលក៏ខ្ញុំស្គាល់។ មានប៉ុន្មាននាក់ៗក៏ខ្ញុំស្គាល់ ទាំងឈ្មោះហើយ តាមវរសេនាធំនីមួយៗក៏ខ្ញុំស្គាល់។ ហើយអ៊ីចឹងគេបញ្ជាការ -- ជាបញ្ជាពីលើ បាទ បញ្ជាពីលើឲ្យទៅចាប់ហ្នឹងវាមានផ្នែក។ កងអ្នកទៅចាប់ ដឹងតែគេទៅចាប់ទេ។ ចាប់យកមក

ហើយ យកមកដាក់នៅកន្លែងណាៗ ហ្នឹងអ្នកទទួលខុសត្រូវអាហ្នឹង ដូចជាគេចាប់បានហើយ គេយកមកដាក់ឱ្យអង្គភាពរបស់ខ្ញុំមួយកាលនៅប្រចាំនៅលើកោះតាង។ គឺប្រគល់ថាឈ្មោះអី នៅវរៈណា នៅលើកោះតាងហ្នឹង វរសេនាតូចហ្នឹងឈ្មោះអី? ឈ្មោះ "ក" អ៊ីចឹងទៅ។ អ៊ីចឹងឥឡូវ "ក" ហ្នឹងទទួលខុសត្រូវកប៉ាល់នេះនៅលើកោះ ហើយទុកឱ្យនៅការពារនៅកន្លែងហ្នឹង។ អ៊ីចឹងហើយបានជាខ្ញុំស្គាល់ទៅតាមរយៈ ព្រោះអង្គភាពណាក៏ដូចអង្គភាពណាដែរ យុទ្ធជនស្គាល់ទាំងអស់ គឺមេៗអ្នកដឹកនាំ ជាវរសេនាតូច វរសេនាធំ អង្គភាពកងពលតែមួយក៏ពិតមែន ប៉ុន្តែវាច្រើន។ គ្រាន់តែកងពល១៦៤ ហ្នឹង មានដល់បួនប្រាំ ទាំងអស់ប្រាំពីរកងពលឯណោះ -- ប្រាំពីរវរសេនាធំ បាទខ្ញុំដឹង។ ហើយវរសេនាធំនីមួយៗក៏បានខ្ញុំស្គាល់ទាំងអស់ ស្គាល់។ ខ្ញុំមិនមែនមេបញ្ជាការអីទេ ប៉ុន្តែយុទ្ធជននៅក្នុងកងពលហ្នឹងត្រូវតែស្គាល់មេបញ្ជាការរបស់វរសេនាធំនីមួយៗគឺស្គាល់ ភាគច្រើនស្គាល់អ៊ីចឹងទៅតែម្ដង ព្រោះមានការទាក់ទងគ្នាថា ទាក់ទងគ្នារហូតវរសេនាធំ៦១, ៦២, ៦៣។ អ៊ីចឹង គេមិនហៅថាវរសេនាធំ៦១ទេ ៦១បញ្ជាការឈ្មោះអី? ៦១ បញ្ជាការឈ្មោះ ញ៉ាន់ អ៊ីចឹងទៅ។ ខ្ញុំស្គាល់ឈ្មោះ តាញ៉ាន់។ បញ្ជាការ៦២ឈ្មោះអី? បាទឈ្មោះ "ក" អ៊ីចឹងទៅ។ ត្រូវតែស្គាល់ ខ្ញុំស្គាល់ភាគច្រើន ខ្ញុំស្គាល់តែម្ដង។ ហើយយុទ្ធជនដែលទាំងអស់ភាគច្រើនស្គាល់កម្មាភិបាលគ្រប់ស្មើរតែគ្រប់អង្គភាព។ សូមអរគុណណាស់ ព្រោះនេះជាយោធាត្រូវតែស្គាល់តែម្ដង មេៗអ្នកធំៗហ្នឹង គឺស្គាល់ ភាគច្រើនស្គាល់តែម្ដង តែគ្រាន់តែមេធំមិនសូវស្គាល់អ្នកតូច ស្គាល់តូចៗ កូនចៅអត់សូវស្គាល់ទេ ប៉ុន្តែធម្មតាកូនចៅឆាប់ស្គាល់ណាស់មេ ឆាប់ស្គាល់ណាស់។ អ្វីក៏ឆាប់ស្គាល់? បានថារឿងការងារអី គឺថាទាក់ទងតែមេទេ ទាក់ទងតែមេធំៗទេ។ អរគុណណាស់ សូមបន្តទៀតចុះ។

[១០:១៧:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨នាទី ដល់ម៉ោង ១០:៣៧ នាទី)*

[១០:៣៧:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនិតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំត្រឡប់មកហេតុការណ៍ដែលទាក់ទងទៅនឹងកប៉ាល់អាមេរិកាំង ហើយខ្ញុំនឹងសួរសំណួរមួយចំនួនអំពីហេតុការណ៍នោះ ពីព្រោះថាតាមពិត គឺជាអ្វីដែលបាន -- ពិតជាបានកើតឡើងមែន។ ខ្ញុំនឹងផ្តោតលើទិដ្ឋភាពមួយជាក់ស្តែង ហើយសូមឲ្យលោកពន្យល់ពីខ្សែសង្វាក់នៃការបញ្ជា។ តើអ្នកណា បុគ្គលណាដែលបញ្ជាឲ្យមានការចាប់ខ្លួននាវិកនៅលើម៉ាយ៉ាហ្គេស? តើអ្នកណាជាអ្នកចេញបញ្ជាទៅអ្នកណាជាអ្នកទទួលបញ្ជាឲ្យចាប់នាវិកនៅនៅលើកប៉ាល់ម៉ាយ៉ាហ្គេស?

[១០:៣៨:៥៥]

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ ដោយខ្ញុំជាយុទ្ធជនមួយរូប ជាយោធាមួយរូបនៅលើកោះ បានទទួលនូវផែនការពីថ្នាក់លើ បាទទទួលផែនការពីថ្នាក់លើនៅក្នុងអង្គប្រជុំ បាទ ក្នុងអង្គប្រជុំ គឺយោធាទាំងអស់ត្រូវគោរពអង្គការថ្នាក់លើ បាទគោរពអង្គការថ្នាក់លើ។ អង្គការថ្នាក់លើដាក់សារាចរមកយើងត្រូវតែគោរព បើអ៊ីចឹងហើយវរសេនាតូចត្រូវគោរពរបស់វរសេនាធំ។ វរសេនាធំត្រូវគោរពបញ្ជា--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** អ៊ីចឹងកងពលអ្នកបញ្ជា បាទ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសាក្សី ចាំស្តាប់សំណួរម្តងទៀត! ចាំស្តាប់សំណួរឱ្យបានច្បាស់សិន ហើយចាំឆ្លើយឱ្យចំនឹងសំណួរដែលសួរ។ ឆ្លើយពីភាពចាំបាច់តបទៅនឹងសំណួរដែលសួរបានហើយ ចៀសវាងអត្ថាធិប្បាយហួសព្រំដែននៃការតាំងសំណួរ។ វាឥតប្រយោជន៍ទេ ហើយនាំតែលំបាកដល់លោកខ្លួនឯងទេណា។

តាំងសំណួរសាជាថ្មីម្តងទៀត ដើម្បីឱ្យច្បាស់លាស់!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១០:៤០:១៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំមិនសួរលោកឱ្យនិយាយជាទូទៅទេ។ ខ្ញុំសួរសំណួរមួយច្បាស់លាស់អំពីហេតុការណ៍មួយជាក់លាក់ ថាអ្នកណាជាអ្នកបញ្ជាឱ្យមានការចាប់ខ្លួននាវិកនៅលើកប៉ាល់ម៉ាយ៉ាហ្គេស? អ្នកណាជាអ្នកចេញបញ្ជា អ្នកជាអ្នកទទួលបញ្ជាក្នុងការចាប់នាវិកពេលនោះ?

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ បញ្ជាពីលើទៅមាន តាមុត កងពលបញ្ជាទៅសមាជិកនៃកងនាវាកប៉ាល់ ខាងកប៉ាល់ឱ្យទៅចាប់បាទ។ អាហ្នឹងៗគេតាមបញ្ជាបាទ ទៅតាមបញ្ជា បញ្ជាទៅវរសេនាតូចវរសេនាតូចគេបញ្ជាទៅយោធាទៅចាប់ហើយនៅក្នុងអង្គភាពរបស់គេ។ បាទ ទៅចាប់យកមកតែម្តង។ បាទ សូមអរគុណ។

**ស៖** អ៊ីចឹងលោកសាក្សី គឺថាបញ្ជាលោកនិយាយហាក់ដូចជាទូទៅ មាស មុត ជាមេបញ្ជាការថ្នាក់ខ្ពស់។ ថាហេតុអ្វីបានជាលោកដឹង លោកនៅកោះតាងឯណោះ លោក ហេតុអីបានលោកដឹងថា មាស មុត បញ្ជាទៅខាងវរសេនាតូច តើលោកបានឃើញ ។ ឬលោកឮអ្នកណានិយាយ? លោកប្រាប់ខ្ញុំឱ្យច្បាស់មើល៍ តើវិធីដែលលោកដឹងហ្នឹង គឺដោយរបៀបណាថា អ្នកណាជាអ្នកចេញបញ្ជា អ្នកណាជាអ្នកទទួលបញ្ជាកាលនោះ?

**ឆ៖** បាទ កាលនុ៎ងគេចាប់ម៉ាយ៉ាហ្គេសហ្នឹងមកបាទ ចាប់ម៉ាយ៉ាហ្គេសនុ៎ងមានខាងនាវាខាងជើងទឹកបាទ កងជើងទឹករបស់គេ គឺខាងគេចាប់មក។ ចាប់មកៗហ្នឹងគេបញ្ជា គេស្តាប់ពីខាងលើទាល់តែខាងលើបញ្ជាបាទ គឺកងពលបញ្ជា បានគេហ៊ានចាប់ បើថាអត់បញ្ជាទេគឺអត់ចាប់ជាដាច់ខាត។

មិនប៉ានចាប់ទេ ព្រោះគ្មាននរណាចង់ធ្វើសង្គ្រាមបន្តទៀតទេ ព្រោះកាលពេលវេលានុ៎ងចប់ហើយ ប៉ុន្តែដល់ចាប់អ៊ីចឹងមានបញ្ហាកើតឡើង។ អ៊ីចឹងមានតែខាងលើទេ បានប៉ានបញ្ជាទៅកង ហើយកងនោះ ក៏គេនិយាយដែរ។ និយាយថា "ចុយប៉ានទៅចាប់វី កប៉ាល់ធំ!" "យី! ទាល់តែយើងបញ្ជាទៅវើយ៉ាងណាក៏ដោយ តែគេបញ្ជាយើងត្រូវតែចាប់" "អ៊ីចឹងយើងធ្វើហ្នឹងដោយម្ចាស់ការដោយខ្លួនឯង ឬមួយហៅថាបញ្ជាពីលើមក? យី! មិនមែននរណាប៉ាននោះទេ ត្រឹមវរសេនាតូច វរសេនាធំក៏មិនប៉ានដែរ ទាល់តែបញ្ជាពីលើ ពីកងពលមក បានគេប៉ានទៅធ្វើសកម្មភាពហ្នឹង ចាប់មកតែម្តង។" បាទ សូមអរគុណ។

[១០:៤៣:០៧]

**ស៖** តើពិតដែរឬទេលោកសាក្សី ថាលោកមិនដឹងពីអ្វីថា អ្នកណាជាអ្នកចេញបញ្ជានៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៥ ថាមិនដឹងថាអ្នកណាជាអ្នកចេញបញ្ជាឲ្យចាប់កប៉ាល់ម៉ាយ៉ាហ្គេសទេ ហើយគ្រាន់តែលោកសន្និដ្ឋានថា ដោយសារលោក មាស មុត ជាមេបញ្ជាការកងពល ខ្សែសង្វាក់បញ្ជាតាមយោធាគឺបែបហ្នឹង ហើយលោកក៏សន្និដ្ឋាថា មាស មុត ទៅ។ តើអ៊ីចឹងដែរឬទេ តាមសក្ខីកម្មរបស់លោក?

**ឆ៖** នេះតាមការក្តាប់នៃការរៀនសូត្ររបស់ -- ក្នុងអង្គភាពនីមួយៗទទួលពីផែនការ ពីកងពលទេ។ អ្វីក៏ដោយទាល់តែទទួលផែនការពីកងពលបានប៉ានធ្វើអាហ្នឹង។ អ្វីក៏មិនម្ចាស់ការបានទេ ទាល់តែទទួលផែនការពីកងពល។ អ៊ីចឹងអត្តនោម័តិរបស់ខ្ញុំ ខ្ញុំជឿថាដល់តែបញ្ជាពីកងពល។ បាទសូមអរគុណ។

**ស៖** ខ្ញុំគិតថា គ្រប់គ្រាន់ហើយលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងនិយាយទៅដល់ពីពេលវេលារហូតទៅដល់ឆ្នាំ១៩៧៦ នៅពេលដែលកងពល១៦៤ ដែលបង្កើតឡើងជាកងនាវា។ តើលោកអាចជម្រាបតុលាការបានទេ តើមានសមាជិកមានប៉ុន្មាន? កងទ័ពប៉ុន្មាន ហើយនិងកងទ័ពមិនប្រយុទ្ធប៉ុន្មាននៅក្នុងឆ្នាំ១៩៧៦នុ៎ង គឺថាចំនួនសរុបនៃកងទ័ពយោធានៅក្នុងកងពល១៦៤នោះ មានប៉ុន្មានតាមការប៉ាន់ស្មានរបស់លោក?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំមិនបានដឹងទេ ព្រោះរឿងរ៉ាវអស់ទាំងនេះទាក់ទងនឹងជាកម្មាភិបាលគេធំៗ អាហ្នឹងបានគេដឹងនៃចំនួនកងទ័ពត្រៀម កងទ័ពប្រយុទ្ធកងទ័ពអី។ ខ្ញុំដឹងតែត្រឹមវរសេនាធំរបស់ខ្ញុំទេដែលអ្នកប្រយុទ្ធ បាទអ្នក អត់មានត្រៀមទេ មានតែអ្នកប្រយុទ្ធ អ្នកត្រៀមប្រយុទ្ធបាទ។ មានតែ បើថាឲ្យដឹងនៅក្នុងក្របខ័ណ្ឌនៃការកងពលទាំងមូលហ្នុង គឺខ្ញុំអត់បានដឹងដែរទេ ព្រោះខ្ញុំក្តាប់ជុំតែក្នុងវរសេនាធំរបស់ខ្ញុំ អាហ្នឹងខ្ញុំក្តាប់ជុំ។ បាទអរគុណណាស់។

[១០:៤៥:៤៧]

**ស៖** ឥឡូវនេះ ខ្ញុំពិនិត្យទៅឋានានុក្រមខាងក្រោមទៀត។ តើលោកមាន ដឹងថាមានយុទ្ធជនប្រយុទ្ធ ហើយយុទ្ធជនដែលមិនប្រយុទ្ធប៉ុន្មាននៅក្នុងកងវរសេនាធំ១៦០ -- វរសេនាធំ៦២ ដែលស្ថិតនៅក្នុងកងពល១៦៤នោះ លោកដឹងទេ មានយុទ្ធជនប្រយុទ្ធ ហើយនិងមិនប្រយុទ្ធហ្នឹងមានប៉ុន្មាន?

**ឆ៖** វរសេនាធំរបស់ខ្ញុំមាន បួនវរសេនាតូចៗ សុទ្ធតែជាអ្នកកងការពារនៅលើកោះទាំងអស់ បាទ នៅលើកោះទាំងអស់។ អ៊ីចឹងវរសេនាធំរបស់ខ្ញុំ៦២នេះ បាទជាអ្នកត្រៀមប្រយុទ្ធ បាទត្រៀមប្រយុទ្ធទាំងអស់នៅលើកោះការពារ និងលើកោះទាំងអស់គ្នាបាទ អត់មាននៅលើគោកទេ អាហ្នឹងសូមអរគុណ ហើយជម្រាបប្រាប់ដោយត្រង់។

**ស៖** ខ្ញុំនឹងត្រូវប្រាប់លោកថា វរសេនាធំ៦២នោះ ហើយប្រហែលជាថ្ងៃ២៧ ខែតុលា ឆ្នាំ១៩៧៦ នោះ គឺប្រហែលមាន២០០០ជាងឯណោះ បាទប្រហែលជាមាន១៦០០ជាងអ្នកឯណោះ។ តើលោកអាចនឹកឃើញពីចំនួននេះទេ?

**ឆ៖** បាទ ខ្ញុំអត់បាននឹកឃើញដែរទេ នៅនឹកឃើញមិនអស់ទេ ព្រោះមួយវរសេនាតូចវាមាន ៤០០នាក់ – មួយវរសេនាតូចវាមាន៤០០នាក់ ហើយវាបួនវរសេនាតូចនោះ។ អ៊ីចឹងខ្ញុំគិតឃើញមិនអស់ទេបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី សំណួរសូមឲ្យជាក់លាក់ ហើយសូមឲ្យលោកយោងឯក -- យោងផង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺខ្ញុំយោងទៅរកឯកសារ E3/19/23.3.45.1 ជាឯកសារដែលស្ថិតនៅក្នុងបញ្ជីកងទ័ពប្រចាំថ្ងៃនៅក្នុងខែតុលា ឆ្នាំ១៩៧៦ បាទដែលពិនិត្យទៅគឺថារៀបចំឡើងដោយៗលោកមាស មុត ខ្លួនឯងដែលជាកងពល១៦៤ ដែលថាកងទ័ពសរុបនៅក្នុងកងពល១៦៤នេះ គឺ៨៦១១នាក់ បាទ ហើយបើសរុបទាំងកងគាំទ្រផ្សេងៗទៀត គឺថាវាមានកងពល -- កងទ័ពគាំទ្រ គឺថាអាចមាន១៧០០នាក់ផ្សេងទៀត។ អ៊ីចឹងថាតើនៅក្នុងកងវរសេនាធំរបស់លោកហ្នឹងនៅពេលនោះ តើពិតជាមាន១៦០០នាក់អ៊ីចឹងដែរឬទេលោកសាក្សី?

[១០:៤៩:០៧]

**2-TCW-1000៖**

**ឆ៖** បាទ ពិតប្រាកដមែនហើយ សូមអរគុណ។

**សៈ** ប៉ុន្តែសំណួររបស់ខ្ញុំ តើលោកស្គាល់អ្នកទាំងអស់ហ្នឹង ស្គាល់ឈ្មោះទាំងអស់ទេ ថាតើមេបញ្ជាការកងតូច បញ្ជាការកងអនុសេនាធំ ហើយមេបញ្ជាការក្រុម កងវរសេនាតូចជាដើម។ តើលោកស្គាល់បានប៉ុន្មានដែរឬទេ?

**ឆះ** បាទ កន្លងមកខ្ញុំនៅក្នុងវរសេនាធំ៦២ហ្នឹង គឺថាអត់អីទេមិនបានស្គាល់អស់ទេ ស្គាល់តែកម្មាភិបាលធំៗទេបាទ។ វរសេនាធំឈ្មោះអី ឈ្មោះយ៉ាង ជាមេបញ្ជាការវរសេនាធំរបស់ខ្ញុំ។ ហើយវរសេនាតូចរបស់ខ្ញុំហ្នឹងឈ្មោះអី អាហ្នឹងខ្ញុំស្គាល់តែបញ្ជាការវរសេនាតូច និងបញ្ជាការនៃវរសេនាធំតែប៉ុណ្ណឹងទេ។ ត្រង់តែអនុសេនាតូច អនុសេនាធំ ជារួមនៅក្នុងវរសេនាធំរបស់ខ្ញុំទូទៅ គឺអត់ ចាំមិនបានទេ បើកម្មាភិបាលធំៗជាវរសេនាធំខុសៗគ្នា អាហ្នឹង ខ្ញុំអាចចងចាំបាន។

**សៈ** សូមលោករៀបរាប់ប្រាប់ខ្ញុំ ថាតើការណែនាំ ហើយការបញ្ជាអ្វីខ្លះដែលលោកបានឃើញដោយខ្លួនឯង បានដឹងដោយខ្លួនឯង តើលោកធ្លាប់បានឃើញថ្នាក់លើ ហើយនិងបញ្ជាការរបស់លោកទទួលមកពីថ្នាក់លើ ហើយថ្នាក់លើមួយទៀតបានទទួលពីថ្នាក់លើមកពីកន្លែងណា បញ្ជូនទៅរបៀបម៉េច។ តើលោកបានឃើញដោយខ្លួនឯងផ្ទាល់បែបនេះដែរឬទេ?

[១០:៥១:០៨]

**ឆះ** បាទ ខ្ញុំខាងយោធា គឺថាបានតែទទួលបញ្ជាទេ បាទតែទទួលបញ្ជា។ ទទួលបញ្ជាពីខាងលើត្រឹមសិទ្ធិ ខ្ញុំទទួលត្រឹមវរសេនាតូច។ អ៊ីចឹងវរសេនាតូចហ្នឹងចេះតែទទួលបន្តពីលើមក បើឲ្យអត្តនោម័តិវរសេនាតូចហ្នឹងធ្វើ គឺថាម្ចាស់ការធ្វើខ្លួនឯង គឺមិនបានទេ ព្រោះបានរៀនសូត្រពិតប្រាកដណាស់ រៀនសូត្រអំពី គោរពវិន័យៗ។ អ្វីខាងលើដាក់ ត្រូវធ្វើ បានធ្វើ។ បើខាងលើមិនដាក់ គឺដាច់ខាតមិនឲ្យធ្វើទេ។ អ៊ីចឹងខ្ញុំទទួលត្រឹមវរសេនាតូចរបស់ខ្ញុំ វរសេនាតូចទទួលទៅ បើវរសេនាធំ វរសេនាធំទទួលបញ្ជាពីកងពល។ បាទ សូមអរគុណណាស់។

**សៈ** បាទ ឥឡូវនេះ យើងចូលទៅដល់ឧបទ្ទវហេតុពីរដែលលោកបានរៀបរាប់ ដែលនៅក្នុងសវនាការពីមុន ពីបីសប្តាហ៍មុននោះ គឺថាលោក ហេតុការណ៍ទី១ ដែលលោករៀបរាប់ គឺថាកើតឡើងនៅចុងឆ្នាំ១៩៧៦ ឬក៏ដើមឆ្នាំ១៩៧៧ គឺការសម្លាប់ដោយយោធាខ្មែរក្រហមនូវគ្រួសារវៀតណាម មានប្តីប្រពន្ធ និងកូនមួយ ហើយសម្លាប់ដោយកងទ័ពមកពីកងវរសេនាធំ៦២ ដែលជា -- ឈរជើងនៅកោះពូលូវៃ តើលោកស្គាល់ទេអ្នកដែលសម្លាប់គ្រួសារវៀតណាមហ្នឹងដោយឈ្មោះ លោកស្គាល់ថាក្រុមហ្នឹងមានអ្នកណាខ្លះ? ឈ្មោះអ្វីខ្លះ?

[១០:៥៣:០៤]

**ឆ៖** បាទក្នុងពេលនោះ ខ្ញុំក៏ភ្លេចឈ្មោះគេបាត់ហើយ ហើយវាយូរពេក ក្នុងវរសេនាតូចរបស់ខ្ញុំ។ វរសេនាតូចរបស់ខ្ញុំហ្នឹង មិនមែនខ្ញុំនៅក្នុងវរសេនាតូចហ្នឹង វាអនុសេនាធំខុសគ្នា ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃវរសេនាតូចជាមួយគ្នា ប៉ុន្តែក្រុមពិសេស ក្រុមកងពិសេស ដែលវរសេនាតូចហ្នឹងគេអ្នកធ្វើឃាត ហើយកាលនោះ ខ្ញុំក៏នៅជិតហ្នឹងដែរ បានឃើញរូបភាពនេះពិតប្រាកដមែន តែគ្រាន់តែខ្ញុំមិននៅចងចាំជាឈ្មោះទេ ប្រហែលជាអ្នកនេះភាគច្រើន គឺថាបាត់បង់ជីវិតអស់ដែរ។ បាទ សូមអរគុណ។

**ស៖** ខ្ញុំអាចយល់បាន ដែលលោកថាមិនស្គាល់ឈ្មោះនូវយោធាទាំងនោះ។ តើលោកស្គាល់ថាមេបញ្ជាការរបស់គេឈ្មោះអ្វី? តើអ្នកណាជាមេបញ្ជាការលើមេបញ្ជាការរបស់ក្រុមនៅក្នុងកងពិសេសវរសេនាតូចហ្នឹង លោកនៅចាំទេមានឈ្មោះអ្វីខ្លះ?

**ឆ៖** បាទ បញ្ជាការវរសេនាតូចនោះ ឈ្មោះ បងយឺន – បងយឺនៗ បាទ បងយឺន ហើយនៅប្រធានក្រុមពិសេសនោះឈ្មោះ ហាន បាទឈ្មោះ ហាន។ នេះជាក្រុមកងពិសេសរបស់គេនៅអ្វីៗ គេត្រូវធ្វើអីៗ អាហ្នឹងលើនៅក្នុងកងពិសេសពិសេសរបស់វរសេនាតូចហ្នឹងហើយ បាទ ខ្ញុំនៅអនុសេនាធំខុសនៅវរសេនាតូចហ្នឹង ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃវរសេនាតូចហ្នឹងដែរ។ ប៉ុន្តែគ្រាន់អនុសេនាធំដោយឡែក បាទ។

[១០:៥៤:៥៥]

**ស៖** ជាថ្មីម្តងទៀត លោកសាក្សី លោកឆ្លើយចម្លើយទូទៅ ប៉ុន្តែខ្ញុំសួរលោកបែបនេះទេថា នៅក្នុងកងវរសេនាធំ១៦២ ដែលមានសមាជិក១៦០០ហ្នឹង គឺថាតើអ្នកណាជាមេបញ្ជាការដែលបញ្ជាឲ្យយោធាទៅសម្លាប់ក្រុមគ្រួសារវៀតណាមដែលមានប្តី ប្រពន្ធ និងកូន នៅពេលនោះ?

**ឆ៖** កន្លងមកអ្វីក៏ដោយ ក៏មានការទាក់ទិន និងគោរពច្បាប់ដែរ ព្រោះច្បាប់គេបញ្ជា ខាងយោធាធ្វើហើយ។ អីចឹងអ្វីក៏ដោយក៏បញ្ជាតាមជាន់ថ្នាក់មក បាទ បញ្ជាតាមជាន់ថ្នាក់បានខាងយោធាធ្វើ។ អីចឹងមិនមែនថា ធ្វើទៅម្ចាស់ការនៅវរសេនាតូច ប្រធាននៃវរសេនាតូចហ្នឹង គឺថាអត់ទេ ទាល់តែបញ្ជាពីលើមកបានគេហ៊ានធ្វើ។ ហើយបើគេអត់បញ្ជាមក មានតែបញ្ជូន បាទ បញ្ជូនគេឲ្យទៅនៅ ទៅដីគោក។ បាទ ហ្នឹងខ្ញុំសូមជម្រាបអីចឹង។

**ស៖** ជាថ្មីម្តងទៀត លោកសាក្សី លោកបានរៀបរាប់ពីហេតុការណ៍មួយដែលបានកើតឡើងនៅក្នុងកោះពូលូវ៉ៃ ហើយការកាប់សម្លាប់ហ្នឹងធ្វើឡើងដោយកងទ័ពមកពីវរសេនាធំ៦២។ តើលោក

អាចប្រាប់ខ្ញុំនិងតុលាការបានដែរទេ ថាតើយោធាទាំងអស់ហ្នឹងធ្វើការសម្លាប់ហ្នឹងដោយខ្លួនឯង ឬក៏មានការណែនាំ ការបញ្ជា? ក្នុងករណីដែលមានការបញ្ជា អ្នកណាជាអ្នកបញ្ជាឲ្យអ្នកទាំងអស់នោះធ្វើបែបនោះ?

**ឆ៖** បាទ អរគុណណាស់។ វរសេនាតូចបញ្ជាពីវរសនាធំមកហើយ បានប៊ានបញ្ជាឲ្យយោធាកងពិសេសរបស់គាត់ធ្វើ បានប៊ានធ្វើ។ បាទ សូមអរគុណ។

[១០:៥៧:១៨]

**ស៖** បាទ ប៉ុន្តែអ្នកណាជាមេបញ្ជាការកងវរសេនាតូចដែលចេញបញ្ជាទៅឲ្យកងពិសេសហ្នឹង បាទ? ហើយកងពិសេសនោះ មេបញ្ជាការឈ្មោះអី? តើលោកបានឮ បានឃើញ ឬក៏ដឹងដោយរបៀបណា? សូមលោកប្រាប់ខ្ញុំ និងតុលាការ ក្នុងឋានៈជាសាក្សីពេលនេះ។

**ឆ៖** នៅក្នុងនុ៎ង ដោយជឿជាក់ថា គោរពវិន័យ គោរពច្បាប់អង្គការ គឺបញ្ជាវរសេនាតូចឈ្មោះតាឃឿន គាត់អ្នកបញ្ជាផ្ទាល់។ ព្រោះខាងលើអនុញ្ញាតឲ្យធ្វើហើយ បានគាត់បញ្ជាឲ្យយោធាធ្វើ។ បាទ ឈ្មោ តាឃឿន គឺគាត់បញ្ជាការនៃវរសេនាតូច ហើយបញ្ជាទៅក្រុមពិសេសនៃការកងការពាររបស់គាត់ហ្នឹង គឺឲ្យធ្វើតែម្តង។ បាទ នេះជាផ្ទាល់ បាទគឺផ្ទាល់ហ្មង។ ផ្ទាល់ដែលខ្ញុំបានរស់នៅនោះដែរ គឺអ្វីក៏ដោយពេលដែលធ្វើគឺហៅកងទ័ព បាទ មានប្រជុំហើយ អីក៏ដោយ ប្រជុំនិងមានផែនការធ្វើ បានធ្វើ។ បាទ បើអត់ប្រជុំ អត់មានផែនការអីទេ គឺអត់ទេ អត់ មិនអាចធ្វើបានទេ។ អ្វីក៏ដោយផ្សព្វផ្សាយហើយបានធ្វើ។ បាទ អរគុណ។

**ស៖** ខ្ញុំនឹងកាត់របស់លោក -- កាត់សក្ខីកម្ម ប៉ុន្តែហេតុការណ៍ដែលលោកបានរៀបរាប់ថា កើតឡើងនៅកោះឆ្ងាយពីមាត់សមុទ្រ ច្រាំងសមុទ្រ ដែលថាបើជិះកាណូតវិញត្រូវប្រហែលប្រាំមួយម៉ោង ឬប្រាំពីរម៉ោង បានទៅដល់។ ថាតើការបញ្ជូន បញ្ជាហ្នឹងដូចម្តេច ដើម្បីឲ្យគេសម្លាប់ក្រុមគ្រួសារហ្នឹង? តើវិធីនៃការបញ្ជាដូចម្តេច លោកបានឮបញ្ជា ឬក៏បានឃើញការបញ្ជូន ការបញ្ជាហ្នឹងដូចម្តេច? តើលោកបានដឹងដូចម្តេចនៅថ្ងៃនោះ?

**ឆ៖** បាទ ក្នុងពេលនុ៎ងគឺបញ្ជាទៅតាម បាទ តាមទូរលេខ ទាក់ទងតាមទូរលេខទៅ គេបញ្ជាទៅវរសេនាតូច វរសេនាធំទៅ បញ្ជាទៅដល់ ធ្វើសកម្មភាពភ្លាមៗហ្មង បាទ។ បាទ អរគុណ។

**ស៖** តើលោកកាលនោះមានសិទ្ធិក្នុងការអានសារទូរលេខហ្នឹងទេ?

**ឆ៖** បាទ គ្មានទេ។ បាទ អរគុណ។

**ស៖** តើអាចទៅរួចដែរទេដែលថា អ្នកនៅកោះពូលូវ៉ៃនោះអាចទទួលសារទូរលេខបាន? ទទួលដោយរបៀបណា?

**ឆ៖** ការទទួលទូរលេខរបស់គេ គឺជានីរសារដែលក្នុងក្រុមនីរសាររបស់គេទេអ្នកទទួល ទទួលហើយគេផ្សព្វផ្សាយទៅមេបញ្ជាការហើយ។ បាទ អានេះតាមៗការដឹងរបស់ខ្ញុំនៅកន្លែងហ្នឹង គឺខ្ញុំបានចេញចូល ឃើញចេញចូលជាបន្តបន្ទាប់ដែរ។

**ស៖** តើការិយាល័យមន្ទីរនៅកោះពូលូវ៉ៃនោះជាកោះមួយនៅឆ្ងាយណាស់។ តើមន្ទីររបស់លោកនៅកន្លែងណាកាលនោះ ពេលដែលលោកដឹងនោះ?

[១១:០១:៣១]

**ឆ៖** បាទ នៅក្នុងពេលហ្នឹង ខ្ញុំនៅជាអនុសេនាធំ៥៣បាទ ហើយនិងទីបញ្ជាការវរសេនាតូចហ្នឹងនៅឃ្លាតគ្នាប្រហែលជា៥០០ម៉ែត្រទេ។ ៥០០ម៉ែត្រៗមួយអនុសេនាធំ។ ឃ្លាតគ្នាប៉ុណ្ណឹងៗទេ ព្រោះកោះនុ៎ងមិនមែនធំប៉ុន្មានទេ កោះពូធីវ៉ៃនោះ។ អ៊ីចឹងកោះនុ៎ងវាមានបួនអនុសេនាធំឯណោះ។ អ៊ីចឹងកោះនុ៎ងប្រហែលជា៣គីឡូទេ ប្រហែលជា៣គីឡូទេ ហើយទទឹងប្រហែលជា១គីឡូតែប៉ុណ្ណឹងទេ។ កោះនោះអត់ធំទេ។ អ៊ីចឹងហើយមានបួនអនុសេនាធំនោះ។ អ៊ីចឹងខ្ញុំក៏នៅរស់ក្បែរ រស់នៅក្បែរនៃវរសេនាតូចនោះដែរ។ បាទ សូមអរគុណ។

**ស៖** តើលោកដឹងទេថា កោះពូលូវ៉ៃហ្នឹងវៀតណាមគេយកទៅវិញ កាន់កាប់វិញហ្នឹងនៅពេលណា លោកបានដឹងដែរឬអត់?

**ឆ៖** បាទ នៅក្នុង៧៥ ខ្ញុំជម្រាបអង្គប្រជុំ។ បាទ នៅឆ្នាំ៧៥នេះ ខ្ញុំភ្លេចខែ ភ្លេចអីហើយ។ ហើយជាវរសេនាតូចរបស់ខ្ញុំ ដោយវៀតណាមវាយលុកចូលមកក្នុងយកកោះពូធីវ៉ៃនោះក្នុងឆ្នាំ៧៥។ បាទ គឺវ៉ៃចូលយកពូធីវ៉ៃនេះ គឺថាចាប់ៗអង្គភាពរបស់ខ្ញុំមួយវរសេនាតូចៗ យកទៅដាក់នៅកោះត្រល់ហើយ។ បាទ ហ្នឹងខ្ញុំសូមជម្រាបប្រាប់។

**ស៖** លើកលែងតែខ្ញុំយល់ច្រឡំ ប៉ុន្តែហេតុការណ៍ដំបូងដែលលោកបានរៀបរាប់នោះ បានកើតឡើងនៅដើមឆ្នាំ១៩៧៦ -- ចុង១៩៧៦ ហើយនិងដើមឆ្នាំ១៩៧៧។ តើហេតុការណ៍ហ្នឹងជាហេតុការណ៍កើតនៅលើពូលូវ៉ៃដែរឬទេ អ្វីដែលលោករៀបរាប់អម្បាញ់មិញនេះ?

[១១:០៤:០៤]

**ឆ៖** បាទ ខ្ញុំរៀបរាប់នេះមិនមែនថានេះទេ ឧប្បត្តិហេតុដែលកើតឡើងនៅវៀតណាមចូលមក

យកនៅកោះពូធីវ៉ៃហ្នឹងនៅឆ្នាំចុង៧៦ ចូល៧៧ហើយ។ ក្នុងនោះ ខ្ញុំនៅកោះតាង ខ្ញុំៗសម្រាកពេទ្យនៅក្នុងអង្គភាពហ្នឹងដែរ ប៉ុន្តែខ្ញុំនៅសម្រាកពេទ្យ តែក្រោយមកវៀតណាមបានវ៉ៃលុកយកកោះនោះតែម្តងនៅក្នុងឆ្នាំ៧៥ៗ ចុង៧៥ហ្នឹង។ បាទ ហ្នឹងជាការរឿងរ៉ាវហ្នឹងក៏ខ្ញុំបានដឹង ហើយអង្គភាពរបស់ខ្ញុំក៏បានបាត់បង់ជីវិតអស់ច្រើន ហើយគេចាប់យកទៅចំនួនប្រហែលជាៗ ទាំងអស់ប្រហែលជា៣០០នាក់ដែរ។ បាទ សូមអរគុណណាស់។

**ស៖** ឥឡូវនេះខ្ញុំយល់ច្រឡំហើយលោកសាក្សី។ លោករៀបរាប់អំពីហេតុការណ៍ពីរនៅក្នុងសក្ខីកម្មចុងក្រោយ គឺថា គ្រួសារវៀតណាមប្តីប្រពន្ធ ហើយមានកូនម្នាក់ ហើយគេដឹកមកតាមទូក គេយកមកដាក់នៅកោះមួយ ហើយយោធាសម្លាប់ -- យោធានៅក្នុងកងវរសេនាធំ៦២ បានសម្លាប់នៅដើមដូងនៅក្រោមដើមដូង។ តើអ៊ីចឹង ហេតុការណ៍ហ្នឹង តើហេតុការណ៍កើតនៅកោះពូលូវ៉ៃ ឬក៏នៅកន្លែងណា?

**ឆ៖** បាទ ពិតប្រាកដណាស់ នៅកោះពូធីវ៉ៃ។

**ស៖** ប៉ុន្តែលោកក៏បាននិយាយថា លោកនិយាយថា នៅក្នុងឆ្នាំ១៩៧៥នោះ ក៏ទ័ពវៀតណាមវាយយកកាន់កាប់កោះពូលូវ៉ៃនោះរួចមកហើយ តើហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទត្រឹមត្រូវហើយបាទ។

**ស៖** អ៊ីចឹងបើពិនិត្យទៅ មិនអាចកើតឡើងបានទេ នៅក្នុងដើម -- នៅក្នុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ វាមិនអាចទៅរួចទេ ដែលថាទ័ពខ្មែរក្រហមយកគ្រួសារវៀតណាមមកសម្លាប់នៅនឹងកោះពូលូវ៉ៃនោះ ពីព្រោះកោះពូលូវ៉ៃនោះ ត្រូវបានវៀតណាមយកទៅវិញបាត់ហើយនោះ។ នេះបើតាមខ្ញុំស្តាប់សក្ខីកម្មលោក?

[១១:០៦:៣០]

**ឆ៖** រឿងរ៉ាវនេះខ្ញុំសូមជម្រាបថា មុននឹងសម្លាប់នេះ ឃើញថាវៀតណាមមិនទាន់យកកោះនោះបានទេ។ អូ៎!មុននឹង -- ខ្ញុំនឹកឃើញហើយបាទ -- ពេលដែលវៀតណាមយកកោះ បាទយកកោះនោះបានហើយ ពេលដែលវៀតណាមប្រគល់កោះនោះឱ្យមកកម្ពុជាវិញ បាទឱ្យមកកម្ពុជាវិញ គឺខ្ញុំ អង្គភាពរបស់ខ្ញុំទៅនៅកោះនោះផ្ទាល់តែម្តង ទៅនៅកោះពូធីវ៉ៃនោះ ខ្ញុំចេញពីកោះតាងហើយ។ បាទ ខ្ញុំចេញពីកោះតាង ទៅនៅកោះពូធីវ៉ៃ ដែលយួនបានដកទ័ពៗចេញពីកោះពូធីវ៉ៃនៅក្នុងពេលនោះ។ ពេលនោះសកម្មភាពដេញសម្លាប់ ដេញជនជាតិវៀតណាម ឪពុកម្តាយហ្នឹង និងកូនហ្នឹង គឺថា នៅពេលដែលអង្គភាពរបស់ខ្ញុំទៅដល់ៗកន្លែងនោះ។ បាទ សូមអរគុណ។ ហ្នឹង ខ្ញុំសូមជម្រាបអ៊ីចឹង។

[១១:០៧:៤៩]

**ស៖** ខ្ញុំសូមអានឯកសារជូនលោកគឺៗ សៀវភៅរបស់អ្នកកាសែតកម្ពុជា ឯកសារ E3/20 – សៀវភៅរបស់ អេលីហ្សាបេត បេកឃ័រ លោកប្រធាន – ទំព័រភាសាអង់គ្លេស 00237902 ដល់ទៅ 3, ខ្មែរ 00232263 ហើយបារាំង 00638464 ដែលនិយាយដូចខាងក្រោមនេះ៖ "កម្ពុជាបានសុំទោសអំពីហេតុការណ៍កើតឡើងនៅលើកោះ ដែលនិយាយថាមេបញ្ជាការនៅលើទីនោះ គឺមិនយល់ច្បាស់អំពីប្រវត្តិ អំពីភូមិសាស្ត្រ ហើយវៀតណាមក៏បានកាន់កាប់យកកោះពូលូវៃវិញ។" នេះសូមបញ្ចប់សេចក្ដីដកស្រង់។ សំណួរទី១របស់ខ្ញុំទៅលោកសាក្សី ថាតើត្រឹមត្រូវដែរឬទេ គឺមេបញ្ជាការកងពលលើមូលដ្ឋាននោះ គឺយល់ច្រឡំអំពីភូមិសាស្ត្រកោះពូលូវៃ ដែលថា យល់ថាជារបស់ខ្មែរទេ ជារបស់វៀតណាមទេ បានខ្លួនទៅវៃអ៊ីចឹង។ តើលោកអាចឆ្លើយដូចម្ដេចបាន?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមស្នើឲ្យមេធាវីបញ្ជាក់ពី ERN បាទ។ អ៊ីចឹងខ្ញុំមិនបានទទួលទំព័រទេ ប៉ុន្តែបាន ERN ។

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹង គឺទំព័រ 8 និង 9។

**អ្នកបកប្រែ៖**

បាទ 198 សូមកែតម្រូវ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងគឺខ្ញុំសួរសាក្សីថា តើមេបញ្ជាការលើមូលដ្ឋានហ្នឹង គាត់យល់ខុស យល់ច្រឡំអំពីទីតាំងភូមិសាស្ត្រដែរឬទេនៅពេលនោះ? លោកដឹងដែរឬទេពីរឿងនេះ?

**2-TCW-1000៖**

**ឆ៖** បាទ អត់បានដឹងដែរបាទ សូមអរគុណ។

**ស៖** ហើយការរឹបអូសកោះពូលូវៃ តើនៅក្នុងឆ្នាំ១៩៧៥អ៊ីចឹង ដែលលោកនិយាយថា៧៥ អ៊ីចឹងឬយ៉ាងណា?

**ឆ៖** ខ្ញុំត្រូវ--

**លោក នីកូឡាស គូមជែន៖**

គឺថាមានភាពច្របូកច្របល់បន្តិច គឺថាកោះនេះគឺត្រូវវៀតណាមរឹបអូសយកនៅក្នុងឆ្នាំ១៩៧៥។

**លោក វ៉ិចទ័រ កូប៉េ៖**

បញ្ហាគឺអ៊ីចេះទេលោកប្រធាន ខ្ញុំរួតសួរបន្តិច ដោយសារខ្ញុំមានពេលវេលាខ្លី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំព្យាយាមស្វែងយល់ឲ្យដឹងថាតើព្រឹត្តិការណ៍កើតមានឡើងនៅពេលណា ហើយតាមបទពិសោធន៍ ឬក៏តាមការចងចាំរបស់គាត់ ថាតើគាត់កងទ័ពវៀតណាមចាកចេញពីកោះនោះនៅពេលណាដែរ?

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំសូមជម្រាបថា ខ្ញុំអត់បាននៅចងចាំទេ ព្រោះកាលនុ៎ង ខ្ញុំវ៉ៃអាមេរិកាំងហើយនៅឆ្នាំ៧៥។ រំលងបានតែមួយខែ វៀតណាមបានមកវ៉ៃយកកម្ពុជានៅកោះៗពូធីវ៉ៃ។ នៅពេលនុ៎ងវ៉ៃរយៈប្រហែលជាកន្លះខែបានវាចាប់កងទ័ពយោធានៅលើកោះនោះទាំងអស់ ហើយចាប់បានរយៈបានរយៈបីខែ បាទបីខែបានវៀតណាមប្រគល់កោះនោះឲ្យមកវិញបាទ។ ប្រគល់កោះនោះឲ្យមកវិញ គឺខ្ញុំបានទៅនៅលើកោះនោះ នៅពេលនោះខ្ញុំបានដឹងច្បាស់ពិតប្រាកដរបស់ខ្ញុំមែន។ ខ្ញុំអត់ -- នេះជាការពិតរបស់ខ្ញុំ។

[១១:១១:៥៣]

**ស៖** ហើយព្រឹត្តិការណ៍ដែលលោកកំពុងរៀបរាប់កើតឡើងនៅពេលណា? ព្រឹត្តិការណ៍នេះកើតឡើងក្រោយពេលរឹបអូសកោះនោះបានមកវិញដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងណា?

**ឆ៖** បាទ អរគុណណាស់។ នៅក្នុងពេលនុ៎ង មិនមែនការប្រយុទ្ធគ្នាទៀតទេ អត់ទេ។ វរសេនាតូចរបស់ខ្ញុំប្រហែលជា៣០០នាក់ដែលគេចាប់យកទៅនោះ គឺបញ្ជូនទៅកោះត្រល់។ ក្រោយមកទៀតដែលការចរចាគ្នា អង្គការថ្នាក់លើបានចរចាគ្នាត្រូវ គេបញ្ជូនពួកកងរបស់ខ្ញុំហ្នឹងឲ្យវិលត្រឡប់មកវិញ ហើយខ្ញុំដែលខ្ញុំអត់បានជាប់នៅលើកោះនោះ គឺខ្ញុំនៅកោះតាង ក្រោយមកបានខ្ញុំទៅនៅកោះតាងនោះតែម្ដងៗនៅពេលនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន តើនៅពេលនេះ ខ្ញុំអាចផ្ដល់ពេលវេលានេះទៅឲ្យក្រុមមេធាវីការពារក្ដីក្រុម ខៀវ សំផន ហើយនៅពេលណាដែលក្រុមមេធាវីការពារក្ដី ខៀវ សំផន សួរហើយនៅសល់ម៉ោង ខ្ញុំនឹងសួរបន្ត ដោយសារថាខ្ញុំសំណួរច្រើនណាស់។ អ៊ីចឹងខ្ញុំសូមប្រគល់ពេលវេលាឲ្យគាត់ពេលនេះ បើសល់ម៉ោង

សូមខ្ញុំសួរបន្តទៅទៀត។

[១១:១៣:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក [redacted]។ ខ្ញុំឈ្មោះ គង់ សំអុន ជាសហមេធាវីជាតិរបស់លោក ខៀវ សំផន ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកបន្ត។ សំណួរដំបូងរបស់ខ្ញុំ គឺទាក់ទងទៅនឹងការងាររបស់លោកនៅកោះពូលូវៃ ដែលលោកទើបតែឆ្លើយបញ្ចប់អម្បាញ់មិញនេះ។ លោកបានបញ្ជាក់អម្បាញ់មិញថា លោកត្រូវរបួសនៅពេលដែលវាយគ្នានៅលើកោះតាងជាមួយពួកអាមេរិក ហើយរយៈពេលប្រហែលជាកន្លះខែក្រោយមក មានការប្រយុទ្ធគ្នាទៅលើកោះពូលូវៃទៀតជាមួយខាងវៀតណាមម្តង។ ហើយបីខែក្រោយមក ទើបខាងកងទ័ពវៀតណាមប្រគល់កោះពូលូវៃមកឲ្យការគ្រប់គ្រងរបស់ខ្មែរវិញ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**2-TCW-1000៖**

**ឆ៖** បាទ ពិតប្រាកដត្រឹមត្រូវមែនហើយលោក។ បាទ អរគុណ។

[១១:១៤:៥១]

**ប្រធានអង្គជំនុំ៖**

លោក១មេធាវី សូមរំឭកថា មិនគប្បីបញ្ចេញនាមត្រកូល និងនាមខ្លួនគាត់ទេ គឺប្រើរហស្សនាមគាត់មានរហស្សនាម [2-TCW-1000]។

**លោក គង់ សំអុន៖**

បាទ សូមអភ័យទោសលោកប្រធាន។ ខ្ញុំនឹងអនុវត្តបន្តទៀតនេះបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី នៅពេលដែលលោកទៅធ្វើការនៅកោះពូលូវៃ លោកចាំបានថាមេបញ្ជាការ

របស់លោកឈ្មោះអីដែរទេ?

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ មេបញ្ជាការរបស់ខ្ញុំ ក្រោយមកគឺឈ្មោះ តាសំណាង។ មុនឈ្មោះ បងយឺន តែក្រោយមកទៀតឈ្មោះ តាសំណាង ជាមេបញ្ជាការរបស់ខ្ញុំ ដែលនៅក្នុងវរសេនាតូច ៦២២ នោះ។ បាទអរគុណ។

[១១:១៦:០១]

**ស៖** បាទ សូមអរគុណ ហើយលោកនៅក្នុងទីតាំងកោះពូលូវ៉ៃហ្នឹងក្នុងរយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ឆ្នាំ៧៥ ពេលវាយអាមេរិកាំងហើយ និងវាយយួន អង្គភាពរបស់ខ្លួនវាយយួនហើយ ហើយនៅក្នុងឆ្នាំ៧៥ដែរ ខ្ញុំបានទៅនៅលើកោះនោះរយៈរហូតដល់ឆ្នាំ៧៧។ បាទ ៧៧ បានអង្គការដកឲ្យខ្ញុំមកនៅខាងកងនាវាជើងទឹកវិញ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាច្បាស់ជាងនេះបន្តិចបានទេថា ឆ្នាំ ១៩៧៧ ហ្នឹងជាពេលដើម ចុងឆ្នាំ ឬក៏ខែណាតាមដែលលោកអាចចាំបាន?

**ឆ៖** បាទ នៅក្នុងដើមឆ្នាំ៧៧ បានពាក់កណ្ដាលឆ្នាំហើយៗ ក្នុងខែ៣ -- ខែ៤ ខែ៥ហើយបានខ្ញុំមកនៅនាវា ខាងនាវាជើងទឹកហ្នឹង ៧៧ហ្នឹង។ បាទ ដកចេញពីកោះៗពូធីវ៉ៃមក បានអង្គការឲ្យខ្ញុំមកនៅខាងនាវាជើងទឹក និងខាងកប៉ាល់វិញ។ បាទ អរគុណ។

**ស៖** បាទ សូមអរគុណ។ សម្រាប់លោកផ្ទាល់ ក៏ដូចជាក្នុងកងរបស់លោកការងារប្រចាំថ្ងៃរបស់លោកធ្វើអីដែរនៅក្នុងពេលនុ៎ង?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំអង្គាល់នៅឆ្នាំ៧៥ នៅខាងកោះពូធីវ៉ៃហ្នឹង ខ្ញុំបាទការកន្លងហើយដែលការខ្វះខាត ដែលការណ៍ដែលគេលែងទុកចិត្តខ្ញុំ ខ្ញុំមានការកងសាងខ្លួនបានល្អ បានល្អហើយខ្ញុំក៏អង្គការមានជំនឿជឿជាក់ហើយ។ ខ្ញុំជាយុទ្ធជនមួយរូបដែលល្អនៅក្នុងក្របខ័ណ្ឌនៅក្នុងអង្គភាពនោះបានគេដកមកហើយនៅខាងនាវាជើងទឹកខាងកប៉ាល់តែម្ដង។ បាទ អត់មានការងារមុខងារអីទេ។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

លោកប្រធានសូមអនុញ្ញាតប្រគល់ឯកសារ E319/23.3.12 ដើម្បីសួរសាក្សីបញ្ជាក់ទៅលើ

ឈ្មោះដែលបានផ្តល់សក្ខីកម្មលើឯកសារនេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី សូមលោកអានខ្សឹបៗនៅក្នុងចិត្តខ្លួនឯង ហើយមិនបាច់បញ្ចេញសំឡេងពីឈ្មោះរបស់សាក្សីម្នាក់នេះទេ។ លោកស្គាល់ឈ្មោះ កន្លែងដែលខ្ញុំគូសពណ៌ពីលើនេះទេ?

**2-TCW-1000៖**

**ឆ៖** បាទ សូមអរគុណណាស់។ ខ្ញុំជម្រាបលោកថាឈ្មោះទាំងអស់នេះដែលខ្ញុំអត់បានស្គាល់ទេពិតប្រាកដដែលខ្ញុំអត់បានស្គាល់។

**ស៖** បាទ លោកៗសាក្សី លោកអានឈ្មោះហ្នឹងដាច់ទេ? ឬមួយក៏លោកមិនអាចអានបានទេលោក បើលោកៗមិនអាចអានបានទេ សូមឲ្យមេធាវីរបស់លោកជួយអានឈ្មោះឲ្យលោកស្តាប់។

**ឆ៖** បាទ អរគុណណាស់។ ឈ្មោះ [redacted]នេះ ខ្ញុំអត់ៗបានស្គាល់ពិត។

**ស៖** លោកមិនបានហៅឈ្មោះនេះទេ ហើយលោកពិនិត្យឲ្យច្បាស់តាមអ្វីដែលលោកអានអម្បាញ់មិញនេះ គឺអត់ត្រូវឈ្មោះហ្នឹងទេ ដូច្នេះសូមឲ្យលោកមេធាវីជួយៗប្រាប់ឈ្មោះផងបាទ។

**ឆ៖** បាទ អត់ៗស្គាល់ទេ បាទអរគុណ។

[១១:២១:៣៥]

**ស៖** បាទ សូមអរគុណ។ នៅក្នុងសក្ខីកម្មរបស់សាក្សីម្នាក់នេះ គាត់បានឆ្លើយបញ្ជាក់ទៅលើវត្តមានរបស់កងទ័ពវៀតណាមនៅលើកោះពូលូវៃនោះដែរ ហើយជាក់ស្តែងនៅក្នុងចម្លើយទី១០ ខ្ញុំសូមអានជូនលោកប្រធាន៖ "អង្គភាពរបស់ខ្ញុំគឺមានភារកិច្ចការពារឃ្លាំងប្រាក់នៅកំពង់សោម។ អង្គភាពរបស់ខ្ញុំគឺវរសេនាតូចលេខ៤៥០ មានយោធាប្រហែល៥០០នាក់ (សូមទោស៤៥០) ហើយមាន៤៥០ទៅ៥០០នាក់"។ ខ្ញុំ សំណួរ-ចម្លើយទី១១ លោកឆ្លើយថា៖ "វរសេនាតូចលេខ៤៥០ ហៅថាកងពិសេសក្រោយមកកងពិសេសរបស់ខ្ញុំត្រូវបានបែងចែកទៅជាកងការពារនៅកំពង់ផែ និងកម្លាំងជាង២០០នាក់ត្រូវបានបញ្ជូនឲ្យទៅការពារកោះពូលូវៃ ព្រោះនៅពេលនោះ វៀតណាមបានចូលមកកាន់កាប់កោះ។ នៅពេលនោះខ្ញុំមានតួនាទីជាអនុប្រធានអនុសេនាធំលេខ៤ វរសេនាតូច៤៥០ និងកងពល១៦៤។" បាទ លោកបានបញ្ជាក់អំពីការបញ្ជូនកងទ័ពវៀតណាម -- សូមទោសការបញ្ជូនកងយោធាទៅកាន់កោះពូលូវៃ

ដើម្បីទៅដណ្ដើមយកកោះពូលូវ៉ៃនោះមកវិញ។ តើនៅក្នុងពេលនោះលោកជាសមាជិកម្នាក់ចេញពីកំពង់សោម ឬក៏លោកចេញពីកន្លែងផ្សេងតាមអ្វីដែលលោកមានប្រសាសន៍បាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ដើម្បីជាប្រតិចារឹក សំណួរនេះគឺថាមានភាពច្របូកច្របល់ក្នុងការសម្រាប់ប្រតិចារឹកនេះណាស់។ តាមខ្ញុំឮគឺថាវៀតណាមបានរឹបអូសកោះនេះភ្លាមៗក្រោយថ្ងៃរំដោះ ហើយក៏ដកកងទ័ពទៅវិញនៅក្នុងរយៈពេលប៉ុន្មានសប្ដាហ៍ក្រោយមក។ ដូច្នេះសំណួរនេះគឺច្របូកច្របល់ ពីព្រោះគាត់ បើសាក្សីបានឆ្លើយថាកងទ័ពវៀតណាមបានដកចេញទៅវិញក្នុងរយៈពេលពីរបីខែក្រោយមក។

[១១:២៤:៣១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារតែមានភាពច្របូកច្របល់ មានភាពខ្វែងគ្នាដូច្នេះហើយ ទើបខ្ញុំលើកសំណួរនេះតាំងសួរទៅសាក្សី ដើម្បីឲ្យឆ្លើយបញ្ជាក់ទៅលើភាពខ្វែងគ្នាបែបនេះបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យសួរ ហើយអាចរៀបចំសំណួររបស់លោកឡើងវិញ លោកមេធាវីទំនងជាសាក្សីភ្លេចហើយ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកសាក្សី លោកអាចឆ្លើយនឹងសំណួរនេះបានទេ?

**2-TCW-1000៖**

**ឆ៖** បាទ រឿងនេះ ជារឿងពិតប្រាកដមួយដែលខ្ញុំបានអនុវត្តជាក់ស្ដែងនៅក្នុងវរសេនាធំរបស់ខ្ញុំតាំងពីឆ្នាំ៧៥ រហូត។ ខ្ញុំចេញពីកោះ បាទចេញពីកោះតាង – ចេញពីកោះតាង ដែលយួនដកចេញទៅហ្នឹងទៅកោះពូធីវ៉ៃហ្នឹង មិនមែនខ្ញុំ មិនមែនខ្ញុំចេញពី៤៥០ បួនអី មិនមែនទេ។ វរសេនាតូច៤៥០ផ្សេង។ វរសេនា៤៨០ផ្សេង។ វរសេនាធំ៤១០ផ្សេង។ អ៊ីចឹង ជាវរសេនាធំ៦២២នេះ ជាវរសេនាធំទទួលខុសត្រូវកោះតាង កោះពូធីវ៉ៃចាស់ និងកោះពូធីវ៉ៃថ្មី។ នេះខ្ញុំសូមបញ្ជាក់ឲ្យច្បាស់នៅក្នុងវរសេនាធំរបស់ខ្ញុំដែល

ទទួលបីកោះ បាទបីកោះ។ អ៊ីចឹង ខ្ញុំមិនមែនថា ចេញពីកំពង់ផែ ឬមួយចេញពីដីគោកទេ ក្នុងវៀតណាមដកទ័ព ប្រហែលជារយៈបីខែហើយ បានបញ្ជូនកងខ្ញុំវរសេនាធំនៅក្នុងវរសេនាធំ៦២ហ្នឹង មួយអនុសេនាធំទៅនៅលើកោះពូធីវ៉ៃវិញ។ បាទ ហើយក្រោយមក ដែលយុទ្ធជនដែលវៀតណាមចាប់បាននោះ បានជញ្ជូនមកដល់កំពង់សោម ហើយអង្គការរៀបចំបញ្ជូនកងនោះឲ្យទៅនៅជាមួយគ្នានៅក្នុងកោះពូធីវ៉ៃវិញ។ បាទសូមអរគុណ។ ខ្ញុំសូមជម្រាបដោយពិតប្រាកដ។

[១១:២៦:៣៨]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបន្ថែមទាក់ទងទៅនឹងពេលវេលា ពីព្រោះអម្បាញ់មិញនេះ លោកនិយាយថាកងទ័ពវៀតណាមបានដកចេញពីកោះពូលូវ៉ៃហ្នឹងបីខែ បានបញ្ជូនលោកទៅនៅលើកោះពូលូវ៉ៃនោះ។ ហើយពីមុនមកលោកបានបញ្ជាក់ថា កងទ័ពវៀតណាមបានកាន់កាប់កោះពូលូវ៉ៃបីខែ។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកបញ្ជាក់នូវពេលវេលាឲ្យច្បាស់លាស់ ថាតើកងទ័ពវៀតណាមបានកាន់កាប់រយៈពេលបីខែនៅលើកោះពូលូវ៉ៃនោះ ហើយបីខែក្រោយមកទៀត ក្រោយពីការដកចេញរបស់កងទ័ពវៀត-ណាមពីកោះពូលូវ៉ៃនោះ បានក្រុមលោកទៅកាន់នៅកោះពូលូវ៉ៃនោះ ឬមួយយ៉ាងម៉េច លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ឆ៖** បាទ ពិតប្រាកដណាស់ ខ្ញុំបានចេញពីនៅ -- ចេញពីកោះតាងទៅនៅកោះពូធីវ៉ៃនោះ បាទទៅកោះពូធីវ៉ៃដែលវៀតណាមដកចេញភ្លាម គឺទៅនៅភ្លាមតែម្ដង បាទ។

**ស៖** អ៊ីចឹង មិនមានន័យថាបីខែក្រោយ ទើបក្រុមរបស់លោក កងរបស់លោកបានទៅនៅកោះពូលូវ៉ៃទេ តើអ៊ីចឹងទេ?

**ឆ៖** បាទ អរគុណណាស់។ មិនមែនថាវៀតណាមដកបីខែហើយបានទៅនៅទេ គឺវៀតណាមយកកាន់កាប់បានតែបីខែ។ បីខែហ្នឹងហើយគឺវៀតណាមដក។ ដកគឺកងរបស់យើងខ្ញុំទៅនៅតែម្ដង។ បាទ អត់មានពន្យារពេលបីខែក្រោយទៀតទេ។ បាទ សូមអរគុណ។

[១១:២៨:២៤]

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលលោកទៅដល់កោះពូលូវ៉ៃនោះ តើលោកបានឃើញកងទ័ពវៀតណាម ឬក៏ជនជាតិវៀតណាមនៅលើកោះនោះដែរទេ?

**ឆ៖** បាទ ខ្ញុំទៅដល់នៅលើកោះនោះ អត់មានទេ អត់មានវៀតណាមនៅអីទេមួយទេ មានតែផ្ទះដែលវាសាងសង់ បាទមានតែសាងសង់នៅលើកោះហ្នឹងទេ ហើយវៀតណាមក៏ដកចេញថ្មីៗហ្នឹងដែរ

ពិតប្រាកដមែន។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងការចាប់ខ្លួនវៀតណាម។ លោកបាននិយាយអំពីការចាប់ខ្លួនជនជាតិវៀតណាមនេះ អំពីវិធានការខុសគ្នាលើការជនជាតិ -- ការចាប់ខ្លួនជនជាតិវៀតណាមជាស៊ីវិល ហើយនិងយោធា។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើមានការណែនាំទាក់ទងទៅនឹងការចាប់ខ្លួនជនជាតិវៀតណាមជាស៊ីវិលនិងជាយោធា ដែលឆ្លងកាត់នៅក្នុងតំបន់សមុទ្រខ្មែរនោះដែរទេ ជាពិសេសទីតាំងដែលលោកធ្វើការនោះ?

[១១:៣០:០០]

**ឆ៖** បាទ អរគុណណាស់ ដោយយើងខ្ញុំជាអ្នកកងការពារនៅផ្ទៃសមុទ្រព្រំដែនកោះ បាទ ទាំងកោះតាង កោះពូធីវៃចាស់ ទាំងកោះពូធីវៃថ្មី។ យោធាទាំងអស់គឺថានៅការពារលើកោះ គឺឲ្យតែអ្នកចូលទឹកដីកម្ពុជា គឺចាប់ទាំងអស់។ ដោយបញ្ជាគឺដាច់ខាតត្រូវតែចាប់ ឲ្យតែចូលទឹកដីកម្ពុជា។ បាទ សូមអរគុណណាស់ សូមជម្រាបជូន។

**ស៖** បាទ ខ្ញុំសូមទុកសំណួរនេះសិន ហើយនិងសួរទៅចំណុចមួយទៀតទាក់ទងទៅនឹងសាក្សីម្នាក់ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានប្រគល់ឯកសារនេះដើម្បីបញ្ជាក់ទៅលើឈ្មោះរបស់សាក្សីនោះជាមួយនឹងសាក្សីរូបនេះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត!

**លោក គង់ សំអុន៖**

បាទ ឯកសារគឺ E319/23.3.21។ បាទ លោកសាក្សីដូចមុនដែរ លោកមិនបាច់ហៅឈ្មោះសាក្សីនេះទេ ហើយសូមលោកមេធាវីជួយអានឈ្មោះផង។

**2-TCW-1000៖**

**ឆ៖** បាទ ឈ្មោះនេះ ខ្ញុំអត់ស្គាល់ដែរបាទ។

[១១:៣២:១៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ សាក្សីរូបនេះគាត់បានលើកពីការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យជាមួយនឹងកងទ័ពវៀតណាម នៅតំបន់កោះក្រចកសេះ ហើយនិងកោះពូលូវៃនេះដែរ។ តើ

លោកមានចាំព្រឹត្តិការណ៍ដែលកើតឡើងដោយឡែកនៅកោះក្រចកសេះទេ?

**ឆៈ** បាទ អរគុណណាស់។ ខ្ញុំសូមជម្រាបសម្ដែងនូវការស្មោះត្រង់ កោះក្រចកនេះ គឺខ្ញុំ ឆ្នាំ៧៥ បានអង្គការបញ្ជា បាទបានបញ្ជាឲ្យខ្ញុំទៅ។ ទៅហ្នឹងមិនមែននេះទេ ឆ្នាំ៧៥ ដែលពេលរំដោះហើយហ្នឹង អាហ្នឹងជាដំបូងទេ គេបញ្ជាទៅ ខ្ញុំទៅ។ កោះក្រចកសេះនេះជាកោះរបស់វៀតណាមពិតប្រាកដ បាទ ទៅដល់ គេហៅថាកោះប៉ូឡូវ៉ាន់សង់ បាទ កោះប៉ូឡូវ៉ាន់សង់ កោះក្រចកសេះជាកោះរបស់វៀតណាម។ ខ្ញុំទៅដល់កន្លែងនោះ ឃើញសុទ្ធតែជាជនជាតិវៀតណាម ក៏ខ្ញុំ គេបញ្ជាឲ្យវិលត្រឡប់មកនៅកោះតាង -- កោះវិញ បាទមកកោះពូឃីវ៉ៃ មិនមែនទៅប្រយុទ្ធគ្នានៅពេលនោះ អត់មានដែលទៅប្រយុទ្ធទេ។ សូមអរគុណ។

**សៈ** បាទ ខ្ញុំសូមឲ្យលោកបញ្ជាក់ថា នៅក្នុងតួនាទីរបស់លោក លោកមិនដែលទៅប្រយុទ្ធទេ ឬមួយក៏មានន័យថា មិនដែលមានការប្រយុទ្ធរវាងយោធាកម្ពុជា និងកងទ័ពវៀតណាមនៅលើកោះក្រចកសេះនោះទេ?

[១១:៣៤:០៩]

**ឆៈ** ព្រឹត្តិការណ៍កើតឡើងដែលនៅប្រយុទ្ធហ្នឹង មិនមានទេ អត់មានទេ កោះក្រចកសេះ អត់មានដែលប្រយុទ្ធអីទេ អត់មានដែលទៅ បាទគ្រាន់តែទៅមើល មើលហើយបាទ ដឹងថាជនជាតិរបស់គេហើយ ក៏វិលត្រឡប់មកវិញ បើថាប្រយុទ្ធគ្នា វ៉ៃគ្នាអី គឺកងណាក៏អត់មានទៅវ៉ៃដែរ កោះនោះនៅឆ្ងាយពីកោះពូឃីវ៉ៃ បាទ ឆ្ងាយដែរ ខ្ញុំប្រហែលវាមិននៅចងចាំទេ ជិះកប៉ាល់ប្រហែលជាបី បួន ប្រាំម៉ោងដែរបានដល់។ បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ បើខ្ញុំកត់លេខឯកសារដែលផ្ដល់ជូនសាក្សីហ្នឹង គឺឯកសារហ្នឹងមិនទាន់បានទទួលយកដោយអង្គជំនុំជម្រះនៅឡើយទេ។ វាស្ថិតនៅក្នុងសំណើរបស់លោក ខៀវ សំផន ដែលត្រូវជជែកពិភាក្សាគ្នានៅថ្ងៃស្អែក។ ហើយយើងនឹងមកទាល់ពេលនេះ យើងអត់ទាន់ទទួលបានការបកប្រែនៅឡើយទេ។ ដូច្នេះ ខ្ញុំរង់ចាំឲ្យមានការបកប្រែឯកសារសិន។ ខ្ញុំអត់មានឯកសារហ្នឹងទេ គឺ E319/23.3.21 ដែលមេធាវី គង់ សំអុន បានលើកឡើង ហើយបាន

ប្រគល់ជូនសាក្សីនេះ គឺជាឯកសារមួយដែលស្ថិតនៅក្នុងចំណោមឯកសារថ្មីដែលត្រូវដាក់បង្ហាញ ហើយដែលមានដាក់បញ្ជូននៅក្នុងសំណើរបស់មេធាវីលោក ខៀវ សំផន ដែលត្រូវពិភាក្សាគ្នានៅពេលក្រោយ។ តើវាជាករណីអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានផ្សព្វផ្សាយនូវដីកាសម្រេចផ្ទាល់មាត់កាលពីព្រឹកមិញ លើសំណើសុំប្រើប្រាស់ឯកសារទាំងបួនពីសំណុំរឿង០០៣ របស់មេធាវីការពារក្ដី ខៀវ សំផន រួចហើយ។ មានន័យថាអង្គជំនុំជម្រះអនុញ្ញាតហើយព្រឹកមិញ។ អង្គជំនុំជម្រះបញ្ជាក់ច្បាស់ណាស់ ពីព្រោះថាពេលវេលាដែលត្រូវសួរដេញដោលដោយមេធាវីចំពោះសាក្សី[2-TCW-1000]នេះ គឺត្រូវធ្វើនៅព្រឹកនេះ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះប្រញាប់ប្រញាល់ក្នុងការផ្សព្វផ្សាយនូវសេចក្ដីសម្រេចនោះមុន។ ចំណែកឯសំណើដែលលើកទៅធ្វើការដេញ ពិភាក្សាស្ដាប់សារណារបស់ភាគីពាក់ព័ន្ធនឹងសំណើមួយរបស់មេធាវីការពារក្ដី នួន ជា និងសំណើពីររបស់សហព្រះរាជអាជ្ញា។ នេះដូចច្បាស់លាស់ហើយ។ ហើយក្រុមមេធាវីការពារក្ដី ខៀវ សំផន មានតែកំណត់ហេតុស្ដាប់សក្ខីកម្មស្ដាប់សាក្សីពីសំណុំរឿងផ្សេងនោះ មកនោះ គឺមានតែបួនទេ ហើយអង្គជំនុំជម្រះសម្រេចទទួលយករួចហើយ ព្រោះភាគីពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ មិនបានតវ៉ាអីទេ បញ្ជាក់ច្បាស់លាស់នៅក្នុងសេចក្ដីសម្រេចព្រឹកមិញរួចហើយ។

បាទ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ និងបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី មុនពេលសម្រាកយើងបានជជែកគ្នាអំពីការប្រយុទ្ធជាមួយកងទ័ពវៀតណាម ហើយយើងបានជជែកអំពីការវាយគ្នានៅលើកោះពូលូវៃ។ ខ្ញុំចង់សួរសំណួរលោកបន្ថែមទាក់ទងទៅនឹងការណែនាំរបស់ថ្នាក់លើរបស់លោក ថាតើមានការណែនាំមកដល់លោកជាយុទ្ធជនហ្នឹង ដើម្បីទៅរករឿងដល់ប្រទេសវៀតណាម ឬក៏កងទ័ពវៀតណាមដែរទេ ក្នុងពេលដែលលោកធ្វើការកងនាវិកនោះ?

**2-TCW-1000៖**

**ឆ៖** បាទ អរគុណណាស់។ ក្រោយពីរំដោះនៅឆ្នាំ៧៥ហើយ កងទ័ពជាភារកិច្ចអ្នកការពារនៅទឹកដីព្រំដែនកោះ នៅសមុទ្រ។ គឺថាអត់មានការណែនាំអប់រំទៅវាយនៅវៀតណាម ឬមួយទៅអីទេអត់មានទេ គ្រាន់តែការពារ តែបើមានវៀតណាមមានអីក៏ដោយចូលមកទឹកដីកម្ពុជាគឺថា មានការទប់ស្កាត់មានការវាយគ្នា។ អ៊ីចឹងការណែនាំឲ្យទៅវាយគេគឺគ្មានទេ ក្នុងពេលបច្ចុប្បន្ននុ៎ង។ បាទ អរគុណ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការចូលរបស់ទូកវៀតណាម ឬក៏ទូកបរទេសផ្សេងទៀតនៅលើទឹកដីសមុទ្ររបស់កម្ពុជាក្នុងពេលនោះ តើលោកមានដែលជួបប្រទះទូកនេសាទរបស់វៀត-ណាមដែលអមដោយកងការពារដែលមានប្រដាប់អាវុធនៅលើទូក ការពារទូកនេសាទទាំងអស់នោះដែរទេ?

[១៣:៣៦:៣៩]

**ឆ៖** បាទ អរគុណណាស់។ នៅលើផ្ទៃសមុទ្រដែលយើងខ្ញុំបាននៅការពារនៅលើកោះនុ៎ងពេលកប៉ាល់នេសាទត្រីរបស់ថៃដែលចូលមកកម្ពុជា គឺថាមិនដែលមានអាវុធទេ។ បាទ អត់មានដែល

អាវុធ មានអាវុធទេក្នុងពេលបច្ចុប្បន្ននោះ។ បាទ អរគុណ។

**ស៖** បាទ សំណួររបស់ខ្ញុំទាក់ទងទៅនឹងទូកនេសាទរបស់ខាងវៀតណាមវិញ។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ អរគុណណាស់។ នៅក្នុងឆ្នាំនោះដែរ ពេលទូកវៀតណាមៗដែលចូលមកទឹកដីកម្ពុជា ខ្លះមាន ខ្លះមានអាវុធ តែខ្លះទៀតអត់មានទេ មានតែមងមានតែអីធម្មតា ខ្លះមានអាវុធត្រឹមកាំភ្លើងអឹមសី ឬមួយអាកាតែប៉ុណ្ណោះទេ ប៉ុន្តែអត់មានកាំភ្លើងច្រើនទេ មានមួយដើម ឬពីរដើមតែប៉ុណ្ណឹងទេ។

**ស៖** បាទ សូមអរគុណ។ លោកដឹងដោយរបៀបណា?

**ឆ៖** មូលហេតុដែលដឹងដោយក្នុងអង្គភាពរបស់ខ្លួនទៅធ្វើសកម្មភាព។ បើវៀតណាមចូលមកក៏ដោយ ថៃចូលក៏ដោយ ឲ្យតែចូលទឹកដីកម្ពុជាគឺថា ត្រូវតែដេញចាប់តែម្តង តែបើចាប់ ហើយមានកាំភ្លើងបាញ់ត ច្បាស់តែលិចហើយក្នុងពេលនោះ។ បាទ សូមអរគុណ។

[១៣:៣៨:៤១]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមអានសក្ខីកម្មរបស់សាក្សីដែលមានលេខ E319/23.3.21 ត្រង់សំណួរចម្លើយលេខ២១។ ខ្ញុំសូមដកស្រង់៖ “សម្រាប់យើង រឿងដែលសំខាន់ដំបូង ផែនការរួមគឺការពារប្រទេសទី១។ ទី២ គឺការកងសាងប្រទេស។ ការណែនាំធ្វើឲ្យការការពារប្រទេសមានន័យថា យើងត្រូវតែស្ថិតនៅលើកោះជានិច្ច មិនត្រូវបោះបង់កោះទេ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ បើសិនជាយើងឃើញមានកប៉ាល់ចម្បាំងចូលមកក្នុងដែនទឹកយើង យើងត្រូវតែរាយការណ៍មកខាងកងពលដើម្បីឲ្យគេធ្វើអន្តរាគមន៍។ ប៉ុន្តែសម្រាប់កាណូតតូចៗចាប់ពី២០សេះ ទៅដល់ ៤០០សេះ ក្នុងនាមខ្ញុំដែលជាមេបញ្ជាការលើកោះ គឺខ្ញុំទទួលខុសត្រូវក្នុងការសម្រេចទប់ទល់ជាមួយកាណូតទាំងនេះ។ នៅនឹងកាណូតរបស់ខ្ញុំគឺមានដេកា៨២មិល្លីម៉ែត្រ និងកាំភ្លើងយន្ត ៣០មិល្លីម៉ែត្រផង។ ខាងកាណូតវៀតណាមដែលធ្លាប់ចូលមកក្នុងទឹកដីយើងនោះ គឺគេមានកាំភ្លើងដូចជា បេ៤០ជាដើម។ ពេលខ្លះមានកាណូត ១០ គ្រឿង ឬច្រើនជាងនេះទៅទៀត បានចូលទៅដែនទឹកយើង ក្នុងចំណោមនោះកាណូតខ្លះ គឺសម្រាប់ការពារកាណូតនេសាទរបស់ពួកគេ។”

បាទ លោកសាក្សី ក្រោយពីបានស្តាប់ការដកស្រង់របស់សក្ខីកម្មរបស់សាក្សីម្នាក់ដែលខ្ញុំបានជម្រាបជូនលោករួចហើយនេះ តើលោកមានការឆ្លើយតបយ៉ាងម៉េចទៅនឹងសក្ខីកម្មនេះដែរទេ?

**ឆ៖** បាទ រឿងរ៉ាវអស់ទាំងនេះ ខ្ញុំបានក្តាប់ដឹង ព្រោះជាមុខខុសគ្នា ខុសនឹងវរសេនាធំនីមួយៗ

បាទ។ វរសេនាធំរបស់ខ្ញុំ ខាងប៉ែកខាងកោះពូធីវ៉ៃ គឺថាមិនដែលបានជួបប្រទះទេ តែមុខរបស់គេគឺមាន បាទ ក្នុងអង្គភាពរបស់គេ វរសេនាធំខុសគ្នា។ អ៊ីចឹងព្រឹត្តិការណ៍ដែលកើតឡើងខុសៗគ្នានេះ គឺថាមានៗ តែរហូត អត់ចេះៗដូចគ្នាទេ។ អ៊ីចឹងមុខខ្ញុំឃើញអ៊ីចេះ មុខខាងវរសេនាធំនោះឃើញអ៊ីចុះ ឃើញខុសគ្នា ទាំងអស់ ប៉ុន្តែរាយការណ៍ទៅខាងលើដូចតែគ្នា។ បាទ អរគុណណាស់។

[១៣:៤១:៥២]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសក្ខីកម្មរបស់លោក កាលពីថ្ងៃទី១៦ ខែធ្នូ កន្លងទៅ លោកបានបញ្ជាក់នៅម៉ោងប្រហែល ១០:៣៩:០៤ លោកបានបញ្ជាក់ថា៖ “ក្នុងពេលនោះ ឆ្នាំ៧៧ ឃើញថា ខ្ញុំបានឃើញម្តងឬពីរដងដែរ ប៉ុន្តែក្រោយៗមកឃើញថាមិនមានសកម្មភាពអីធ្វើបាបទៅលើ ផែទេ ឃើញថាមកដល់ផែនេះហើយ ហើយនេះឃើញថាគេភាគច្រើនៗឡានគេមកជញ្ជូនចេញយកទៅ ក្រុងកំពង់សោមតែម្តង។” ហើយបន្តមកទៀតក៏មានការតាំងសំណួរទាក់ទងទៅនឹងសក្ខីកម្មរបស់លោក ជាពិសេសត្រង់ឯកសារ E319/23.3.46 ត្រង់សំណួរចម្លើយលេខ១០ ដែលលោកមានបញ្ជាក់ថា៖ “មនុស្សដែលគេចាប់បាន គឺមានចំនួនរាប់ពាន់នាក់បើតាមខ្ញុំដឹង ហើយក្នុងមួយខែៗគេបញ្ជូនមនុស្សតាម ផែអូរឈើទាលច្រើនជាងពីបួនទៅប្រាំដង។” អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកបានឃើញការ ចាប់ ឬក៏នាំខ្លួនជនជាតិវៀតណាមតាមទូកហ្នឹង នៅនឹងភ្នែករបស់លោកហ្នឹងប៉ុន្មានករណី? ហើយចំនួន ប៉ុន្មានជាក់ស្តែងដែលលោកបានឃើញផ្ទាល់?

**ឆ៖** បាទ ពិតប្រាកដណាស់ ដែលខ្ញុំឃើញព្រឹត្តិការណ៍ដែលកើតឡើងពេលចាប់ម្តងៗ ឃើញ ថាមានៗដូចខ្ញុំរៀបរាប់ពីខាងដើមហើយ។ បាទ ហ្នឹងអត់និយាយ អត់មានភូតភរកុហកដល់អង្គការអន្តរ ជាតិ អង្គការថ្នាក់ជាតិទេ ព្រោះរឿងរ៉ាវទាំងអស់នេះគឺមានពិតប្រាកដ បញ្ជូនទៅតាមផែអូរឈើទាល ដើម្បីឡានមកដឹក យកមកក្រុងកំពង់សោមបាទ ខ្លះទៀតក៏យកទៅខាងអូរត្រេះ យកទៅខាងចម្ការដូង បាទ ច្រើនកន្លែងដែរ ព្រោះក្នុងមួយខែៗ គឺថាចាប់ៗរហូត ឆ្នាំ៧៧ហ្នឹង ៧៨ហ្នឹង ចាប់ខ្លាំងបាទ។

**ស៖** បាទ សូមអរគុណ។ លោកសាក្សី បញ្ហានៅត្រង់នេះ គឺថាចម្លើយរបស់លោកវាមានភាព ផ្ទុយគ្នា។ ចម្លើយមួយលោកថា លោកឃើញតែចាប់ពីរបីករណីទេក្នុងមួយឆ្នាំ។ ហើយចម្លើយមួយទៀត លោកថាលោកឃើញដល់ទៅរាប់ពាន់នាក់ ហើយបីបួនដងក្នុងមួយខែ។ ដូច្នេះ វាមានភាពផ្ទុយគ្នាបែប នេះ ដែលខ្ញុំចង់ឲ្យលោកបញ្ជាក់ ថាតើចម្លើយណាដែលលោកបានឃើញពិតប្រាកដ ហើយអ្វីដែលលោក ដែលខ្ញុំសួរលោកនេះ គឺការបានឃើញនឹងភ្នែករបស់លោក។ លោកអាចបញ្ជាក់បានទេ?

**ផ៖** ខ្ញុំសូមបញ្ជាក់ប្រាប់ ជាពិតដែលខ្ញុំនៅលើផែ ផែអូរឈើទាល ដំណាក់ស្ដេចនេះ គឺថាពីរបីដងក៏ពិតមែនបាទ ហើយឃើញជាក់ស្ដែងនិងការចាប់បញ្ជូន។ តែចាប់ដែលដឹកតាមទឹកដែលយើងខ្ញុំបានឃើញជាក់ៗស្ដែងនឹងភ្នែករបស់ខ្ញុំ ព្រោះខ្ញុំនៅបើកបរខាងកប៉ាល់នេសាទត្រីដែរ ពេលនោះឃើញគេចាប់បាន គឺគេចាប់បញ្ជូនមកតាមរយៈហ្នឹង ហ្នឹងជាការពិតរបស់ខ្ញុំដែលខ្ញុំបានឃើញពិតប្រាកដមែន។

[១៣:៤៦:១៦]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាជាក់លាក់ ពីពេលដែលថាលោកថាលោកធ្វើការនេសាទត្រីហ្នឹងបានទេ? លោកបានបញ្ជាក់ខាងដើមរួចមកហើយថា នៅពេលដែលមានសង្គ្រាមជាមួយសហរដ្ឋអាមេរិកនៅលើកោះពូលូវៃនោះ -- (សូមទោស) កោះតាងនោះ លោកបានត្រូវរបួស ហើយលោកទទួលការព្យាបាល។ អ៊ីចឹងខ្ញុំចង់ដឹងថា រយៈពេលដែលលោកព្យាបាលនោះ ប៉ុន្មានខែប៉ុន្មានឆ្នាំដែរ ហើយពេលណាទើបលោកត្រឡប់មកចូលអង្គភាពដើម្បីការងារបន្តទៀតវិញ?

**ផ៖** បាទ អរគុណណាស់។ ខ្ញុំពេលធ្វើសកម្មភាពប្រយុទ្ធគ្នានៅលើកោះនោះ ខ្ញុំបានរបួសត្រគៀកនេះ សម្រាកពេទ្យបានតែកន្លះខែទេ ខ្ញុំវិលទៅនៅអង្គភាពវិញ។ បាទអរគុណ។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលលោកមកនៅអូរឈើទាល លោកអាចបញ្ជាក់ពីពេលវេលាច្បាស់លាស់ទេថា លោកចាប់ផ្ដើមនៅផែអូរឈើទាលហ្នឹងក្នុងឆ្នាំណា ខែណា?

**ផ៖** នៅក្នុងឆ្នាំ៧៧ ប្រហាក់ប្រហែលជាខែ៤ ខែ៥ហើយបាទ ខ្ញុំអត់ចងចាំទេ ព្រោះពេលវេលាហ្នឹង។ ពេលនោះខ្ញុំនៅហ្វឹកហ្វឺនបច្ចេកទេសនៅសាលានៅហ្នឹង នៅផែអូរឈើទាលហ្នឹង។ បាទខ្ញុំភ្លេចខែហើយ បាទអរគុណ។

[១៣:៤៨:៣៥]

**ស៖** លោកអាចបញ្ជាក់ពីអំឡុងពេលបានទេថា រយៈពេលប៉ុន្មានខែ ឬប៉ុន្មានឆ្នាំនៅក្នុងផែអូរឈើទាលនោះ?

**ផ៖** បាទ ខ្ញុំនៅហ្វឹកហ្វឺននៅផែអូរឈើទាលហ្នឹងបានចំនួនប្រហែលជាមួយខែៗ។ ដល់ខែក្រោយបានខ្ញុំទៅហាត់ ទៅរៀនៗបច្ចេកទេសនៅកោះរុង។ ទៅដល់កោះរុង ខ្ញុំទៅហ្វឹកហ្វឺននៅសាលានោះហើយ បានខ្ញុំត្រឡប់មកនៅដំណាក់ស្ដេច។ ដំណាក់ស្ដេចហ្នឹងក៏នៅ ហើយនិងអូតែលសុខាហ្នឹង ក៏នៅ បាទនៅពីរកន្លែងហ្នឹង គឺថាខ្ញុំចល័ត។ ដោយសារចល័ត ដោយសារជានីរសាររបស់វរសេនាធំនៅខាងជើងទឹកហ្នឹង អ៊ីចឹងខ្ញុំចល័តចុះឡើង ដឹកជញ្ជូនសម្ភារៈចុះឡើងនៅតាមកំពង់ផែ។ បាទ អរគុណ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងសវនាការកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំហ្នឹង -- សូមទោស ឆ្នាំមុន ម៉ោង ១០:៥៧:៥៥ លោកបានឆ្លើយនៅក្នុងសវនាការនេះថា សូមដកស្រង់៖ “អ្នកដែលគ្មានអាវុធនោះ ឃើញថាគេចាប់បញ្ជូនទៅផែអូរឈើទាលដើម្បីយកទៅកន្លែងមន្ទីរកងពលបាទ តែអ្នកដែលខ្ញុំនិយាយថាឆ្នាំ៧៦ ដែលខ្ញុំមិនទាន់ចូលនៅកងវរសេនាធំ១៤០នេះ ពេលដែលខ្ញុំនៅក្នុងកងពល”។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកឃើញការចាប់បញ្ជូនមនុស្ស ជាពិសេសជនបរទេសពីដែនទឹកមកកំពង់ -- មកផែអូរឈើទាលហ្នឹង នៅពេលដែលលោករៀន ឬក៏ក្នុងអំឡុងពេលណាមួយ លោកអាចបញ្ជាក់បានទេ?

**ឆ៖** នៅក្នុងទម្រង់នុំង ខ្ញុំបាទរៀនវគ្គបិទហើយ ចប់ហើយ។ អ៊ីចឹងខ្ញុំនៅខាងនីរសាររបស់វរសេនាធំ។ អ៊ីចឹងខ្ញុំនៅបើកបរដឹកជញ្ជូនជាសម្ភារៈភ័ស្តុភារដែលទៅតាមកោះ ទៅតាមនាវា ហើយអ៊ីចឹងរយៈពេលហ្នឹង ខ្ញុំនៅយូរខែរហូតដល់ឆ្នាំ ទាល់រហូតដល់វៀតណាមចូល ៧៩តែម្តងបាទ។

[១៣:៥១:៤៦]

**ស៖** អ៊ីចឹងបានន័យថាលោកបានឃើញគេបញ្ជូនមនុស្សពីសមុទ្រមកហ្នឹង ចូលមកផែអូរឈើទាលហ្នឹងជាប្រចាំ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ក្នុងនុំងវាបញ្ជូនមកក្នុងរយៈពេលខែទើបតែខែ -- ឆ្នាំ៧៧, ៧៨ ពាក់កណ្តាលឆ្នាំហ្នឹងគឺថា ឃើញថាបាត់អត់ឃើញបញ្ជូនមកទេ ប៉ុន្មានខែមុន គឺគេបញ្ជូនមកបន្តបន្ទាប់។ ពេលសភាពការណ៍ដែលប្រែប្រួលនៅក្នុងប្រទេស ឃើញថា អត់ដែលឃើញទៀតទេ អត់ដែលឃើញបញ្ជូនមកទៀតទេ។ អាហ្នឹងជិតដល់ខែវៀតណាមចូលហើយ ជិតដល់ឆ្នាំវៀតណាមចូលមកហើយ អត់ដែលឃើញបន្តទៀតទេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E319/23.3.12 ដែលខ្ញុំបានជូនទៅលោករួចហើយ ត្រង់សំណួរចម្លើយលេខ៦៦ សាក្សីរូបនោះបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “[...] នៅពេលខ្លះយោធាខ្មែរក្រហមដែលប្រចាំការនៅតាមកោះចាប់ទូកបាន ហើយបញ្ជូនទូកទៅនោះទៅរាម ដោយមិនបញ្ជូនមកផែកំពង់សោមទេ។ ខ្ញុំសូមបញ្ជាក់ផងដែរថា ផែអូរឈើទាលជាកន្លែងដែលអ្នកជំនាញចិនបណ្តុះបណ្តាលកម្លាំងយោធាជើងទឹកខ្មែរក្រហម ដូច្នេះ គេមិនឱ្យកប៉ាល់ធម្មតាចូលចតនៅទីនោះទេ។ ផែនៅរាម គឺជាផែអន្តរជាតិដែលមានកប៉ាល់ទូទៅអាចចេញចូលបាន។” សូមចប់ការដកស្រង់។ ខ្ញុំចង់សួរថាលោកមានប្រតិកម្មយ៉ាងម៉េចចំពោះសក្ខីកម្មរបស់សាក្សីរូបនេះ ដែលបញ្ជាក់ថា ផែអូរឈើទាលជាកន្លែងបណ្តុះ

បណ្ដាល ដែលមានអ្នកជំនាញចិននៅទីនោះ ហើយមិនអនុញ្ញាតឲ្យកប៉ាល់ធម្មតាចុះចតនៅទីនោះទេបាទ?

[១៣:៥៤:១៩]

**ឆ៖** រឿងរ៉ាវនេះ ខ្ញុំសូមជម្រាបថា នៅផែរាម ផែរាមក៏ភាគច្រើនយកទៅ ក៏យកទៅច្រើនដែរ។ ចាប់ថៃ គឺភាគច្រើនយកទៅហ្នឹង ចាប់យួនក៏យកទៅហ្នឹង។ នៅផែអូរឈើទាលនេះក៏ជាអ៊ីចឹង។ នេះជាការពិត ដែលខ្ញុំបានឃើញជាក់ស្ដែងនឹងភ្នែករបស់ខ្ញុំ ដែលគេចាប់បានហើយធ្វើទារុណកម្មនៅលើផែក៏មាន។ បាទ សូមអរគុណ។

**ស៖** បាទ ចុះទាក់ទងនឹងសំណួររបស់ខ្ញុំ ដែលខ្ញុំស្នើសុំថាលោកមានប្រតិកម្មយ៉ាងម៉េច ចំពោះសាក្សីម្នាក់ដែលបាននិយាយថា ផែននៅអូរឈើទាលនេះ មិនអនុញ្ញាតឲ្យមានផែ -- ឲ្យមានកប៉ាល់ ឬក៏ទូកណាចូលចតទេ ពីព្រោះជាកន្លែងដែលហ្វឹកហ្វឺនយោធាជើងទឹករបស់ខ្មែរក្រហម។ តើលោកឆ្លើយតបដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ប្រហែលជាមកពីបញ្ហាបកប្រែហើយមើលទៅ ដោយសារថាមេធាវីការពារក្ដីនិយាយញាប់ពេក។ បើទៅតាមការបកប្រែនេះ គឺវាបញ្ច្រាស់ពីអ្វីដែលសាក្សីនិយាយនៅក្នុងសម្រង់នេះ។ ប្រហែលជាមេធាវីការពារក្ដីត្រូវអានជាថ្មីម្ដងទៀត។ សាក្សីនិយាយថាមានចិននៅអូរឈើទាល ហើយគឺថាទីនោះមិនមែនជាកំពង់ផែអន្តរជាតិនោះទេ។ វាខុសពីអ្វីដែលមាននៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ។

[១៣:៥៦:២៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ខ្ញុំអាចសង្ខេបជូនខ្លឹមសារដែលខ្ញុំបានអានអំមិញ។ គឺនៅកំពង់ផែអូរឈើទាល គឺជាកន្លែងហ្វឹកហ្វឺនយោធាជើងទឹក។ ឯកំពង់ផែអន្តរជាតិនោះគឺនៅរាមទេ បាទ។ អ៊ីចឹងលោកសាក្សី លោកអាចស្ដាប់បានចម្លើយនេះ ការដកស្រង់របស់ខ្ញុំអម្បាញ់មិញនេះទេ? ហើយលោកមានប្រតិកម្មឆ្លើយតបទៅនឹងសក្ខីកម្មនេះយ៉ាងដូចម្ដេចដែរ?

2-TCW-1000៖

**ឆ៖** បាទ អរគុណណាស់ខ្ញុំមិនជំទាស់អីទេ រឿងរ៉ាវអស់ទាំងនេះ។ គឺផែនៅ ផែអូរឈើទាលនេះ ក៏មិនមែនជាផែអន្តរជាតិដែរ។ ផែនេះគឺថា ជាធម្មតាចេញចូល ហើយក៏គ្មានចិននៅលើផែនេះដែរ អត់នៅនឹងគល់ផែដំណាក់ស្ដេចនេះ គ្មានទេ។ ចិនគឺនៅតែក្រុង។ នៅម៉ាកន្លែងដែរ នៅខាងផ្នែកអូតែលសុខា។ អាហ្នឹងមានម៉ាកន្លែងហ្នឹងទេ ហើយនៅរាម នៅផែអូរឈើទាលនេះ គ្មានទេ។ អ៊ីចឹង កប៉ាល់នេះឃើញថា កប៉ាល់ចម្បាំងក៏អត់មានចូលចតនៅទីនោះដែរ។ កប៉ាល់នៅរាមក៏អត់ដែរ។ នេះជាការពិតដែលខ្ញុំ -- ហើយក៏អត់ជំទាស់នូវសាក្សីបានបំភ្លឺពីមុន ពីផែយោធា ជាផែអន្តរជាតិ គឺថាមិនទាន់ប្រកាសថា ផែណាមួយទេ អត់ទាន់បានប្រកាសទេក្នុងនោះ។ បាទ សូមអរគុណ។

[១៣:៥៨:០៦]

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងជោគវាសនារបស់អ្នកដែលត្រូវបានចាប់ខ្លួន។ ខ្ញុំចង់សួរលោកថា ឆ្លើយនឹងសំណួររបស់សហមេធាវីដើមបណ្ដឹងប្បវេណី លោកបានលើកអំពីបទបញ្ជាដែលថា ករណីដែលមានមនុស្សចំនួនតិចតួច គឺគេសម្លាប់ចោលតែម្ដង ហើយតើលោកជាអ្នកទទួលបញ្ជានេះ ហើយត្រូវទទួលពីអ្នកណា លោកអាចបញ្ជាក់បានទេ ដែលថាការចាប់ខ្លួន ឧទាហរណ៍ជនជាតិវៀតណាមនៅតាមកោះដែលមានគ្នាតិចសម្លាប់ចោលនៅនឹងកន្លែងនៅនឹងកោះហ្នឹង។ លោកទទួលបញ្ជាពីណាមក?

**ឆ៖** ខ្ញុំបានសូមជម្រាបពីខាងដើមហើយ គឺខណៈជាយោធានៅក្រោមការដឹកនាំរបស់ខាងលើគឺថាមិនហ៊ានធ្វើឲ្យខុសច្បាប់ទេ។ ទាល់តែបញ្ជាពីខាងលើ។ បញ្ជាពីវរសេនាតូចរបស់ខ្លួន និងបញ្ជាវរសេនាធំ មកវរសេនាតូច និងតាមជាន់ថ្នាក់ខាងក្រោមអាចមានលទ្ធភាពបានហ៊ានធ្វើ។

**សៈ** បាទ លោកសាក្សី សំណួររបស់ខ្ញុំចង់ឲ្យលោកឆ្លើយជាក់លាក់ទៅលើបុគ្គល មានឈ្មោះមនុស្ស ឬក៏តួនាទីច្បាស់លាស់។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា បញ្ជាពីលើមក មកវរសេនាតូច បាទ វរសេនាតូចបានបញ្ជាឲ្យយោធាធ្វើ ធ្វើសកម្មភាព។ បើចាប់បានតិចគឺសម្លាប់ចោល អាហ្នឹងហ៊ានធ្វើហើយ។ បើថាអត់ពីខាងលើមកគឺមិនហ៊ានធ្វើទេ ហើយបញ្ជាការរបស់ខ្លួនហ្នឹង គឺឈ្មោះ បងសំណាង អ៊ីចឹងទៅ បាទបងសំណាងគាត់មេបញ្ជាការវរសេនាតូចអ៊ីចឹង។ បើគាត់បញ្ជាមក គឺយោធារបស់កងរបស់គាត់ គឺថាធ្វើហើយបាទនេះបានទទួលបញ្ជារបស់គេអ៊ីចឹង។

[១៤:០០:៣៩]

**ស៖** បាទ សូមអរគុណ។ ចុះឈ្មោះសំណាងនេះ ជាមេបញ្ជាការវរសេនាតូចរបស់លោកផ្ទាល់ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បងសំណាងជាបញ្ជាការនៃវរសេនាតូចរបស់ខ្ញុំ ពិតប្រាកដ បាទ។

**ស៖** ហើយគាត់ជាអ្នកបញ្ជាឲ្យលោកសម្លាប់ចោលនូវអ្នកដែលចាប់បានៅលើកោះ នៅតាមសមុទ្រ កាលណាបើមានគ្នាតិច គឺសម្លាប់នៅហ្នឹងកន្លែង តើអ៊ីចឹងមែនទេ?

**ឆ៖** តាមការឆ្លងកាត់របស់ខ្ញុំ ខ្ញុំមិនមែនអ្នកបានសម្លាប់អីទេ ប៉ុន្តែក្នុងអង្គភាពរបស់ខ្ញុំ ឃើញថា តែបញ្ជាពីគាត់មកហើយ គឺត្រូវតែធ្វើ ត្រូវតែសម្លាប់បាទ។ បើចាប់បានពេញ គឺម្នាក់ ពីរនាក់ គឺសម្លាប់សម្លាប់ចោលនៅលើកោះ និងនៅលើទឹកហើយ។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា លោកសំណាង អតីតមេបញ្ជារបស់លោកហ្នឹងនៅឯណាឥឡូវនេះ?

**ឆ៖** បាទ អរគុណ។ មេបញ្ជារបស់ខ្ញុំ បងសំណាង នោះគឺថាខ្ញុំបែកគាត់តាំងពីឆ្នាំ៧៧ ពេលដែលគេចាត់តាំងឲ្យខ្ញុំមកនៅកង -- កប៉ាល់ មកនៅកប៉ាល់មក។ គឺថាខ្ញុំបែកពីគាត់រហូតដល់សព្វថ្ងៃនេះ មិនដែលជួបប្រទះគាត់ទេ។ មិនដឹងគាត់រស់នៅកន្លែងណា ឬមួយក៏គាត់សម្លាប់ក៏មិនដឹងដែរ បែកបាត់យូរហើយ។

[១៤:០២:៣៨]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីកាលៈទេសៈបែបណា ក្នុងស្ថានភាពយ៉ាងណា បានជាលោក សំណាង បញ្ជាឲ្យក្រុមរបស់លោកហ្នឹងកម្ទេចអ្នកដែលចាប់បាននៅលើកោះ កាលបើមានគ្នាតិចហ្នឹង?

**ឆ៖** បាទ រឿងរ៉ាវអស់ទាំងនេះឃើញថា តាមការរាយការណ៍ពី ស្តាប់ការណែនាំរបស់វរសេនាតូច គឺថាបញ្ជាមកពីវរសេនាធំ។ វរសេនាធំថា ម្នាក់ ពីរនាក់--

**ស៖** សូមទោសលោកសាក្សី។ ខ្ញុំសួរលោកឲ្យបញ្ជាក់ពីកាលៈទេសៈ ឬក៏ស្ថានភាពក្នុងព្រឹត្តិ-ការណ៍អ្វីដែលលោកបានទទួលការបញ្ជាបែបនេះ ជាការប្រជុំ ឬក៏ជាការណែនាំបែបណាក្នុងស្ថានភាពអាចបញ្ជាក់ពីទីតាំង ទីកន្លែង ឬក៏ពេលវេលា លោកអាចបញ្ជាក់បានទេជុំវិញបញ្ជានេះ ការបញ្ជានេះ?

**ឆ៖** កន្លងមក ឃើញថានៅក្នុងអំឡុងហ្នឹង ឃើញថាមានជាការណែនាំ ណែនាំអប់រំប្រជុំបាទ បើគ្នាតិច អាហ្នឹងយើងសម្លាប់ចោល កាលណាបើដឹកទៅវិញ វាខាតបាទ វាខាតនៅក្នុងពេលនោះ។

អ៊ីចឹងគម្រោងរបស់គេ គឺថាបើគ្នាតិច អាហ្នឹងសម្លាប់នៅលើកោះ និងលើទឹកហ្នឹងហើយ មិនបាច់យកទៅឲ្យខាងអីទេ--

[១៤:០៤:៣៧]

**ស៖** បាទ ខ្ញុំស្ដាប់យល់ហើយ ខ្ញុំជឿថាអង្គជំនុំជម្រះក៏ស្ដាប់យល់ចំណុចនេះដែរ ក៏ប៉ុន្តែសំណួររបស់ខ្ញុំទាក់ទងទៅនឹងព្រឹត្តិការណ៍នៃការបញ្ជាហ្នឹងក្នុងហេតុការណ៍ណា? ជាការប្រជុំ ប្រជុំហ្នឹងយ៉ាងម៉េចក្នុងទីតាំងកន្លែងណា មានការណែនាំ ឬក៏ការចូលរួមពីអ្នកណាខ្លះ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនដោយស្មោះ។ នៅក្នុងអំឡុងនុ៎ង គឺថាច្បាប់វិន័យរឹងតឹងណាស់ បាទ រឹងតឹងណាស់ ធ្វើអ្វីក៏ដោយដល់តែប្រជុំ។ ប្រជុំ គឺថាម៉ឺងម៉ាត់តែម្ដង បាទ។ បើឲ្យសម្លាប់ សម្លាប់។ អ្នកមិនសម្លាប់ហ្នឹង សម្លាប់ខ្លួនឯងឥឡូវហើយ។ អាហ្នឹងជាបញ្ជាផ្ដាច់ការតែម្ដង គឺថាអត់មានហៅថា ហ្ន៎! បញ្ជាហើយ ឬមួយប្រជុំប្រាប់ហើយ មិនអនុវត្តគោលនយោបាយនោះ គឺថាមិនបានទេ អាហ្នឹងជាការពិតប្រាកដ និងប្រជុំទៅតាមវរសេនាតូច វរសេនាតូច គឺផ្សព្វផ្សាយដល់យោធាទាំងអស់នៅក្នុងអង្គភាព បាទ។ នេះជាពិតប្រាកដ។

**ស៖** បាទ លោកសាក្សី ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់។ តើការប្រជុំដែលលោកថាទទួលបញ្ជាឲ្យសម្លាប់ កាលណាបើចាប់បានមនុស្សតិចសម្លាប់នៅកន្លែងហ្នឹង ជាការប្រជុំនៅក្នុងក្រុម ឬក្នុងកង ឬក៏ជាការប្រជុំយ៉ាងម៉េច? លោកអាចបញ្ជាក់ឲ្យច្បាស់ខ្លីបានទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់។ ជាការពិតណាស់ ពេលដែលប្រជុំ គឺថាប្រជុំជាវរសេនាតូច ជាផែនការរួមនៃវរសេនាតូច។ ហើយវរសេនាតូចហ្នឹង គេថាគេផ្សព្វផ្សាយពីខាងលើមកហើយ អ៊ីចឹងគឺធ្វើត្រឹមវរសេនាតូច។ ហ្នឹងជាការពិតនៃៗការប្រជុំ គឺច្បាស់តែម្ដង អ្វីក៏ដោយ គឺមិនប៉ានទេ។

[១៤:០៦:៥៨]

**ស៖** បាទ សូមអរគុណ។

**ឆ៖** បាទ។

**ស៖** លោកដែលចូលរួមប្រជុំដែលដឹកនាំដោយវរសេនាធំទេ ទាក់ទងទៅនឹងបញ្ហាដែលយើងនិយាយគ្នានេះ?

**ឆ៖** ទេ ខ្ញុំអត់ៗដែលទេ បាន -- អត់ដែលបានចូលរួមប្រជុំជាមួយវរសេនាធំទេ គ្រាន់តែ បាទ ចូលរួម រួមប្រជុំ នឹងជាកងវរសេនាតូច បាទ។

**ស៖** បាទ សូមអរគុណ។

**ឆ៖** បាទ។

**ស៖** ចុះទាក់ទងទៅនឹងការប្រជុំកងពល លោកដែលបានចូលរួមក្នុងអង្គប្រជុំកងពលដែរទេ ទាក់ទងទៅនឹងបញ្ហាដែលយើងកំពុងជជែកគ្នាហ្នឹង?

**ឆ៖** បាទ អរគុណណាស់។ ក្នុងតួនាទីឋានៈជាយុទ្ធជន មិនដែលបានចូលរួមប្រជុំដល់ធំៗ កន្លែងកងពលទេ បាទ។ សូម្បីតែកន្លែងវរសេនាធំហ្នឹង ក៏មិនបានចូលរួមប្រជុំផង បាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការដែលលោកនិយាយអំពីថា វៀតណាមជាសត្រូវស្លូតបូត។ លោកចាំបានទេថា មានការណែនាំ ឬការបង្រៀននៅទីកន្លែងណាដែរ ដែលអប់រំ ឬក៏បង្រៀនលោកថាវៀតណាមជាសត្រូវស្លូតបូតនោះ?

[១៤:០៩:00]

**ឆ៖** បាទ អរគុណណាស់។ រឿងរ៉ាវអស់ទាំងនេះ ខ្ញុំសូមជម្រាបបញ្ជាក់ច្បាស់។ រឿងសត្រូវស្លូតបូត វៀតណាមនិងកម្ពុជា គឺបានទទួលនូវៗការរៀនសូត្ររយៈមួយថ្ងៃ ពីរថ្ងៃ។ បាទ គឺសត្រូវស្លូតបូតវៀតណាមនិងកម្ពុជា គឺថាអត់មានល្អនឹងគ្នាទេ គឺសត្រូវស្លូតបូតតែម្តង ព្រោះរឿងរ៉ាវទាំងនេះ គឺយើងខ្ញុំនៅចងចាំរហូត អត់មានបំភ្លេចបាន។

**ស៖** បាទៗ សូមអរគុណ។ លោកបានបញ្ជាក់រួចហើយនូវចំណុចនេះ ប៉ុន្តែសំណួររបស់ខ្ញុំ ខ្ញុំចង់សួរអំពីទីកន្លែងនិងពេលវេលា ថាតើលោករៀនសូត្រនៅកន្លែងណា? ហើយនៅពេលណា? លោកអាចឆ្លើយឱ្យខ្លីមក ពេលវេលារបស់ខ្ញុំប្រហែលជាខើចដែរហើយ។

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំបានស្តាប់ គឺវគ្គសិក្សានៅកោះ បាទ នៅកោះ ដោយគេទទួលផែនការហើយបានចុះទៅផ្សព្វផ្សាយនៅកោះអ៊ីចឹងទៅ។ អ៊ីចឹងសិក្សានៅសាលា នៅកោះ ទៅតាមវរសេនាតូច។ បាទ អរគុណ។

**ស៖** កោះឈ្មោះអីដែរ? លោកអាចបញ្ជាក់បាន?

**ឆ៖** កោះពូធីវៃ បាទ កោះពូធីវៃ។

**ស៖** កោះពូធិវៃ ប៉ុប្ញ? ខ្ញុំបានស្តាប់សក្ខីកម្មរបស់លោកកន្លងមកមានប្រើពាក្យថា កោះពូធិវៃ ហើយកោះពូធីវៃ ហើយមានការហៅខ្លះថា កោះពូលូវៃ។ អ៊ីចឹងលោកអាចបញ្ជាក់មើល តើវាជាឈ្មោះតែមួយ ឬក៏មានកោះផ្សេងៗគ្នា?

**ឆ៖** បាទ ជាការពិតណាស់គឺថា កោះនេះកោះតែមួយទេ។ ខ្លះគេហៅពូធិវៃ ខ្លះហៅពូធីវៃ បាទ ខ្លះហៅកោះវៃ។ ប៉ុន្តែការពិតកោះនេះតែមួយទេ។ បាទ គ្រាន់តែមួយកោះពូធីវៃចាស់ មួយកោះពូធីវៃថ្មី។ កោះពីរហ្នឹង គឺកោះឈ្មោះតែមួយ។ បាទ សូមអរគុណ កោះតែមួយ។

**ស៖** បាទ សូមអរគុណ។ តើពេលដែលលោកនិយាយអំពីការហ្វឹកហ្វឺននៅកោះពូលូវៃហ្នឹង គឺនៅពេលដែលកងទ័ពវៀតណាមបានដកចេញពីកោះនោះ ហើយលោកបានទៅឈរជើងនៅទីនោះក្រោយមកទៀត ឬមួយក៏នៅពេលណា? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំជម្រាបបញ្ជាក់ហើយថាពេលដែលវៀតណាមដក់ទ័ពចេញទៅ ខ្ញុំទៅឈរនៅលើកោះនោះ បាទ នៅលើកោះពូធីវៃនោះតែម្តង។

**ស៖** បាទ សូមអរគុណ។ ហើយនៅពេលនោះមានសង្គ្រាមទេ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម ហើយនិងកងទ័ពកម្ពុជាទេ នៅពេលដែលលោកសិក្សាអំពីខ្លឹមសារថា វៀតណាមជាសត្រូវស្លូពូជរបស់កម្ពុជា?

**ឆ៖** នៅក្នុងឆ្នាំនុំងគ្មានទេ គេមិនដែលប្រយុទ្ធគ្នាទេ។ ពេលរៀនសូត្រហើយ ជាវៀតណាមថាសត្រូវស្លូពូជហ្នឹង គឺក៏មិនដែលប្រយុទ្ធគ្នា មិនដែលវៃគ្នាដែរ។ មានតែជួរព្រំដែនខាងដីគោកទេ ដែលគេវៃគ្នាបាទ ខាងទឹកអត់មានទេ។ បាទ អរគុណ។

[១៤:១២:៤៤]

**ស៖** បាទ សូមអរគុណ។ លោកចាំបានថា អ្នកណាជាមេបញ្ជាការរបស់លោក ឬក៏ជាអ្នកណែនាំលោក បង្រៀនលោកពីកម្ពុជានិងវៀតណាមជាសត្រូវស្លូពូជហ្នឹងដែរទេ?

**ឆ៖** រឿងរ៉ាវអស់ទាំងនេះគឺថា សត្រូវស្លូពូជហ្នឹងគឺ បើតាមជាការក្តាប់របស់ខ្ញុំ ហើយជាការពិតរបស់ខ្ញុំឃើញថា ផ្សព្វផ្សាយនឹងការពិតនៅក្នុងអង្គភាពវរសេនាតូច តែផ្សព្វផ្សាយដែលខាងក្រៅ គឺចេញពីកន្លែងមន្ទីរកងពលមក។ ឃើញថា សត្រូវស្លូពូជអ៊ីចឹងហ្នង បាទជាផ្សព្វផ្សាយទូទាំងប្រទេសអ៊ីចឹងហ្នង។

**ស៖** បាទ លោកសាក្សី សំណួររបស់ខ្ញុំគឺ ខ្ញុំសួរថា នរណា ឈ្មោះអី បុគ្គលណា ជាអ្នកអប់រំលោក ឬក៏ជាមេបញ្ជាការលោកដែលបានណែនាំលោកអំពីកម្ពុជា និង វៀតណាមជាសត្រូវស្លូពូជនឹងគ្នានោះ លោកស្គាល់ឈ្មោះគេទេ?

**ឆ៖** បាទ អរគុណណាស់ គឺថាបញ្ជាការរបស់ខ្ញុំជាវរសេនាតូចហ្នង។ ការណែនាំអប់រំ បាទ។

អប់រំវៀតណាមជាសត្រូវស្លូពូជ សត្រូវទី១នៃកម្ពុជា។

**ស៖** ឈ្មោះ?

**ឆ៖** ឈ្មោះ លោក សំណាង បាទ លោក សំណាង។

**ស៖** លោកជាអ្នកចូលរួមរៀនសូត្រដោយផ្ទាល់ ឬមួយក៏គ្រាន់តែមានការណែនាំ និយាយរបៀបតៗគ្នាទេ?

**ឆ៖** ជាការពិតណាស់ ខ្ញុំបានរៀនសូត្រផ្ទាល់និងជាការណែនាំផ្ទាល់ពីបញ្ជាការ។ បាទអរគុណ។

[១៤:១៥:០៣]

**ស៖** ខ្ញុំចង់សួរបញ្ជាក់ថា តើលោក សំណាង ដែលជាមេបញ្ជាការរបស់លោកជាអ្នកបង្រៀនលោក -- ជាអ្នកបង្រៀន ឬមួយក៏មានអ្នកផ្សេងទៀត?

**ឆ៖** អរគុណណាស់។ ខ្ញុំបានទទួលនូវផែនការដែលការបង្រៀននៃការស្តាប់នូវផ្នែកនយោបាយអប់រំរបស់វរសេនាតូចរបស់ខ្ញុំ ឃើញថា មានជំនួយការជាវរសេនាធំៗនៃការចូលរួម។ មិនមែនថាម្ចាស់ការក្នុងការធ្វើទេ។ អ៊ីចឹងមានវរសេនាធំ មានអនុៗមកចូលរួម ក្នុងការផ្សព្វផ្សាយពីរឿងរ៉ាវអស់ទាំងនេះបាទ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំចង់បញ្ជាក់អំពីពេលវេលាដែលលោកនៅកោះពូលូវៃ។ ថាតើលោកនៅទីនោះក្នុងរយៈពេលប៉ុន្មាននៅក្នុងកោះពូលូវៃហ្នឹង? ហើយខ្ញុំចង់ផ្តោតទៅលើការរៀនរបស់លោកនៅនឹងកោះពូលូវៃហ្នឹងរៀនដែលនិយាយអំពីថា កម្ពុជាវៀតណាមជាសត្រូវស្លូពូជហ្នឹងនៅក្នុងពាក់កណ្តាលដំបូងដែលលោករស់នៅ ឬមួយក៏ក្នុងអំឡុងពេលណាមួយដែលអាចថាពេលចាប់ផ្តើមដំបូង ឬក៏ពេលចុងក្រោយនៃការស្នាក់នៅក្នុងកោះពូលូវៃហ្នឹង?

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំនៅកោះពូធីវៃពេលធ្វើសកម្មភាពអាមេរិកហើយ ខ្ញុំទៅនៅកោះពូធីវៃហ្នឹងរហូតដល់នៅឆ្នាំ១៧៧។ ឆ្នាំ៧៧ហ្នឹង ក្នុងខែ១៤ ខែ៥ ហើយហ្នឹង បានខ្ញុំចេញពីកោះនោះមកនៅខាងនាវាកប៉ាល់។

**ស៖** បាទ អំមិញសំណួរទី២របស់ខ្ញុំ ទាក់ទងទៅនឹងពេលវេលាដែលលោករៀនអំពីថា កម្ពុជាវៀតណាមជាសត្រូវស្លូពូជហ្នឹងក្នុងអំឡុងពេលណា?

**ឆ៖** បាទ ដើមឆ្នាំ៧៧ គឺថា បានបើកវគ្គសិក្សាផ្សព្វផ្សាយពេញទំហឹងតែម្តងនៅក្នុងអង្គភាពរបស់ខ្ញុំ ក្នុងឆ្នាំ៧៧។ បាទ អរគុណ។

**សះ** លោកអាចបញ្ជាក់ម្តងទៀតបានទេ ក្រែងលោខ្ញុំមិនបានចាប់លោកទាន់ថាលោកសំណាងហ្នឹងគាត់មានតួនាទី ឬឋានៈជាអ្វីដែរ? ជាមេបញ្ជាការរបស់លោកហ្នឹងក្នុងឋានៈជាអ្វី?

**ធះ** បាទ បងសំណាង គឺគាត់ប្រធានស្នងការនយោបាយសម្រាប់ផ្សព្វផ្សាយ។ អ្វីៗគឺថា គឺគាត់អ្នកទទួលហើយ និងផ្សព្វផ្សាយ គឺគាត់ប្រធាននយោបាយ បាទ បងសំណាង។

[១៤:១៨:៥៩]

**សះ** នយោបាយនៅក្នុងផ្នែកអី? ក្នុងកងតូច កងធំ ឬក៏ក្នុងវរៈណាមួយ លោកអាចបញ្ជាក់ពីឋានៈ ឬតួនាទីរបស់គាត់ទេ?

**ធះ** បាទ បងសំណាង គាត់ប្រធាននៃវរសេនាតូច គឺប្រធាននៃវរសេនាតូចជាតួនាទីរបស់គាត់ដែលប្រធានហ្នឹងតែម្តង។ ប្រធានទេ នៅក្នុងអង្គភាពរបស់ខ្ញុំវរសេនាតូច។

**សះ** បាទ សូមអរគុណ។ លោកមានបានចូលរួមវគ្គហ្វឹកហ្វឺនទៅលើខ្លឹមសារស្រដៀងគ្នានេះជាមួយនឹងថ្នាក់លើផ្សេងទៀត។ ឧទាហរណ៍ក្នុងវរសេនាធំ ឬក្នុងកងពល លោកដែលបានចូលរួមរៀនសូត្រទេ?

**ធះ** បាទ ខ្ញុំមិនដែលបានចូលរួមរៀនសូត្រ ប្រជុំដល់កម្រិតខ្ពស់ៗទេ បាទៗ អស់ហើយត្រឹមអនុសេនាធំ និងវរសេនាតូច តែប៉ុណ្ណឹង។ បាទ មិនដែលបានចូលរួមនៅអង្គវរៈ ប្រជុំធំៗទេ បាទ សូមជម្រាបអ៊ីចឹង។

**សះ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសង្គ្រាមមួយជាមួយសហរដ្ឋអាមេរិក លោក ខ្ញុំស្តាប់លោកបានពីព្រឹកមិញ នៅម៉ោងប្រាំបួនសាមសិបប្រាំនាទី លោកនិយាយថា គេចាប់ៗនាវិកនៅក្នុងកប៉ាល់ម៉ាយ៉ាហ្គេស ហើយមិនទាន់បញ្ជូនទៅវិញទេ ហើយត្រូវទាហានអាមេរិកាំងវ៉ៃ។ ហើយនៅក្នុងសក្ខីកម្មមួយនៅក្នុងចម្លើយមួយរបស់លោក នៅក្នុងឯកសារ E3/9092, ត្រង់ ERN ជាភាសាខ្មែរ 00955499, ភាសាបារាំង 00980438, ភាសាអង់គ្លេស 00978570។ ខ្ញុំសូមដកស្រង់ លោកឆ្លើយថា៖ "បាទ លែងឲ្យទៅវិញ ដល់ហើយវាឡើងលើកប៉ាល់វារួចរាល់អស់ហើយ វាវាយយើងតាមយន្តហោះ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើសក្ខីកម្មណាមួយពិតប្រាកដលោកអាចបញ្ជាក់បានទេ?

**ធះ** បាទ ក្នុងពេលហ្នឹងខ្ញុំជម្រាបបាន។ ពេលវេលាដែលអាមេរិកាំង ដែលគេលែងជនជាតិដែលដឹកទៅដីគោកនោះមកវិញ បាទ បញ្ជូនមកវិញ មកវិញមកដល់កប៉ាល់ម៉ាយ៉ាហ្គេសហ្នឹង គឺថា

សមាជិកនៅលើកប៉ាល់ហ្នឹង ឃើញថាឡើងលើកប៉ាល់ហ្នឹងទាំងអស់ ឡើងហើយកប៉ាល់ហ្នឹងក៏បើកចេញទៅ ក៏បើកចេញទៅ ម៉ាយ៉ាហ្គេសហ្នឹងក៏បើកចេញទៅ។ ពេលដែលគេចេញទៅ គឺថាសកម្មភាពដែលយន្តហោះវាយទម្លាក់គ្រាប់បែកមកលើកោះតាងនោះយ៉ាងខ្លាំង រហូតដល់ម៉ោងប្រាំពីរយប់បាទប្រាំពីរយប់ បានអស់ បានអាមេរិកាំងដកទាំងយន្តហោះទាំងអស់ ដកទាំងអីទាំងអស់ ទាំងកប៉ាល់តូចកប៉ាល់ធំ នៅក្នុងសមុទ្រហ្នឹង គឺថាអត់មានបន្តនូវសកម្មភាពទៀតទេ។ បាទ អរគុណ។

[១៤:២៣:២១]

**ស៖** សំណួររបស់ខ្ញុំខ្លីទេ គឺទាក់ទងទៅនឹងថាតើខាងកម្ពុជាបានដោះលែងនាវិកនៅលើកប៉ាល់ម៉ាយ៉ាហ្គេសនោះឲ្យត្រឡប់ទៅវិញហើយបានមានការវាយប្រហារ ឬក៏មិនទាន់ដោះលែងទេ ហើយមានការវាយប្រហារពីអាមេរិក? លោកស្តាប់សំណួរខ្ញុំបានទេ?

**ឆ៖** ខ្ញុំជម្រាបបញ្ជាក់ថា ពេលដែលយើងឲ្យវាត្រឡប់ទៅវិញហើយ បានចាប់ផ្តើមវ៉ៃគ្នា បាទឲ្យបានកប៉ាល់ គ្រាន់តែកប៉ាល់ម៉ាយ៉ាហ្គេសនោះចេញ គឺចាប់វ៉ៃគ្នាតែម្តង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរតូចមួយទៀតទាក់ទងទៅនឹងវគ្គរៀនសូត្រ។ លោកបានចូលរួមវគ្គរៀនសូត្រណាមួយផ្សេងទៀតទេពីអ្វីដែល ក្រៅពីអ្វីដែលលោកបាននិយាយរួចហើយ នៅក្នុងសវនាការនេះ? ឧទាហរណ៍ថ្នាក់រៀនសូត្រជាមួយកងពលជាដើម?

**ឆ៖** បាទ ក្រោយៗមកទៀត ខ្ញុំមិនបានៗចូលវគ្គសិក្សាជាមួយវរសេនាតូច ឬមួយកងពលអីទៀតដែរ ព្រោះតាំងពីហ្នឹងមកក៏មានការស្ងប់ស្ងាត់រហូតទៅ អត់មានបានទទួលផែនការអីទៀតទេ អត់បានប្រជុំរៀនសូត្រអីទៀតទេ។ បាទ អរគុណ។

**ស៖** បាទ សូមអរគុណ។ លោកបានឆ្លើយកន្លងមកថា មាស មុត ជាប្រធានកងពល១៦៤។ សំណួររបស់ខ្ញុំសួរថា តើលោកស្គាល់នរណាជាអគ្គមេបញ្ជាការកងទ័ពទូទាំងប្រទេសទេ?

**ឆ៖** បាទ ខ្ញុំសូមអរគុណណាស់។ ក្រោយពីបានចប់សង្គ្រាមឆ្នាំ៧៥ហើយ ដោយសារប្រកាសនៃបក្សកុម្មុយនីស្តហើយ អ្នកណាដឹកនាំ ដែលធំ ក្នុងរង្វង់នោះខ្ញុំសូមនិយាយហើយ។ ឆ្នាំ៧៥ ដែលរំដោះហើយ ប្រកាសនៃបក្សកុម្មុយនីស្តគឺថា ខ្ញុំពីមុនដំបូងឮមានប្រវត្តិថា ដឹងថាឈ្មោះៗមានតែឈ្មោះទេ។ ហើយខ្ញុំបានដឹងថា អ្នកឈ្មោះធ្លាប់ឮ បាទឮលោក ខៀវ សំផន។ ដល់ពេលចប់ឆ្នាំ៧៥ រំដោះហើយប្រកាសឈ្មោះនៃបក្សកុម្មុយនីស្ត ស្រាប់ឃើញលោក ប៉ុល ពត។ បាទ នេះជាការពិត។ អគ្គមគ្គុទ្ទេសន៍ផ្តើមដែលដឹកនាំប្រជាជនកម្ពុជា អាហ្នឹងជា -- បានរៀនសូត្រ។ ហើយអ្នកកងពលធំរបស់ខ្ញុំគឺថាតា

មាស មុត នេះគឺគាត់ប្រធាននៃវរៈ ប្រធានកងពលប្រចាំនៅក្រុងកំពង់សោមតែម្តង។ នេះតាំងពីឆ្នាំ៧៥ មក បាទខ្ញុំពិតប្រាកដដែលខ្ញុំនៅចងចាំ គឺថាអត់ភ្លេចទេរហូតដល់ឆ្នាំ -- រហូត៩៣ ដែលខ្ញុំចេញពីសមរភូមិ សំឡូតមកដល់សព្វថ្ងៃនេះ។

[១៤:២៧:២២]

**ស៖** បាទ សូមអរគុណលោកសាក្សី។ សំណួររបស់ខ្ញុំអម្បាញ់មិញនេះ គឺខ្ញុំសួរទៅលើអគ្គមេបញ្ជាការកងទ័ព។ ខ្ញុំសួរថានរណាជាអគ្គមេបញ្ជាការកងទ័ពនៅទូទាំងប្រទេស មិនមែនៗអគ្គមគ្គុទ្ទេសក៍ទេ។ លោកស្តាប់សំណួរខ្ញុំបានទេ? លោកស្គាល់ឈ្មោះគាត់ទេ?

**ឆ៖** បាទ នៅក្នុងហ្នឹងរឿង សាច់រឿងហ្នឹង ខ្ញុំអត់បាននៅចងចាំទេបាទ អត់ចងចាំទេ។ អ្នកដឹកនាំនៃខាងយោធា ខាងនយោបាយអី គឺខ្ញុំអត់បានចងចាំទេ ព្រោះខ្ញុំកាលនោះនៅវាងស្មើរដែរបាទ ហើយការចងចាំរបស់ខ្ញុំក៏មានការភ្លាំងច្រើនដែរជំនាន់នោះ។

**ស៖** បាទ សូមអរគុណ។ លោកស្គាល់ឈ្មោះ សុន សេន ទេ?

**ឆ៖** បាទ ពិតប្រាកដណាស់ ខ្ញុំស្គាល់ឈ្មោះ ប៉ុន្តែខ្ញុំពុំដែលឃើញមុខទេ ហើយក៏ពុំដែលបានទទួលនូវដំណឹងអីគាត់ជាអគ្គបញ្ជាការអាដែលកងទ័ពដែរ ព្រោះខ្ញុំកាលហ្នឹងវានៅចងចាំ វាភ្លេចច្រើនពេកបាទ សូមអរគុណ។

**ស៖** លោកដែលជួបគាត់ទេ?

**ឆ៖** បាទ ពុំដែលបានជួបទេបាទ។ ពុំដែលជួបទេ សុន សេន។

[១៤:២៩:១១]

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3 -- សូមទោស E319/23.3.12 ត្រង់ចម្លើយលេខ៧៥ សាក្សីរូបនោះគាត់បានបញ្ជាក់អំពីការណែនាំរបស់សុន សេន នេះដែលខ្ញុំសូមដកស្រង់៖ “នៅចុងឆ្នាំ១៩៧៧ ខ្ញុំបានចូលរួមប្រជុំសន្និបាតនៅភ្នំពេញធ្វើការបូកសរុបការងារក្នុងក្របខ័ណ្ឌការងារកងពល១៦៤។ ខ្ញុំព្ទ មាស មុត រាយការណ៍ពីទូកវៀតណាមដែលបានចូលក្នុងដែនសមុទ្រកម្ពុជា ហើយ សុន សេន បាននិយាយថា “បើវៀតណាមទាំងនោះជាជនភៀសខ្លួនទៅប្រទេសថៃ យើងមិនត្រូវចាប់ពួកគេទេ ហើយឲ្យពួកគេធ្វើដំណើរទៅចុះ។” សូមបញ្ចប់ការដកស្រង់។ តើលោកមានដែលស្តាប់បាន ឬឮការណែនាំតាមរយៈមេបញ្ជាការរបស់លោកលើខ្លឹមសារនៃការមិនឲ្យចាប់ជនភៀសខ្លួនដែលជាជនជាតិវៀតណាមនោះដែរទេ?

**ឆ៖** បាទ ក្នុងនោះ ខ្ញុំមិនដែលទេ អត់ដែលឮទេ អត់ដែលឮថាមិនឲ្យចាប់ ដែលតែឮឲ្យចាប់តែម្តង បាទអត់។

**ស៖** បាទ សូមអរគុណ។ សំណួរចុងក្រោយមួយ ខ្ញុំចង់សួរថា តើលោកដឹងពីការកកើតនៃកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំណាទេ? នៅពេលដែលមានការរៀបចំជារចនាសម្ព័ន្ធថ្នាក់ជាតិ លោកបានដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងអីទេ ព្រោះខ្ញុំជាយុទ្ធជន ខ្ញុំមិនបានដឹងគម្រោងផែនការ ការរៀបចំយ៉ាងម៉េចខ្ញុំអត់បានទទួលដឹងទេបាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ ឥឡូវនៅសេសសល់ពេលវេលាខ្លះ សូមប្រគល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី បើសិនជានៅមានសំណួរ សូមអញ្ជើញបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៤:៣១:៥៨]

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឥឡូវនេះ ខ្ញុំចូលដល់មេបញ្ជាការផ្ទាល់របស់លោកឈ្មោះ សំណាង។ នៅពេលដែលលោកស្ថិតនៅលើកោះពូលូវ៉ៃនោះ តើលោកមេបញ្ជាការរបស់លោកឈ្មោះហ្នឹងឬក៏យ៉ាងម៉េច?

**2-TCW-1000 ៖**

**ឆ៖** បាទ ជាពិតប្រាកដណាស់ មេបញ្ជាការរបស់ខ្ញុំ បងសំណាង។

**ស៖** តើគាត់ជាមេបញ្ជាការរបស់លោកដែរទេ នៅពេលដែលលោកប្រយុទ្ធជាមួយនឹងកងកម្លាំងអាមេរិកាំងនៅលើកោះតាង?

**ឆ៖** នៅក្នុងឆ្នាំ៧៥ ខ្ញុំវ៉ៃនៅកោះតាងហ្នឹង ឃើញថាវរសេនាតូចរបស់ខ្ញុំហ្នឹងចែកជាពីរអនុសេនាធំ។ មកមួយអនុសេនាធំ ឃើញថាទៅកោះ នៅកោះពូធីវ៉ៃ។ មួយអនុសេនាធំនៅកោះតាង។ អ៊ីចឹង

មេបញ្ជាការខ្ញុំ បងសំណាង នោះ គឺថាគាត់អត់បាននៅរួមរើជាមួយទេ បាទអត់រួមទេ ប៉ុន្តែនៅជាសមាជិករបស់គាត់មួយដែលនៅក្នុងអនុសេនាធំរបស់ខ្ញុំ។ នៅឆ្នាំ៧៥ហ្នឹង ខ្ញុំនៅធ្វើសកម្មភាពនៅជាមួយអាមេរិកាំងហ្នឹងគឺអនុៗរបស់គាត់ ឈ្មោះ បងនិត។

**ស៖** ប៉ុន្តែនៅពេលដែលលោកនៅកោះពូលូវ៉ៃ បងសំណាងហ្នឹង គឺជាមេបញ្ជាការផ្ទាល់របស់លោកតែម្តង។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដណាស់មេបញ្ជាការរបស់ខ្ញុំ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេគឺថា លោកបានឃើញព្រឹត្តិការណ៍តែពីរលើកទេ គឺការសម្លាប់ជនជាតិវៀតណាម ព្រឹត្តិការណ៍មួយដែលយើងបានពិភាក្សាព្រឹកមិញនេះហើយ គឺកើតឡើងនៅលើកោះពូលូវ៉ៃហ្នឹងផ្ទាល់តែម្តង ហើយនិងព្រឹត្តិការណ៍ទី២ គឺកើតនៅលើផ្ទៃសមុទ្រតែម្តង អ៊ីចឹងត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ជាការពិតណាស់ ត្រឹមត្រូវណាស់។ បាទ អរគុណ។

[១៤:៣៤:៥១]

**ស៖** ព្រឹត្តិការណ៍ទី២ ដែលលោកបាននិយាយថា គេបានបោះក្មេងចូលទៅក្នុងទឹកសមុទ្រគឺលោកស្ថិតនៅលើផ្ទៃទឹកចន្លោះកោះពូលូវ៉ៃ ហើយនិងឆ្នេរ គឺថាតើលោកពេលហ្នឹងលោកឈរជើងនៅចន្លោះកោះពូលូវ៉ៃនិងឆ្នេរ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទកាលនុ៎ងខ្ញុំនៅមកដីគោកហើយ ខ្ញុំមកដីគោក ប៉ុន្តែនៅជិតផែៗបានឃើញព្រឹត្តិការណ៍ដែលគេបោះក្មេងដែលកំពុងតែយំខ្លាំងហ្នឹង បោះចូលទៅក្នុងទឹក អាហ្នឹងឃើញ។ បាទ ជាពិតប្រាកដមែន។

**ស៖** នៅពេលព្រឹត្តិការណ៍នុ៎ងកើតឡើង តើព្រិត្តិការណ៍នេះកើតឡើងនៅលើផ្ទៃសមុទ្រ ឬក៏ព្រឹត្តិការណ៍នេះកើតនៅលើឆ្នេរសមុទ្រ?

**ឆ៖** បាន នៅក្នុងផ្ទៃសមុទ្រតែម្តង បាទ។

**ស៖** តើគេគ្រវាត់ក្មេងហ្នឹងចូលទៅក្នុងទឹកសមុទ្រហ្នឹង គេគ្រវាត់មកពីលើកប៉ាល់ ឬក៏គ្រវាត់ពីលើកោះ ពីឆ្នេរ ឬពីឆ្នេរសមុទ្រ?

[១៤:៣៦:៣៨]

**ឆ៖** ជាការពិតណាស់ វារឿងហ្នឹងខ្ញុំឃើញផ្ទាល់នឹងភ្នែក គឺថាពីលើកប៉ាល់របស់វៀតណាមហ្នឹងតែម្តង ព្រោះគេឡើងទៅនៅលើកប៉ាល់ហ្នឹងហើយ គេក៏ចាប់កូនក្មេងនោះ ឃើញយំខ្លាំងពេកក៏គេ

ចាប់បោះទម្លាក់ទៅចោលតែម្តង។ អានេះជាការពិត។

**ស៖** អ៊ីចឹងព្រឹត្តិការណ៍ហ្នឹង គឺថាប្រព្រឹត្តិឡើងដោយកងទ័ពនៅលើកោះពូលូវ៉ៃ នៅលើផ្ទៃសមុទ្រតែម្តង អ៊ីចឹងមែនឬ?

**ឆ៖** បាទ រឿងរ៉ាវនេះជាការពិតណាស់ ព្រោះសកម្មភាពដែលអង្គភាពរបស់វរសេនាតូចនៃកងវរសេនាធំ៦២ របស់ខ្ញុំបានអ្នកធ្វើសកម្មភាព។ បាទ នេះជាខ្ញុំបានឃើញជាការពិតៗជំនាន់នោះ។

**ស៖** ខ្ញុំសូមបញ្ជាក់ព្រឹត្តិការណ៍ទាំងពីរនេះឲ្យបានច្បាស់លាស់។ អ៊ីចឹងព្រឹត្តិការណ៍ទាំងពីរនេះ គឺត្រូវបានប្រព្រឹត្តឡើង ប្រហែលជាត្រូវបានប្រព្រឹត្តឡើងក្រោមការបញ្ជារបស់បង សំណាង ត្រឹមត្រូវដែរទេ?

**ឆ៖** ផ្នែកយោធាខាងក្រោម គឺគោរពទៅខាងលើ បាទ ខាងលើគោរពទៅខាងលើទៀត យ៉ាងម៉េចខ្ញុំអត់ដឹងទេ ប៉ុន្តែជាគោលការណ៍នយោបាយរបស់ខាងក្រោមជាយុទ្ធជន គឺថាឲ្យតែគេបញ្ជា គឺអនុវត្តហើយ។ បាទ សូមអរគុណ។

[១៤:៣៨:៤៤]

**ស៖** នៅពេលព្រឹត្តិការណ៍នេះកើតឡើង គឺព្រឹត្តិការណ៍ដែលគេគ្រវាត់កូនក្មេងចូលទៅក្នុងទឹកសមុទ្រ ជាព្រឹត្តិការណ៍មួយដែលមេបញ្ជាការលោកហ្នឹង គឺថាត្រូវប្រព្រឹត្តអ៊ីចឹងតែម្តង ឬក៏ត្រូវតែទទួលបញ្ជាសាកសួរពីបងសំណាង សិន?

**ឆ៖** បាទ ក្នុងនោះ គឺសម្រេចពី បងសំណាង គាត់ជាប្រធាន បាទជាប្រធានវរសេនាតូចហ្នឹងបានយោធាខាងក្រោមហ៊ានធ្វើបាទ។

**ស៖** អនុញ្ញាតឲ្យខ្ញុំអានសម្រង់ឲ្យលោកស្តាប់ ដែលជាសាក្សីមកពីកងពល១៦៤ដែរ គឺឯកសារ E3/9113, ERN ជាភាសាអង់គ្លេស 00974222, ខ្មែរ00926399 សាក្សីរូបនេះ ត្រូវបានសាកសួរថាត្រូវធ្វើយ៉ាងម៉េចនៅពេលដែលជួបប្រទះទូកណាមួយនោះ? សាក្សីរូបនេះបានឆ្លើយដូចតទៅ៖ "គេបានបង្គាប់ឲ្យយើង មិនឲ្យយើងចាប់ជនស៊ីវិលទេ។ យើងថាយើងគ្រាន់តែអាចចាប់គេមកសាកសួរ ថាតើជាជនភៀសខ្លួនមែន ឬក៏អត់តែប៉ុណ្ណោះ ហើយបើគេចង់ចាកចេញ គឺថាយើងអនុញ្ញាតឲ្យគេចាកចេញប្រកបដោយសុវត្ថិភាព និងផ្គត់ផ្គង់អាហារឲ្យគេផង។ យើងចាប់ពួកគេមក ហើយព្រលែងទៅវិញហើយយើងប្រាប់ទៅគេថា ឈប់មកទីនេះទៀត។ ទូកតូចនីមួយៗផ្ទុកមនុស្សប្រហែលជាប្រាំបីនាក់។ នៅពេលដែលឃើញពួកគេជិះទូកតាមតូចៗបែបនេះ យើងអាណិតអាសូរពួកគេណាស់។ ទាក់ទងទៅ

នឹងភ្នាក់ងារព័ត៌មានដែលចូលមកលើកោះយើង គឺថាយើងត្រូវទទួលបញ្ជាពីកងពល។ គឺថាយើងត្រូវបានបញ្ជាឱ្យចាប់អ្នកណាដែលចូលមកស៊ើបការណ៍នៅទឹកដីរបស់យើង។”

លោកសាក្សី សាក្សីម្នាក់នេះ គឺហាក់បីដូចជាឆ្លើយខុសពីលោក ថានៅពេលណាដែលជួបប្រទះទូកណាមួយ ហើយបើថាអ្នកទាំងនោះគឺជាជនភៀសខ្លួន យើងអនុញ្ញាតឱ្យគេត្រឡប់ទៅវិញ។ ប៉ុន្តែបើមានការសង្ស័យថាមិនមែនជាជនភៀសខ្លួនទេ ជាអ្នកស៊ើបការណ៍អីយ៉ាងដូច្នោះ គឺថាត្រូវចាប់ពួកគេមកដើម្បីបញ្ជូនទៅលើសួរបន្តទៀត។ ដូច្នេះយើងឃើញលោកឆ្លើយថា បញ្ជានេះគឺចេញមកពី បងសំណាង។ ដូច្នេះ អ្វីដែលខ្ញុំបញ្ជាក់អម្បាញ់មិញ សូមលោកឆ្លើយតបយ៉ាងម៉េច -- តើលោកឆ្លើយតបយ៉ាងណាដែរ?

[១៤:៤២:០៣]

**ឆ៖** បាទ មិនដឹងយ៉ាងម៉េចទេ ប៉ុន្តែជាគោលដៅនៃច្បាប់របស់បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ គឺថាគ្មានទេ។ គឺវៀតណាមសត្រូវស្លូតបូតហើយ អត់មានថាចាប់ហើយលែងទៅវិញទេ បើលែង អត់មានលែងទេ។ បើចាប់បាន គឺថាយកមកសួរចម្លើយ។ សម្លាសទៅតាមវិទ្យុ អាហ្នឹងខ្ញុំជឿ។ នេះជាការពិតបាទ ខ្ញុំមិនមែនជំទាស់អីទេ។ បើប្អូនគេ មុខសញ្ញារបស់គេ គេមានអ៊ីចឹងក៏មិនដឹងទេ ប៉ុន្តែមុខសញ្ញានៃកងពល -- អ៎! នៃខាងជើងទឹកវរសេនាធំ៦២របស់ខ្ញុំ គឺថាគ្មានទេ។ បាទ សូមជម្រាបត្រង់ពីតែម្តង។ បាទ សូមអរគុណ។

**ស៖** លោកបានរៀបរាប់អំពីអង្គភាពរបស់លោក និងអ្នកពាក់ព័ន្ធនៅក្នុងព្រឹត្តិការណ៍ទាំងអស់នេះ។ សូមដកស្រង់ “គឺថាជាចោរព្រៃដ៏សាហាវ” បញ្ចប់ការដកស្រង់។ គឺតើ -- ថាតើបង សំណាង ហើយនិងក្រុមរបស់លោកហ្នឹង គឺជាចោរព្រៃ ឬក៏មិនមែនទេ?

**ឆ៖** បាទ ខ្ញុំសូមលើកឡើងបញ្ហាអស់ទាំងនេះ ដែលព្រឹត្តិការណ៍ដែលកើតឡើង គួរឱ្យយើងខ្ញុំចាប់អារម្មណ៍។ រឿងរ៉ាវអស់ទាំងនេះ ខ្ញុំជាយោធាមួយប្រចាំនៅក្នុងរង្វង់កងពល១៦៤ ជាវរសេនាតូច ៦២២, ៦២ វរសេនាធំ។ អង្គភាពរបស់ខ្ញុំមិនមែនជាចោរព្រៃ ឬមួយហៅថានៅក្រោមការដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺអ្នកមានបញ្ហាការគ្រប់គ្រង គ្រប់គ្រាន់ នៅក្នុងឆ្នាំ ចាប់តាំងពីឆ្នាំ៧២ រហូតដល់ឆ្នាំ ៧៥ រំដោះហើយ រហូតដល់សព្វថ្ងៃ ដែលបាក់បែករលត់រលាយនេះ។ បាទ សូមអរគុណ សូមជម្រាប។

[១៤:៤៤:៣៥]

**ស៖** តើលោកចង់និយាយប្រាប់ថាយ៉ាងម៉េចដែរ ពេលដែលគេចាប់កប៉ាល់ម៉ាយ៉ាហ្គេស “គឺថាយើងគឺដូចក្រុមចោរព្រៃអ៊ីចឹង ដោយសារថាយើងចាប់កប៉ាល់ម៉ាយ៉ាហ្គេសនេះទាំងខុសច្បាប់”។ តើ

លោកចង់ថាម៉េច ដែលថា "ក្រុមរបស់យើង គឺដូចជាចោរព្រៃ" អ៊ីចឹង?

**ឆ៖** បាទ ខ្ញុំសូមជម្រាបដល់លោកទាំងអស់។ ខ្ញុំវាយតម្លៃដូចជាចោរព្រៃគ្មានច្បាប់ បាទ អត់មានច្បាប់គោរពច្បាប់អន្តរជាតិ។ កាលនោះនៅសង្គ្រាមភ្លាមៗដែលមិនទាន់បំពាក់បំប៉នលើផ្នែកនយោបាយអីមួយ គឺអត់។ អ៊ីចឹងឲ្យតែឃើញ គឺចាប់ ឃើញចាប់ទាំងអស់ ធ្វើឲ្យតែឃើញ ចាប់ ឃើញចាប់ៗតែម្តង ឲ្យតែកប៉ាល់។ មិនថាកប៉ាល់នេសាទថៃ មិនមែនគ្រាន់ថាកប៉ាល់អាមេរិកាំងអីទេ គឺឲ្យតែឃើញ ដឹងតែគេបញ្ជាឲ្យចាប់ហ្នឹង ហើយអ៊ីចឹងចេះតែចាប់ហើយ។ អ៊ីចឹងខ្ញុំប្រៀបធៀបទៅ វាដូចជាចោរព្រៃ ដែលគ្មានច្បាប់បាទ។ ខ្ញុំវាយតម្លៃហ្នឹង កាលហ្នឹង ខ្ញុំនិយាយមែនថា ដូចៗដូចអាដែងចោរព្រៃអ៊ីចឹង គ្មានដឹងច្បាប់ ដឹងទម្លាប់ដែលផ្លូវអន្តរជាតិ មិនអន្តរជាតិទេ គឺថា ពេលភ្លាមៗនោះ គឺថាខ្ញុំឃើញព្រឹត្តិការណ៍ហ្នឹងពិតប្រាកដ បាទ។

**ប្រធានអង្គជំនុំ៖**

ពេលវេលាដូចជាលើសហើយលោកមេធាវី។

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះផ្អាកត្រឹមហ្នឹងណ៎ា បញ្ចប់ត្រឹមហ្នឹងក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ លោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំនៅមានសំណួរច្រើនទៀតដែរ។ ខ្ញុំសូមសួរសំណួរមួយចុងក្រោយមួយទៀតចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ព្រឹត្តិការណ៍ទាំងពីរដែលលោកថា បានសម្លាប់ប្រជាជនវៀតណាម តើសកម្មភាពនេះប្រព្រឹត្តឡើងដោយក្រុមចោរព្រៃដែលបានចាប់កប៉ាល់ម៉ាយ៉ាហ្គេសហ្នឹងដដែលឬ? ឬថាក្រុមដែលៗសម្លាប់ជនជាតិវៀតណាមហ្នឹង គឺជាក្រុមចោរព្រៃតែមួយដែលៗចាប់កប៉ាល់ម៉ាយ៉ាហ្គេស ឬក៏យ៉ាងណា?

**2-TCW-1000៖**

**ឆ៖** បាទ នៅក្នុងឆ្នាំនោះ ឃើញថា ដោយមុខសញ្ញារបស់វរសេនាធំ៦២ គឺវរសេនាធំ៦២ហ្នឹងជានៅក្នុងមុខហ្នឹងហើយ នៅក្នុងមុខហ្នឹង។ អ៊ីចឹងព្រឹត្តិការណ៍ដែលកើតឡើងហ្នឹងនៅតែក្នុងវរសេនាធំហ្នឹងតែមួយទេ។ អ៊ីចឹងគ្មានវរសេនាធំពីខាងក្រៅណាមកធ្វើសកម្មភាពទេ មានតែវរសេនាធំហ្នឹងធ្វើសកម្មភាព។ វរសេនាធំ៦២ វរសេនាតូច៤១០ហ្នឹង គឺថាអ្នកធ្វើសកម្មភាពហើយ។ អ៊ីចឹងរឿងរ៉ាវអស់ទាំងនេះ ឃើញថាអត់មានពីអង្គភាពណាមកធ្វើទេ នៅក្នុងតែក្របខ័ណ្ឌនៅក្នុងវរសេនាតូចហ្នឹង។ បាទ

សូមអរគុណ។

[១៤:៤៧:៥៩]

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំសល់សំណួរច្រើនណាស់ ប៉ុន្តែអកុសល អស់ពេលសម្រាប់យើងខ្ញុំទៅហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណលោកសាក្សី ដែលសវនាការស្តាប់សក្ខីកម្មរបស់លោកនៅក្នុងឋានៈជាសាក្សីដល់ពេលនេះដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកទទួលបាននូវសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសុខសេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាតមានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរចំពោះលោក មឿន សុវណ្ណមេធាវីប្រឹក្សាសាក្សី ដែលលោកបានចូលរួមនៅក្នុងសវនាការនេះ ហើយនាពេលនេះ លោកអាចសម្រាកបានហើយ។

ហើយសវនាការបន្តនេះ អង្គជំនុំជម្រះនឹងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម [2-TCW-848]។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសង្ឃឹមថាអាចនឹងមានឱកាសបំភ្លឺនឹងកម្មវិធីលើកាលវិភាគដើម្បីឲ្យយើងមានក្រុមសម្រាប់តុលាការ។ ស្អែកគឺយើងនឹងពិភាក្សាសំណើសុំដាក់បន្ថែមសាក្សី ទាក់ទងនឹងជនជាតិវៀតណាម។ តើអាចទៅរួចដែរឬទេ ឲ្យសុំអង្គជំនុំជម្រះចង្អុលបង្ហាញថាអាចពេលព្រឹក ឬក៏

ក្រោយពីបញ្ចប់សាក្សីថ្ងៃស្អែក បាទ។ ហើយក៏អាចនឹងមានប្រយោជន៍ដែរ ដើម្បីឲ្យយើងរៀបចំសហសេវិកនៅខាងយើងនៅក្នុងតុលាការ ដើម្បីរៀបចំសម្រាប់ថ្ងៃស្អែក ឬក៏ថ្ងៃសុក្រ នូវការសាកសួរសាក្សីនោះ។ សូមអរគុណលោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ គឺអង្គជំនុំជម្រះបានជម្រាបព្រឹកមិញហើយថា នៅពេលព្រឹកថ្ងៃស្អែក។ ព្រឹកហ្នឹងបានន័យថាចាប់ផ្ដើមដំបូងមុននឹងតសំណួរដេញដោលចំពោះសាក្សី គឺយើងធ្វើកិច្ចការនេះមុន។ យើងមិនបានបញ្ជាក់អ៊ីចឹងមែន ប៉ុន្តែយើងនៅពេលព្រឹកច្បាស់លាស់ហើយ ន័យតាមពាក្យខ្មែរគឺពេលព្រឹកបានន័យថាដើមដំបូងនៃដំណើរការសវនាការហើយ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥១ នាទី ដល់ម៉ោង ១៥:១៣ នាទី)*

[១៥:១៣:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម [2-TCW-848]។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក ថេង ផល៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ថេង ផល។

**ស៖** អរគុណលោក ថេង ផល។ ចុះអង្កាល់ពីលោកផ្ដល់ -- លោកដែលមកផ្ដល់សក្ខីកម្មនៅចំពោះអ្នកស៊ើប -- ចំពោះមុខអ្នកស៊ើបអង្កេតនៃសាលាក្ដីនេះដែរឬទេរយៈពេលកន្លងមក?

**ផ៖** អត់ដែលបានមកទេ លោកគ្រូ។

**ស៖** ជាមួយអ្នកស៊ើបអង្កេតដែលទៅសាកសួរលោកកន្លងមក កាលពី លោកមានបានផ្ដល់សក្ខី-កម្ម ឬក៏ធ្វើការឆ្លើយតបទៅនឹងការតាំងសំណួររបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃតុលាការវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

**ផ៖** បានចូលសម្ភាសជាមួយអ្នកដែលទៅសម្ភាសបានទៅមែនលោកគ្រូ។

**ស៖** ហើយបានធ្វើប៉ុន្មានដង?

**ផ៖** រយៈពេលដែលធ្វើហ្នឹងចំនួនពីរដងលោកគ្រូ។

[១៥:១៦:២៩]

**ស៖** បាទ អរគុណ។ យើងបានពិនិត្យមើលនូវសក្ខីកម្មរបស់លោកដែលផ្ដល់បទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតក្នុងអំឡុងពេលនៃដំណើរការស៊ើបអង្កេតកន្លងមក ដែលលោកបានឆ្លើយបញ្ជាក់នេះគឺគេដាក់ឈ្មោះ ថេង ហ៊ុយ។ ឥឡូវនេះគឺលោកឆ្លើយចំពោះយើងអំមិញថាឈ្មោះ ថេង ផល។ តើឈ្មោះ ថេង ហ៊ុយ ហ្នឹងជានរណាគេ? ហើយ ថេង ផល ហ្នឹងជាអ្នកណាគេ?

**ផ៖** ខ្ញុំសូមឆ្លើយពីរសំណួរនេះ គឺថា កាលពីទៅសម្ភាសលើកដំបូងនោះ គឺខ្ញុំមិនទាន់បានចូលបម្រើការងារទេ គឺខ្ញុំដាក់ឈ្មោះ គឺឈ្មោះធម្មតាឈ្មោះ ហ៊ុយ។ តែដល់ពេលក្រោយមកឆ្នាំ៨៤ ខ្ញុំបានចូលបម្រើការងារនៅក្នុងកសិកម្មក៏បានប្រែឈ្មោះដាក់ឈ្មោះ ថេង ផល។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកដូចជាមិនមែននៅធ្វើនៅ៨៤ទេ គឺធ្វើនៅឆ្នាំ២០០៨ៗ។ ហេតុអ្វីបានជាលោកប្រើឈ្មោះ ថេង ហ៊ុយ ហើយនាពេលនេះលោកឆ្លើយថាលោកឈ្មោះ ថេង ផល?

**ផ៖** អង្កាល់សម្ភាសខ្ញុំហ្នឹងគឺនៅស្វាយអន្ទរលើកដំបូងបំផុត។ កាលនុ៎ងគឺខ្ញុំនៅជាប្រជាជននៅឡើយ ហើយឈ្មោះខ្ញុំគឺឈ្មោះ ថេង ហ៊ុយ។ ឪពុកខ្ញុំឈ្មោះ ថេង។ ខ្ញុំឈ្មោះ ហ៊ុយ លោកគ្រូ។

**ស៖** ចុះឥឡូវនេះលោកប្រើឈ្មោះអីពិតប្រាកដ? នៅជាពិសេសនៅក្នុងអត្តសញ្ញាណបណ្ណរបស់លោកដែលរដ្ឋចេញឲ្យលោកប្រើប្រាស់សព្វថ្ងៃនេះ លោកប្រើឈ្មោះអី?

**ផ៖** សព្វថ្ងៃខ្ញុំបម្រើការងារនៅក្នុងរដ្ឋនេះគឺក្នុងអត្តសញ្ញាណបណ្ណគឺឈ្មោះ ថេង ផល។

**ស៖** បាទ អរគុណលោក ថេង ផល។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** ខែឆ្នាំកំណើតខ្ញុំចាំលោកគ្រូ គឺកើតនៅឆ្នាំ១៩៥១ -- ថ្ងៃ១១-ខែ១១-១៩៥០។

**ស៖** បាទ អរគុណ។ ចុះទីកន្លែងកំណើតរបស់លោកៗនៅកើតនៅទីកន្លែងណា?

**ឆ៖** ឆ្នាំកំណើតរបស់ខ្ញុំបាទគឺនៅក្នុងភូមិពោធិ៍ចិន្តាំ ភូមិស្វាយអន្ទរ ស្រុកព្រៃវែង។

**ស៖** បាទ អរគុណ។ ចុះសព្វថ្ងៃនេះ តើទីកន្លែងរស់នៅរបស់លោក លោករស់នៅទីកន្លែងណា?

**ឆ៖** ឥឡូវគឺខ្ញុំបានបម្រើការងារនៅខេត្តព្រៃវែង នៅក្នុងខេត្តព្រៃវែង ខ្ញុំបានផ្លាស់ទីលំនៅមកនៅក្នុងខេត្តព្រៃវែង នៅឡូតិ៍៧។

**ស៖** អ៊ីចឹង ឡូតិ៍៧ ក្រុងព្រៃវែង អ៊ីចឹងហ្អែស! ខេត្តព្រៃវែង?

**ឆ៖** បាទ ខ្ញុំនៅក្នុងឡូតិ៍៧ ហ្នឹង មែនលោកគ្រូ។

**ស៖** ចុះលោក ធ្វើការងារអ្វីដែរ ឬក៏ប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃ គឺខ្ញុំជាមន្ត្រីបុគ្គលិកបណ្តែតនៅក្នុងមន្ទីរកសិកម្ម។

**ស៖** បាទ អរគុណ ហើយចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ឆេង។ ម្តាយបង្កើតគឺស្លាប់ហើយ តែម្តាយក្រោយ គឺឈ្មោះសាន់។

**ស៖** សួរម្តាយបង្កើត។ ម្តាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** គាត់ឈ្មោះ ឃីម ម្តាយបង្កើត។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ រ៉េត អ៊ុក។ មានកូនចំនួនបីនាក់ ស្រីពីរ ប្រុសមួយ។

**ស៖** បាទ អរគុណលោក ចេង ផល ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជី សវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹងបាន គឺថាលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាជាមួយបុគ្គលទាំងឡាយ ដែលត្រូវបានទទួលយកជាភាគីនៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះទេ។ តើពិតដែរទេ?

**ឆ៖** ពិតមែនលោកគ្រូ គឺខ្ញុំអត់មានពាក់ព័ន្ធជាមួយសាច់ញាតិទាំងអស់នោះទេ ទទេ។

**ស៖** បាទ អរគុណ ហើយលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែកហើយឬនៅ មុនពេល

ចូលមកចំពោះមុខអង្គជំនុំជម្រះនេះ?

**ឆ៖** ខ្ញុំបានចូលស្បថចំពោះមុខលោកតាដំបងដែករួចអស់ហើយ។

**ស៖** បាទ អរគុណ។ តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោក ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះលោក ថេង ផល ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយអំពីករណីយកិច្ច លោក ថេង ផល ក្នុងឋានៈលោកជាសាក្សី ផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគីឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

ហើយអំមិញនេះ គឺលោកបានឆ្លើយរួចហើយថា លោកបានផ្តល់ ធ្លាប់បានផ្តល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតចំនួនពីរលើក។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានអាននូវកំណត់ហេតុដែលលោកបានអះអាងអំមិញថាលោកបាន ធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតកាលពីពេលមុននឹងអស់រយៈពេល -- ដែលចំនួនពីរលើកហ្នឹង ដើម្បីរំឭកការចងចាំរបស់ខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំបានអាននៅក្នុងអាដែងឯកសារដែលបានឲ្យរូបខ្ញុំបាទនោះ គឺឃើញថា ពិតដូចពាក្យដែលខ្ញុំនិយាយមែន។

**ស៖** បាទ អរគុណ ហើយនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

[១៥:២៥:០៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ ថ្ងៃនេះខ្ញុំបាទមានសំណួរមួយចំនួនចង់ជម្រាបសួរលោកសាក្សីឱ្យជួយបំភ្លឺដល់អង្គសវនាការ។ ដែលសំណួររបស់ខ្ញុំ គឺពាក់ព័ន្ធនឹងប្រធានបទស្ដីអំពីប្រវត្តិមួយចំនួន និងរចនាសម្ព័ន្ធគ្រប់គ្រង ហើយបន្ទាប់មកទៀតសហសេវិកអន្តរជាតិរបស់ខ្ញុំនឹងមានសំណួរមួយចំនួនពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តរបស់ជនជាតិវៀត-ណាម។ ឥឡូវសំណួរដំបូងរបស់ខ្ញុំ ខ្ញុំចង់ឱ្យលោកសាក្សីជួយបញ្ជាក់មើលថា ពីប្រវត្តិមួយចំនួនថាតើមុនឆ្នាំ៧៥នោះ លោករស់នៅកន្លែងណាដែរ ហើយធ្វើអ្វីខ្លះ?

**លោក ថេង ផល៖**

**ឆ៖** មុនឆ្នាំ៧៥ គឺរូបខ្ញុំបាទរស់នៅភូមិពោធិ៍ចិន្តាំហ្នឹងតែម្ដង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើពួកខ្មែរក្រហមចូលកាន់កាប់ភូមិរបស់លោកនៅឆ្នាំណាដែរ?

**ឆ៖** ពួកខ្មែរក្រហមបានចូលកាន់កាប់នៅក្នុងឆ្នាំ៧០ គឺមានតិចទេ គឺច្រើនតែវៀតណាម កងទ័ព។

**ស៖** តើលោក -- នៅពេលនោះលោករស់នៅភូមិនោះដែរឬយ៉ាងណា លោកអាចប្រាប់បានទេ?

**ឆ៖** ពេលនុ៎ង គឺខ្ញុំនៅក្នុងភូមិហ្នឹងរហូត។

**ស៖** លោកមានប្រសាសន៍ថានៅពេលហ្នឹង ខ្មែរក្រហមចូលកាន់កាប់តិចតួច។ តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ទេ តិចតួចហ្នឹងរបៀបម៉េចដែរ?

[១៥:២៧:៣១]

**ឆ៖** កាលដែលកងទ័ពវៀតណាមមកនៅហ្នឹង គឺកងទ័ពខ្មែរក្រហម គឺមានចំនួនដូចថាវៀត-

ណាម៧០ ឬប៉ុណ្ណឹង យើងបានតែត្រឹម៣០ភាគរយទេ វាមិនទាន់ច្រើនទេ។

**សះ** តើពេលហ្នឹងការគ្រប់គ្រងរដ្ឋបាលភូមិហ្នឹង គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ឬយ៉ាងណា លោកអាចបញ្ជាក់ឱ្យច្បាស់មើល៍?

**ឆះ** កាលឆ្នាំនុំងគឺនៅមានជំនាញការឡើយ ជំនាញការ គឺជំនាញការវៀតណាម គេអ្នកមើលខុសត្រូវ។

**សះ** តើជំនាញកងទ័ពវៀតណាម និងជំនាញការវៀតណាមហ្នឹង ស្ថិតនៅក្នុងភូមិលោករហូតដល់ឆ្នាំណាដែរ ទើបគេចេញ?

**ឆះ** ត្រង់ខ្ញុំ -- ត្រង់ចេញគឺខ្ញុំមិនបានដឹងទេ លោកគ្រូ។ គេមិនចប់ថ្ងៃណាទេ ពួកអាជំនាញការហ្នឹង អត់ដឹងសោះ។

**សះ** លោកសាក្សី មានកំណត់ហេតុស្តាប់ចម្លើយមួយរបស់អ្នកភូមិរបស់លោកដែរ គាត់ឈ្មោះ អៀង អុន គឺឯកសារលេខ E3/9352, ERN ជាភាសាអង់គ្លេស 00231661, ERN ជាភាសាបារាំង 00226264, ERN ជាភាសាខ្មែរ 00225361 នៅក្នុងហ្នឹងគាត់បានឆ្លើយ អៀង អុន ហ្នឹងឆ្លើយថា៖ “នៅភូមិពោធិ៍ចិន្តាំនេះត្រូវបានគ្រប់គ្រងដោយខ្មែរក្រហមនៅក្នុងឆ្នាំ៧២-៧៣”។ តើលោកឆ្លើយតបយ៉ាងណាដែរចំពោះការលើកឡើងរបស់គាត់នេះ?

**ឆះ** ក្នុងឆ្នាំ៧២-៧៣ហ្នឹង គឺខ្មែរក្រហមគ្រប់គ្រងមែន ដូច អៀង អុន ថាមែនលោកគ្រូ ពេញ។

[១៥:៣០:១៥]

**សះ** តើពេលនោះលោកធ្វើការងារអ្វីដែរ លោកអាចប្រាប់បានទេ?

**ឆះ** ពេលនោះ គឺខ្ញុំជាប្រជាជនធម្មតាលោកគ្រូ ខ្ញុំអត់មានធ្វើការងារអីទេ គឺខ្ញុំជាប់និន្នាការ កូននាយទុន កូនកសិករថ្នាក់លើ។

**សះ** អរគុណលោក។ នៅពេលដែលពួកខ្មែរក្រហមចូលកាន់កាប់ភូមិរបស់លោក តើគេមានដាក់មនុស្សឱ្យគ្រប់គ្រងភូមិហ្នឹងទេ ឬក៏គេប្រើរចនាសម្ព័ន្ធរដ្ឋបាលចាស់?

**ឆះ** នៅក្នុងនោះគឺ មុនដំបូងគឺមានការរចនាសម្ព័ន្ធ គឺនៅក្នុងភូមិហ្នឹងគឺជាប្រធានភូមិនៅនឹងភូមិហ្នឹងកាន់កាប់តែម្តងលោកគ្រូ។

**សះ** ចុះលោកអាចប្រាប់បញ្ជាក់ឱ្យបានច្បាស់ទេ ចាប់តាំងពីឆ្នាំ១៩៧៥មក តើប្រធានភូមិរបស់លោកហ្នឹងជាអ្នកណាគេ? ហើយឈ្មោះអីដែរ?

[១៥:៣១:៥០]

ឆ៖ ចូលឆ្នាំ៧៥ គឺប្រធានភូមិ គឺត្រូវការផ្លាស់ប្ដូរហើយពេលនោះ ត្រូវយកពីក្រោមកកាន់ម្ដង។ ឈ្មោះ សេង ហើយនិងឈ្មោះ ហួន មកនៅកាន់កាប់មើលខុសត្រូវ។

ស៖ រវាង សេង និងហ័ន តើមួយណាជាប្រធានភូមិ?

ឆ៖ ឈ្មោះ ហួន ជាប្រធានភូមិនៅក្នុងភូមិហ្នឹងតែម្ដង។

ស៖ ចុះឈ្មោះ សេង ជាអ្វីដែរ?

ឆ៖ ជាអនុប្រធាន។

ស៖ ក្រៅពីប្រធានភូមិ តើលោកមានស្គាល់ឈ្លបនៅក្នុងភូមិរបស់លោកដែរទេ?

ឆ៖ កងឈ្លបខ្ញុំមិនអាចស្គាល់បានទេ មិនដឹងឯណាឯណើដែរកាលនោះ ខ្ញុំមិនដែលហ៊ានសួរនាំគេ។

ស៖ អម្បាញ់មិញ ខ្ញុំបានលើកឈ្មោះសាក្សីម្នាក់គឺឈ្មោះ អៀង អុន ដែលមកពីឈ្មោះពោធិ៍ចិន្ដាំ ដូចលោកដែរ តើលោកស្គាល់គាត់ដែរឬទេ?

ឆ៖ បាទ ខ្ញុំបាទ ស្គាល់។

ស៖ លោកស្គាល់គាត់តាមរបៀបណាដែរ?

ឆ៖ គឺជាអ្នកមិត្តភក្ដិរៀនតាំងពីតូចរហូតជាមួយគ្នាទល់ឥឡូវ នៅទល់ឥឡូវហ្នឹងលោកគ្រូ។

ស៖ នៅជំនាន់ប៉ុលពតហ្នឹង អៀង អុន ហ្នឹងគាត់ធ្វើអ្វីដែរ?

ឆ៖ ជំនាន់ហ្នឹង អៀង អុន ក៏ជាប្រជាជនដូចតែខ្ញុំដែរលោកគ្រូ អត់មានធ្វើអីទេ ជាមិត្តភក្ដិដើរជីកព្រែកជីកប្រឡាយជាមួយតែគ្នា។

ស៖ ក្រៅពី អៀង អុន តើលោកមានស្គាល់មនុស្សម្នាក់ទៀត ឈ្មោះ អេង ដែរឬទេ?

ឆ៖ សុំអត់ទោសលោកគ្រូ ខ្ញុំស្ដាប់អត់បាន ឈ្មោះអីលោកគ្រូ ឈ្មោះអី?

ស៖ គាត់ឈ្មោះ អេង។

ឆ៖ ខ្ញុំមិនដែលស្គាល់ឈ្មោះ នោះទេលោកគ្រូ អេង ហ្នឹងមិនដែលឮឈ្មោះសោះ។

ស៖ តាមកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់លោក អៀង អុន គឺឯកសារE3/9352, ERN ជាភាសាខ្មែរ 00225355, ERN ជាភាសាអង់គ្លេស 00231660, ERN ជាភាសាបារាំង 00226263។ នៅក្នុង អៀង អុន បានលើកឡើងថា "ឈ្មោះ អេង ឈ្លបភូមិពោធិ៍ចិន្ដាំ មានប្អូនឈ្មោះ អិន នៅរស់

អាយុប្រហែល៥០ឆ្នាំជាង"។ តើ -- ហើយបន្ទាប់មកទៀតនៅខាងឃ្លាខាងក្រោមមកទៀតនៅក្នុងឯកសារដដែល ERN ដដែលនៅក្នុងកថាខណ្ឌខាងក្រោយទៀត អៀង អុន ក៏បាននិយាយថា -- នៅក្នុងERN ជាភាសាខ្មែរ 00225356, ERN ជាភាសាអង់គ្លេស 00231661, ERN ជាភាសាបារាំង 226264។ គាត់បានលើកឡើងថា៖ "ខ្ញុំបានធ្វើឈ្លបភូមិអស់រយៈពេលពីរខែ"។ តើការលើកឡើងទាំងពីររបស់ខ្ញុំនេះអាចរំឭការចងចាំរបស់លោកបានខ្លះដែរឬទេ?

**ឆ៖** បើលោកគ្រូមានប្រសាសន៍អ៊ីចឹងបានខ្ញុំនឹកឃើញមែន។ អេង ហ្នឹងជាឈ្លបមែន ខ្ញុំនឹកឃើញដែរលោកគ្រូ។ អេង ហ្នឹងជាឈ្លបភូមិនៅក្នុងហ្នឹងមែន។

[១៥:៣៧:៤៦]

**ស៖** ចុះចំពោះ អៀង អុន វិញ យ៉ាងម៉េចដែរ?

**ឆ៖** កាលហ្នឹងខ្ញុំវាមិនសូវយកចិត្តទុកដាក់ជាមួយវាដែរ ហើយណាមួយក៏វារាងភ្លេចភ្លាំងដែរលោកគ្រូ ៣០ឆ្នាំហើយរឿងវាធ្វើហ្នឹង។

**ស៖** ក្រៅពីឈ្មោះ អេង និង អៀង អុន នោះនៅក្នុងភូមិហ្នឹង លោកមានស្គាល់មនុស្សម្នាក់ឈ្មោះ ទ្រី ដែរឬទេ តាទ្រី?

**ឆ៖** ឈ្មោះ តាទ្រី ហ្នឹងមានតែគាត់ចាស់ហើយ តាហ្នឹង ចាស់ហើយស្លាប់បាត់យូរហើយ។

**ស៖** នៅសម័យប៉ុល ពត ហ្នឹង គាត់ធ្វើអីដែរលោកអាចប្រាប់បានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ!

**លោក ថេង ផល៖**

**ឆ៖** អ៊ីចេះសម័យហ្នឹងគឺខ្ញុំមិនសូវយកចិត្តទុកដាក់ព្រោះខ្ញុំនៅតែវាលលោកគ្រូ ខ្ញុំនៅតែខាងកាប់ដី រែកដី ដល់អ៊ីចឹងអត់ដឹងគេអ្នកនៅភូមិគេចាត់អ្នកណាធ្វើអីៗអត់ដឹងទេលោកគ្រូ។ គេមិនដែលឲ្យបាននៅភូមិនឹងគេទេខ្ញុំនោះ។

**សួរដោយលោក សេង លាង៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក អៀង អុន ដដែល ហើយ ERN ជាភាសាខ្មែរដដែលគឺ 55កន្ទុយហ្នឹង។ លោក អៀង អុន ហ្នឹងគាត់និយាយថា តាទ្រី ជាម្ចាស់រទេះសេះ។ តើអ្វីដែលខ្ញុំអាននេះលោកចាំបានដែរឬទេ?

**ឆ៖** ពេល -- តាទ្រី ហ្នឹងគាត់ដឹងថាគាត់ជាអ្នកបររទេះសេះពីហ្នឹងមែន តែត្រង់គាត់យ៉ាងម៉េច ខ្ញុំអត់ដឹងទេ ការងារគាត់ខ្ញុំអត់ដែលបានដឹងទេលោកគ្រូ គឺខ្ញុំ ដូចជម្រាបប្រាប់លោកគ្រូអ៊ីចុះ ខ្ញុំមិនដែលបាននៅនឹងភូមិគេទេ។

**ស៖** ឥឡូវងាកមករចនាសម្ព័ន្ធឃុំវិញម្ដង។ តើលោកចាំទេ មេឃុំស្វាយអន្ទរហ្នឹងឈ្មោះអីដែរ?

**ឆ៖** មេឃុំនៅឃុំស្វាយអន្ទរ កាលសម័យនុ៎ង គឺមានឈ្មោះ មុត មួយ ហើយនិង ឆែម មួយ។

**ស៖** លោកបាននិយាយអំពីឈ្មោះ មុត និងឈ្មោះ ឆែម។ តើ មុត ជាអ្នកណា? ហើយ ឆែម ជាអ្នកណាដែរ លោកអាចប្រាប់បានដែរទេ?

[១៥:៤១:០៩]

**ឆ៖** មុត និង ឆែម ហ្នឹង គឺជាក្នុងនាមជាគណៈឃុំទាំងអស់។ ជាប្រធានឃុំ សម័យប៉ុល ពត ហ្នឹង។ ទាំងពីរនាក់។

**ស៖** តើលោកអាចបញ្ជាក់ទេ នរណាគេជាមេឃុំ ហើយនរណាគេជាអនុឃុំ?

**ឆ៖** កាលនោះ គឺមុនដំបូង ឈ្មោះ ឆែម ហ្នឹង ជាអ្នកប្រធាន។ មុត ហ្នឹង ជាអនុឃុំ បាទ។

**ស៖** តើលោកមានស្គាល់មនុស្សម្នាក់ទៀត ឈ្មោះ មឿន ដែរឬទេ?

**ឆ៖** មឿន ហ្នឹង គឺខ្ញុំស្គាល់។

**ស៖** គាត់ជានរណាដែរ ហើយធ្វើអ្វីដែរ?

**ឆ៖** សម័យប៉ុល ពត នោះ គឺគាត់ក្នុងនាមជាប្រធានក្រុម។ ប្រធានក្រុមដឹកនាំ មិនមែនធ្វើអីទេ គ្រាន់តែខ្ញុំដឹងថាគាត់ជាប្រធានក្រុមដឹកនាំធ្វើការដកស្ទូងអី កាប់អីៗហ្នឹង គឺគាត់អ្នកនាំ ដឹកនាំ។

**ស៖** គាត់ជាប្រធានក្រុម ឬក៏ជាប្រធានសហករណ៍ លោកអាចប្រាប់បានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ថេង ផល៖**

**ឆ៖** កាលនុ៎ងគឺខ្ញុំមិនអាចដែរ ប៉ុនខ្ញុំហៅតាមឥឡូវ គេថាប្រធានក្រុមក៏បាន តែកាលនោះគេហៅសហករណ៍ ត្រូវហើយលោកគ្រូ។ មានប្រសាសន៍ហ្នឹងត្រូវហើយ ប្រធានសហករណ៍។

[១៥:៤៣:៣០]

**ស៖** តើលោកស្គាល់ប្រធានឈ្លបឃុំឈ្មោះអីដែរ លោកអាចស្គាល់ទេ?

**ឆ៖** ប្រធានឈ្លបឃុំហ្នឹងគឺ បើកាលហ្នឹងគេហៅសន្តិសុខក៏បានដែរ គឺឈ្មោះ ង៉ុយ បាទ។

**ស៖** អរគុណលោក។ ចុះលោកអាចស្គាល់ទេ គណៈស្រុកជានរណាដែរ លោកអាចស្គាល់បានទេ?

**ឆ៖** សូមអត់ទោស ក្នុងនាមជាគណៈស្រុក ខ្ញុំកាលមុនចាំលោកគ្រូ តែឥឡូវខ្ញុំភ្លេច ឈ្មោះចង្ហួម៨ – តាចង្ហួម៨ អ៊ីចឹងហើយ កាលនុ៎ង ឈ្មោះគាត់ គេហៅ "តាចង្ហួម៨"។

**ស៖** ឥឡូវខ្ញុំនៅមានប្រហែលជាពីរបីសំណួរទៀតទេ។ ឥឡូវខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា តើក្រោយឆ្នាំ៧៥ហ្នឹង តើលោករស់នៅភូមិពោធិ៍ចិន្តាំហ្នឹង តើគេឲ្យលោកធ្វើអ្វីដែរ លោកអាចប្រាប់បានដែរឬទេ?

**ឆ៖** ក្រោយឆ្នាំ៧៥ គឺរូបខ្ញុំបាទជាប្រជាជនធម្មតាសាមញ្ញ គ្មានការងារអីទេ គឺខ្ញុំជាប្រជាជនសុទ្ធ។

**ស៖** ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា លោកធ្វើអ្វី គេឲ្យលោកធ្វើអ្វី?

**ឆ៖** ក្នុងខាងក្រោយ -- ក្រោយឆ្នាំ៧៥ហ្នឹង គឺខ្ញុំគេឲ្យទៅជីកប្រឡាយៗ លើកប្រព័ន្ធភ្លឺស្រែ។ មុនដំបូងគឺលើកប្រព័ន្ធភ្លឺស្រែសិន ឲ្យទៅលើកខាងប្រព័ន្ធភ្លឺស្រែគ្រប់កន្លែងលោកគ្រូបាទ។ អត់ដែលបាននៅក្នុងភូមិទេ។

**ស៖** តើការងារនោះ គេឲ្យលោក តើការងារនោះ គេឲ្យលោកធ្វើ ឬក៏លោកពេញចិត្តធ្វើដោយខ្លួនឯង?

[១៥:៤៦:២៧]

**ឆ៖** សូមអត់ទោសលោកគ្រូ កាលនុ៎ងគ្នាមិនពេញចិត្ត តែដោយសារការបង្ខិតបង្ខំរបស់ការដឹកនាំរបស់ពួកខ្មែរក្រហម។

**ស៖** តើលោកអាចប្រាប់បានទេថា នៅឆ្នាំ៧៥ហ្នឹង មានប្រជាជនប្រហែលជាប្រមាណនាក់នៅភូមិរបស់លោកហ្នឹង? ហើយនៅក្នុងហ្នឹងមានប្រជាជនវៀតណាមប្រហែលប៉ុន្មាននាក់ដែរ លោកអាចដឹងទេ?

**ឆ៖** ក្នុងឆ្នាំ៧៥ហ្នឹង បើតាមខ្ញុំដឹង គឺមានប្រជាជនវៀតណាមដែលមានប្រពន្ធជា មានប្ដី មានប្រពន្ធហ្នឹង គឺមានចំនួនតែបីគ្រួសារទេដែលខ្ញុំស្គាល់ច្បាស់។

**ប្រធានអង្គជំនុំ៖**

បាទ មីក្រូ ក្បាលមីក្រូហ្វូន!

[១៥:៤៧:៣៣]

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំចង់ឱ្យលោកជួយបញ្ជាក់ថា អំពីតួលេខនៃប្រជាជនក្នុងភូមិទាំងមូលហ្នឹង តើលោកអាចចាំបានដែរទេ មានដឹងទេ?

**លោក ថេង ផល៖**

**ឆ៖** ខ្ញុំមិនអាចដឹងបានទេលោកគ្រូ សូមអត់ទោសចុះ អារឿងចំនួននោះមិនសូវដឹងទេ។

**លោក សេង លាង៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំសូមអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៤៨:៣១]

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៉ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ស៖** ខ្ញុំឈ្មោះ អេនគ្រូ ប៉ិយ ខ្ញុំសួរសំណួរមួយចំនួនទៅលោក។ ក៏មានសំណួរខ្លីមួយ ទាក់ទងទៅនឹងដែលលោកថា មានទីប្រឹក្សាចិន និងកងទ័ពនៅកន្លែងនោះ ហើយថាលោកមិនច្បាស់ទេ នៅពេលដែលលោកចាកចេញមក។ លោកអាចបញ្ជាក់បាន តើ សេង និង ហ៊ុន ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធាន និងអនុប្រធានភូមិរបស់លោក? នៅពេលនោះ តើ សេង និង ហួន ។បានចាកចេញហើយឬនៅ នៅ។ពេលដែលអ្នកទាំងពីរត្រូវបានតែងតាំងឱ្យធ្វើជាមេភូមិ និងជាអនុមេភូមិ?

**លោក ថេង ផល៖**

**ឆ៖** ខ្ញុំស្តាប់ដូចអត់ទាន់បានទេ លោកគ្រូ សូមជួយពន្យល់ម្តងទៀត បាន។។

**ស៖** មិនជាអ្វីទេ ខ្ញុំសួរម្តងទៀត។ ពីខាងដើមនេះលោកបានឆ្លើយថា មានទីប្រឹក្សាវៀតណាមនៅក្នុងភូមិរបស់លោក ឬក៏ថានៅក្នុងស្រុករបស់លោក។ ហើយថាលោកមិនច្បាស់ទេ ថាទីប្រឹក្សាវៀត-

ណាមចាកចេញទៅវិញនៅពេលណានោះទេ។ ខ្ញុំចង់ដឹងថា នៅពេលដែលទីប្រឹក្សាវៀតណាមចាកចេញទៅនោះ គឺវាចំពេលនឹងដែល ហួន ហើយនិង សេង ហ្នឹង ត្រូវបានគេចាត់តាំងឲ្យធ្វើប្រធានភូមិ និងអនុប្រធានភូមិហ្នឹងឬ?

**ឆ៖** កាល១នោះគឺ សេង និង ហួន មិនទាន់បានមកធ្វើជាប្រធានភូមិនៅក្នុងភូមិហ្នឹងទេ ទទេ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែលោកបានឆ្លើយថាអ្នកទាំងពីរនេះនៅក្នុងឆ្នាំ១៩៧៥ ត្រូវបានគេចាត់តាំងឲ្យធ្វើជាប្រធានភូមិ និងអនុប្រធានភូមិ។ អ៊ីចឹងហើយបានជាខ្ញុំសាកសួរថា ជំនាញការវៀតណាមនៅពេលនុ៎ង នៅពេលដែលអ្នកទាំងពីរក្លាយទៅជាប្រធានភូមិ និងអនុប្រធានភូមិនេះ តើជំនាញការវៀតណាមបានចាកចេញទៅវិញហើយឬនៅ?

**ឆ៖** ពេលដែលអ្នកទាំងពីរមកកាន់ជាប្រធានភូមិ គឺជំនាញការទៅដកចេញមុនយូរហើយ មុនហ្នឹងទៀត។ មុនហ្នឹងហើយ បានគេតែងតាំងឈ្មោះ សេង និង ហួន មកកាន់កាប់នៅភូមិហ្នឹង។

**ស៖** សូមអរគុណច្រើន។ លោកក៏បាននិយាយផងដែរថា មានប្ដីប្រពន្ធបីគូគឺជាប្ដីប្រពន្ធចម្រុះជាតិសាសន៍ ខ្មែរ វៀតណាម។ តើលោកអាចបញ្ជាក់អំពីឈ្មោះ ប្ដី ឬក៏ប្រពន្ធដែលជាជនជាតិវៀតណាមតែបីនាក់ក្នុងចំណោមបីគូនេះបានទេ?

**ឆ៖** ខ្ញុំអាចបញ្ជាក់បាន គឺប្ដីប្រពន្ធទី១គឺ ឡាច នី គឺមានប្រពន្ធជាវៀតណាម។ ទី២ អឿន ដែលមានប្ដីជាវៀតណាមម្ដង គឺឈ្មោះ ជុយ ប្ដីនោះ។ ហើយបើ ឡាច នី ខ្ញុំមិនអាចស្គាល់បានទេ ប្រពន្ធ ខ្ញុំមិនសូវស្គាល់ឈ្មោះទេ។ ហើយមួយទៀត ង៉ាង ហ្នឹងគឺត្រូវជាប្ដីរបស់ តួល តិច នៅភូមិជាមួយគ្នាហ្នឹង ប្ដី នាងតិច ហ្នឹង។

[១៥:៥២:៥៨]

**ស៖** លោកបានឆ្លើយថា លោកមិនអាចប្រាប់ឈ្មោះប្រពន្ធជាជនជាតិវៀតណាមរបស់ ប្រាក់ នី បានទេ។ បើខ្ញុំនិយាយឈ្មោះ ស៊ុម សាន ហ្នឹង តើឬ ស៊ុម សន នេះ តើ១វាអាចជួយរំឭកដល់ឈ្មោះនេះដែរទេ?

**ឆ៖** កាលសម័យនុ៎ង គឺខ្ញុំមិនសូវជាយកចិត្តទុកដាក់ជាមួយឈ្មោះហ្នឹងដែរ ស្គាល់តែប្ដីជាងគេហ្នង ប្ដីស្គាល់ប្ដី តែត្រង់ប្រពន្ធមិនសូវស្គាល់។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

លោកប្រធាន ខ្ញុំសុំការអនុញ្ញាតផ្ដល់ជូនសាក្សី នូវឯកសារមួយពីមជ្ឈមណ្ឌលឯកសារកម្ពុជា

ត្រង់ទំព័រទី១ គឺឯកសារ E3/7562 គឺដើម្បីសួរទៅសាក្សីសម្តីរបស់សាក្សី 2-TCW-869 ដើម្បីចង់ដឹងថាតើសាក្សីនៅចំពោះមុខនេះស្គាល់សាក្សីរូបនេះដែរឬក៏អត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី សូមលោកកុំបញ្ចេញឈ្មោះសាក្សីម្នាក់នេះណា៎ គឺលោកគ្រាន់តែជម្រាបជូនអង្គជំនុំជម្រះថា តើលោកស្គាល់ឈ្មោះនេះដែរឬក៏អត់បានហើយ? លោកស្គាល់ទេ?

**លោក ថេង ផល៖**

**ផ៖** ឈ្មោះហ្នឹងគឺខ្ញុំមិនដែលស្គាល់ទេលោកគ្រូ សូមអត់ទោសចុះ មិនដែលដឹងទេ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមសួរបុគ្គលម្នាក់ទៀត លោកប្រធានខ្ញុំសូមការអនុញ្ញាតម្តងទៀត។ គឺទំព័រទី១ នៃឯកសារ E3/7594 ក៏ជាឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ គឺ [2-TCW-957] ខ្ញុំចង់សួរសាក្សីនៅចំពោះមុខថា តើសាក្សីចំពោះមុខនេះស្គាល់បុគ្គលសាក្សីមួយនេះដែរឬក៏អត់?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៥៧:៤៧]

**លោក ថេង ផល៖**

**ផ៖** ឈ្មោះក្នុងនេះគឺខ្ញុំមិនអាចស្គាល់បានទេ ព្រោះខ្ញុំមិនដែលស្គាល់មែន។

**ស៖** សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំចាប់ផ្តើមសួរ ទោះបីជាគាត់មិនស្គាល់សាក្សីទាំងនេះក្តី ដើម្បីប្រតិចារឹកនោះគឺសាក្សីម្នាក់ គឺឯកសារ E3/5244, ERN ជាភាសាអង់គ្លេស 00233299, ខ្មែរ 00224794, បារាំង 00231948។ សាក្សីរូបនេះបានបញ្ជាក់ពីឈ្មោះបុគ្គលដែលខ្ញុំទើបតែសួរសាក្សីចំពោះមុខអម្បាញ់មិញនេះ។ ហើយខ្ញុំព្យាយាមប្រើប្រាស់តែរហស្សនាមរបស់គាត់ដោយមិនប្រើប្រាស់ឈ្មោះរបស់សាក្សីម្នាក់នេះទេ។

លោកសាក្សី ដើម្បីជួយរំឭកដល់ការចងចាំរបស់លោកសូមលោកជួយរៀបរាប់តាមដែលលោកអាចចាំទៅបាននៅជនជាតិវៀតណាមទាំងបីនាក់នេះ ព្រមទាំងប្តី ឬប្រពន្ធរបស់ពួកគេដែលមកពីភូមិ

ពោធិ៍ចិន្ដាំ?

**ឆ៖** ឈ្មោះទាំងបីនេះ គឺមានឈ្មោះ ង៉ុយ ហើយនិង តាជី, ប្រពន្ធឈ្មោះ អឿន។ ហើយង៉ុយ ហ្នឹង ប្រពន្ធឈ្មោះ តិច។ បើ នីហ្នឹង គឺខ្ញុំមិនអាចស្គាល់ប្រពន្ធបានទេ ខ្ញុំមិនសូវស្គាល់ទេ។

**ស៖** ប្ដីប្រពន្ធដែលលោកប្រាប់ឈ្មោះអម្បាញ់មិញនេះ ប្ដីឬក៏ប្រពន្ធដែលជាជនជាតិវៀតណាម នេះ ធ្វើម៉េចទើបលោកដឹងថា ប្ដីឬក៏ប្រពន្ធនៃគ្រួសារទាំងបីគ្រួសារនេះ ជាជនជាតិវៀតណាម?

**ឆ៖** ដោយឈ្មោះទាំងបីនេះ គឺដូចជា តិច នេះ គឺជាប្រជាជន នៅក្នុងភូមិហ្នឹងតាំងពីសង្គមចាស់ រហូតមក ហើយគាត់ក៏បានយកប្ដីជាវៀតណាម។ ទី២ ឡាច នី គឺគាត់បានយកប្រពន្ធជាវៀតណាមដែរ តែឮថាយកនៅភ្នំពេញហ្នឹង ហើយកាលសម័យសង្គមចាស់នុ៎ង ហើយខ្ញុំក៏មិនសូវស្គាល់ដែរ។ ដល់ អឿន ហ្នឹង ក៏យកសម័យមុន១៧៥ ទៀត យក១ -- ក្រោយ៧៥ មិនយកមុនទេ យកក្រោយ៧៥ ហើយស្គាល់ គាត់១ជាប្រជាជនចាស់ដែរ អឿន ហ្នឹងគឺជាអ្នកភូមិនៅពោធិ៍ចិន្ដាំទាំងអស់គ្នា ទាំងបីនាក់ហ្នឹង។

[១៦:០១:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកយកចិត្តទុកដាក់ស្ដាប់សំណួររបស់ខ្ញុំបន្តិចដោយ-សារថាយើងខ្ញុំមានពេលវេលាខ្លី។ សំណួរខ្ញុំសួរថា មនុស្សដែលលោកបានបញ្ជាក់ថាជាជនជាតិវៀតណាម ប្ដីឬក៏ប្រពន្ធ ដូចជាប្រពន្ធរបស់ ឡាច នី ប្រពន្ធរបស់គាត់ លោកអត់ស្គាល់ឈ្មោះទេ ហើយ ជុយ គឺជា ជនជាតិវៀតណាម ហើយ ង៉ុយ ជាជនជាតិវៀតណាម។ តើធ្វើម៉េចបានជាលោកដឹងថា អ្នកទាំងបីនាក់ នេះ ជាជនជាតិវៀតណាម?

**ឆ៖** ព្រោះអ្នកទាំងបីហ្នឹង គេ អ្នកដែលដូចជាប្ដីឈ្មោះ ប្ដីនាងតិច ហ្នឹង គឺកាលហ្នឹងគាត់មក នៅរកស៊ីនៅ១ស្រុកហ្នឹង គឺគាត់បានជួបគ្នា យកគ្នាទៅ កាលសម័យសង្គមចាស់ហ្នឹង។ ហើយបើឈ្មោះ ជុយ ហ្នឹងក៏អ៊ីចឹងដែរ គាត់មករកស៊ីក៏បានជួប អឿន ហ្នឹង ក៏យកគ្នាដែរទៅ។ បានដឹងថាគាត់ជួបគ្នាពី សង្គមចាស់ហ្នឹង។ ហើយបើ ឡាច នី នេះ គឺខ្ញុំដឹងដែរ តែថាដឹងថាគាត់យកប្រពន្ធនៅភ្នំពេញ តែប្រពន្ធ ហ្នឹង ជាអ្នកបម្រើនៅហាង ជាស្រីវៀតណាមដែរ។ តែប៉ុណ្ណឹងទេ អត់ដឹងរឿងអីថាយ៉ាងម៉េច១ ឈ្មោះ ហ្នឹង ខ្ញុំមិនស្គាល់ទេ។ បាទ ស្គាល់ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរសំណួរឲ្យចំតែម្ដង។ តើលោកដឹង ថាពួកគាត់ជាជនជាតិវៀតណាមដោយសារ តែពួកគាត់និយាយតុង និយាយភាសាខ្មែរ តុងខុសពីជនជាតិខ្មែរ ឬក៏មើលទៅអាការៈខាងក្រៅថាមាន លក្ខណៈសម្បត្តិហ្នឹងវាខុសគ្នាពីជនជាតិខ្មែរ។ តើអ៊ីចឹងឬក៏យ៉ាងណាដែរ?

**ឆ៖** ខ្ញុំសូមជម្រាបប្រាប់ថា ដែលខ្ញុំសម្គាល់បាន ទៅលើទី១ ទៅលើពាក្យសម្ដីដែលគាត់និយាយមក គាត់មិនចំជាខ្មែរ គាត់និយាយរាងប៉ែឡាំ ជាវៀតណាម។ ដូច្នេះបានខ្ញុំដឹងថាគាត់ជា និយាយវៀត-ណាម ទាំងជុយ ទាំងជុំយហ្នឹង ទាំងពីរហ្នឹង ហើយនិងប្រពន្ធ នី ហ្នឹងក៏ខ្ញុំមិនទាន់បានដឹងដែរ ប៉ុនគ្រាន់ដឹងថាជាប្រពន្ធជាវៀតណាម តែខ្ញុំជួបគាត់តែមិនសូវបាននិយាយជាមួយទេ ខ្ញុំក៏មិនដែលនៅក្បែរគ្នា ផ្ទះនៅឆ្ងាយណាស់។

[១៦:០៥:០៤]

**ស៖** តើលោកនិងអ្នកភូមិរបស់លោកនោះ អាចសន្និដ្ឋានថាអ្នកណាជាជនជាតិវៀតណាមដោយសំអាងទៅលើមុខមាត់ សំអាងទៅលើពណ៌សម្បុរស្បែក ឬក៏សំអាងទៅលើអ្វីមួយដែរនោះបានទេ?

**ឆ៖** ក្នុងភូមិខ្ញុំ គឺមានការសម្គាល់ដោយសារទៅលើការពាក្យសម្ដី។ ទី១ សម្ដីគាត់មិនសូវជាច្បាស់ជាភាសាខ្មែរទី១។ ទី២ ដឹងថាគាត់ហ្នឹងជាអាណិជនវៀតណាមមែន គាត់មករកស៊ី ដូចជាគាត់មករកស៊ីផ្សេងៗកាលនុ៎ង ហើយដល់ហើយគឺមានការពាក់ព័ន្ធស្រឡាញ់គ្នាយកគ្នាទៅ ពួកហ្នឹង បានដឹងហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។

បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៦ ខែមករា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ថេង ផល បន្តបញ្ចប់ និងអាចមានសាក្សីបម្រុងដែលមានរហស្សនាម 2-TCW-904 ហើយដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តិទៅលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិចាម។ ហើយដោយសារនាពេលដំបូងនៃការចាប់ផ្ដើមសវនាការ អង្គជំនុំជម្រះនឹងធ្វើសវ-នាការស្ដាប់សារណាផ្ទាល់មាត់របស់ភាគីលើសំណើសុំចំនួនបី ដែលសុំឲ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីថ្មីបន្ថែម ហើយនិងសូមឲ្យទទួលយកឯកសារមួយចំនួនជាឯកសារភស្តុតាងដាក់ក្នុងសំណុំរឿង ០០២/០២ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:០៧:០៣]

ហើយអង្គជំនុំជម្រះអរគុណលោក ថេង ផល ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោក

ក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកឲ្យបន្តផ្តល់សក្ខីកម្ម នៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក ថេង ផល ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ តែដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់របស់ភាគីទៅលើសំណើសុំទាំងបី អាស្រ័យហេតុនេះ នៅព្រឹកស្អែកនេះ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលឲ្យសាក្សី ថេង ផល នៅរង់ចាំនៅបន្ទប់រង់ចាំសាក្សី សម្រាប់ អ.វ.ត.ក ជាមុនសិន ហើយរង់ចាំអង្គជំនុំជម្រះសាលាដំបូងកោះហៅគាត់ឲ្យចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាសការនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៨នាទី)*